ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 14-Mar-2012, 15:32
CMS/CFO: Sann Rada

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>

# <u>ជំនុំជម្រះក្ដីនៅដំណាក់កាលដំបូង</u>

## <u>សាធារណៈ</u>

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១២**

**ម៉ោង ០៩:០៥ នាទី**

**សវនាការលើកទី៣៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ធូ មណី (បម្រុង)
ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី
លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាវស្មី
លោក វេង ហ៊ាត់
លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*
លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

លោក អេនឌ្រូ អ៊ីនូហ្ស៊ី *(Mr Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោកស្រី អង់តា ហ្គីសសេ

*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

លោក អាង ឧត្តម

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ហុង គីមសួន

លោក ឡោ ជុនធី

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

លោកស្រី ជេត វណ្ណលី

លោកស្រី ទី ស្រ៊ីនណា

លោក គីម ម៉េងឃី

លោក វ៉ែន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោកស្រី ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក វេង ហ៊ត់ | ខ្មែរ |
| លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល | បារាំង |
| លោក ថារីក អាប់ឌុលឡាក់ | អង់គ្លេស |
| លោក អេនឌ្រូ អ៊ីនូហ្ស៊ី | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក អង់តា ហ្គីសសេ | បារាំង |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

[០៩:០៥:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តាមកាលវិភាគដែលបានគ្រោងទុក គឺដោយសារមានការជឿនលឿនតាមជាងអ្វីដែលបានរៀបចំទុកនោះ កាលពីម្សិលមិញ គឺកិច្ចដំណើរការសវនាការគឺបានធ្វើចប់សព្វគ្រប់ ដោយមេធាវីការពារក្តីលោក អៀង សារី បង្ហាញអំពីសេចក្តីជំទាស់របស់ខ្លួនទៅនឹងឯកសារនានា ដែលបានដាក់ ដោយសហព្រះរាជអាជ្ញាចំពោះមុខអង្គ-- ដាក់ដោយសហព្រះរាជអាជ្ញា។ ហើយនៅព្រឹកនេះគឺនឹងចាប់ផ្តើមដោយក្រុមមេធាវីការពារក្តី ខៀវ សំផន។ ក៏ប៉ុន្តែមុននឹងប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ខៀវ សំផន យើងខ្ញុំសូមធ្វើការកែតម្រូវមួយ ទៅលើសេចក្តីសម្រេចទីពីរ កាលពីម្សិលមិញ ត្រង់ការប្រើពាក្យ ថា "វាយតម្លៃភស្តុតាង"។ ពាក្យថា "វាយតម្លៃភស្តុតាង" នេះគឺសូមកែតម្រូវថា "អំពីតម្លៃភស្តុតាង"។

[០៩:០៧:២៩]

អ៊ីចឹង គឺមិនមែនជាការវាយតម្លៃទេ គឺអំពីតម្លៃភស្តុតាង។ ហើយទីពីរ ដោយសារភ្ជាប់នូវបញ្ហាចុងក្រោយ ក្រោយពេលបញ្ចប់នូវកិច្ចដំណើរការសវនាការកាលពីម្សិលមិញ ឃើញថាសេចក្តីសម្រេចនេះ មានការមិនច្បាស់លាស់ជាភាសាបរទេស ជាពិសេសភាសាអង់គ្លេស ដែលបានបកប្រែទៅមិនច្បាស់លាស់។ អ៊ីចឹង ដើម្បីបញ្ជាក់លើបញ្ហានេះឡើងវិញ អង្គជំនុំជម្រះ ខ្ញុំសូមប្រគល់វេទិកាជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីបញ្ជាក់បញ្ហានេះជាភាសាអង់គ្លេស ដើម្បីភាគីដែលពាក់ព័ន្ធបានយល់កាន់តែច្បាស់លើការសម្រេចរបស់អង្គជំនុំជម្រះ។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ ដូចលោកប្រធានបានបញ្ជាក់ហើយ មានភាពលំបាកខ្លះក្នុងការបកស្រាយភាសាអង់គ្លេសកាលពីម្សិលមិញ។ លោកប្រធានបានសម្រេចហើយ ថាអង្គជំនុំជម្រះនឹងមិនសម្រេចផ្តល់ពេលវេលាក្នុងការធ្វើការវាយតម្លៃទៅលើឯកសារមួយចំនួន គឺថាឯកសារ វាយតម្លៃឯកសារណាដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះ ហើយនៅក្នុងពេលធ្វើសេចក្តីសន្និដ្ឋានបិទតែប៉ុណ្ណោះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីចៅក្រម។

ជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីលើកឡើងនូវការជំទាស់របស់ខ្លួនទៅនឹងបណ្តាឯកសារដូចបានបញ្ជាក់នៅក្នុងកថាខណ្ឌ៣ នៃអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០១២ ឯកសារ E172/5 ហើយអង្គជំនុំជម្រះសូមជម្រាបថា ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន មានពេលវេលាមួយព្រឹកនេះ។

សូមអញ្ជើញ!

[០៩:០៩:៣៥]

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ សូមគោរពអង្គសវនាការទាំងមូល។

ខ្ញុំបាទសូមធ្វើការជំទាស់ទៅនឹងការដាក់ឯកសាររបស់សហ-- តំណាងសហព្រះរាជអាជ្ញាដែលមានខ្លឹមសារដូចតទៅ៖

យើងឃើញថា ការដាក់ឯកសាររបស់តំណាងសហព្រះរាជអាជ្ញាត្រូវបានធ្វើឡើងនៅមុនពេលដែលក្រុមប្រឹក្សាជំនុំជម្រះធ្វើសេចក្តីសម្រេចទៅលើការបំបែកសំណុំរឿង នៅក្នុងសំណុំរឿង០០២។ ហើយនិងក្រោយពេលដែលចៅក្រម-- សហចៅក្រមស៊ើបអង្កេត បានចេញដីកាដំណោះស្រាយ។

បញ្ហានេះ យើងមានចំណោទមួយចំនួនដែលធ្វើឲ្យមានការពិនិត្យទៅលើបញ្ជីនេះមានការលំបាកឧទាហរណ៍ចំណុចខ្លះដែលចៅក្រម ដែលក្រុមប្រឹក្សាជំនុំជម្រះបានបង្ហាញអំពីការកំណត់ទៅលើផ្នែកនីមួយៗនៃឧបសម្ព័ន្ធ ហើយដែលការកំណត់នេះបានធ្វើក្រោយពីសហចៅក្រម-- (សូមទោស) ក្រោយពីសហព្រះរាជអាជ្ញាបានចេញ-- បានដាក់ជូននូវភស្តុតាងនូវបញ្ជីឯកសារនោះរួចទៅហើយ។

[០៩:១១:២៣]

ជាចំណោទនោះ យើងឃើញមានបញ្ហាជាច្រើន ដែលៗមានភាពច្របូកច្របល់នៅក្នុងនេះ ហើយដែលយើងខ្ញុំសូមធ្វើការបញ្ជាក់ជាលក្ខណៈទូទៅ ក្នុងដំណាក់កាលដំបូងនេះជារួមសិន។ ទីមួយ ទាក់ទងទៅនឹងអង្គហេតុ ដែលក្រុមប្រឹក្សាជំនុំជម្រះកំណត់យកទៅធ្វើការជំនុំជម្រះនៅពេលក្រោយ ឧទាហរណ៍ដូចជាអង្គហេតុពាក់ព័ន្ធទៅនឹងសហករណ៍ អង្គហេតុពាក់ព័ន្ធទៅនឹងការដ្ឋាន ពាក់ព័ន្ធទៅនឹង

មន្ទីរសន្តិសុខ កន្លែងសម្លាប់មនុស្ស ឬអង្គហេតុពាក់ព័ន្ធទៅនឹងការផ្លាស់ប្តូរលំនៅប្រជាពលរដ្ឋ ដែលត្រូវយកទៅដាក់នៅក្នុងដំណាក់កាលទីបី ហើយដែលមិនត្រូវលើកយកមកដេញដោលនៅក្នុងពេលជំនុំជម្រះលើកដំបូងនាពេលនេះទេ។

ដូច្នេះ យើងឃើញថា ឯកសារមួយចំនួនដែលមាននៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាមិនមែនសម្រាប់ធ្វើការជំនុំជម្រះនៅពេលនេះទេ ហើយឯកសារទាំងអស់នោះ ដែលត្រូវលើកទៅពិភាក្សានៅពេលក្រោយ។ ដូច្នេះ ខាងមេធាវីការពារលោក ខៀវ សំផន នឹងមិនពិនិត្យទៅលើឯកសារដែលក្រុមប្រឹក្សាជំនុំជម្រះបានសម្រេចថា នឹងត្រូវពិភាក្សានៅពេលក្រោយនោះទេ។

[០៩:១២:៥៩]

លើសពីនេះទៀត ចំពោះបទចោទប្រកាន់ដែលមានដូចជា បទប្រល័យពូជសាសន៍ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ដែលជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ត្រូវទុកលើកទៅដេញដោលនៅដំណាក់កាលនៃនីតិវិធីបន្ទាប់ផងដែរ។

ចំណុចទីពីរ អង្គជំនុំជម្រះសាលាដំបូងក៏បានចេញសេចក្តីសម្រេចផងដែរទៅលើការបំបែកកិច្ចនីតិវិធីប្រឆាំងទៅនឹងជនជាប់ចោទ អៀង ធីរិទ្ធ ហើយចំណុចនេះខ្ញុំបានស្តាប់ឮលោកមេធាវី ម៉ៃខល កាណាវាស បានបង្ហាញពីម្សិលមិញហើយ ដែលឯកសារមួយចំនួនទាក់ទងទៅនឹងជនជាប់ចោទ អៀង ធីរិទ្ធ នេះ មិនគួរលើកយកមកពិភាក្សានៅពេលនេះទេ។ ហើយដែលមេធាវីការពារលោក ខៀវ សំផន ក៏មិនបានយកឯកសារទាំងអស់នោះមកធ្វើការជំទាស់ដែរ ដោយគិតថា វាមិនមែនជារឿងដែលពាក់ព័ន្ធជាមួយនឹងកូនក្តីរបស់ខ្លួន ហើយដូច្នេះ មេធាវីការពារលោក ខៀវ សំផន នឹងមិនធ្វើការជំទាស់ទៅលើឯកសារនោះ នៅពេលនេះទេ។

[០៩:១៤:៣៤]

ទីបី ឯកសារមួយចំនួនធំដែលមាននៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញា មិនមានលក្ខណៈពាក់ព័ន្ធទៅនឹងសាច់រឿង ទៅនឹងសំណុំរឿង ដែលយើងនឹងយកមកពិភាក្សានេះ។ ចំណុចនេះគឺបានការពារ ឬក៏លើកឡើងនៅក្នុងវិធានផ្ទៃក្នុងត្រង់វិធាន៨៧(៣)(ក) ដែលអង្គជំនុំជម្រះសាលាដំបូង អាចបដិសេធចំពោះពាក្យសុំឲ្យពិនិត្យភស្តុតាង បើយល់ឃើញថាភស្តុតាងទាំងអស់នោះ មិនជាប់ពាក់ព័ន្ធ។ បញ្ហានេះគឺជាឆន្ទានុសិទ្ធិរបស់ក្រុមប្រឹក្សាជំនុំជម្រះក្នុងការសម្រេច ថាតើភស្តុតាងដែលដាក់ជូនដោយ

សហព្រះរាជអាជ្ញាហ្នឹងមានភស្តុតាង ឬឯកសារណាដែលមិនជាប់ពាក់ព័ន្ធ ហើយដែលក្រុមប្រឹក្សាជំនុំជម្រះអាចបដិសេធចោល។

ទីបួន ចំពោះឯកសារថ្មី យើងឃើញថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចរបស់ខ្លួនលេខ E172/5 ដែលបានបញ្ជាក់អំពីការកំណត់ចំពោះឯកសារថ្មី ដែលនឹងត្រូវយកទៅពិភាក្សានៅក្នុងឧបសម្ព័ន្ធ២១ ដែលមាននីតិវិធីពិភាក្សាដោយឡែកមិនស្ថិតនៅក្នុងការដេញដោលនៅពេលនេះទេ។

[០៩:១៦:២២]

ហើយអ្វីដែលជាការកត់សម្គាល់របស់ក្រុមមេធាវីការពារលោក ខៀវ សំផន ឃើញថា ឯកសារថ្មីនេះ គឺមានរាយប៉ាយនៅគ្រប់ *អាន់ណិច* នៅគ្រប់ឧបសម្ព័ន្ធទាំងអស់ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា ដែលបានដាក់ជូនដោយសហព្រះរាជអាជ្ញា។ ដូច្នេះ បើយើងពិនិត្យទៅលើឯកសារថ្មីនេះគឺមានចំនួនរហូតទៅដល់៣៤១ឯកសារ។ ហើយឯកសារទាំងនេះក្រុមមេធាវីការពារលោក ខៀវ សំផន ក៏មិនលើកយកមកពិចារណា យកមកពិភាក្សាដេញដោល ឬធ្វើការជំទាស់នៅពេលនេះទេ។ ដោយហេតុថា ឯកសារនោះមិនត្រូវពេលសម្រាប់យកមកសួរដេញដោលនៅក្នុងសវនាការនាពេលនេះ ហើយដែលយើងយល់ថា អង្គជំនុំជម្រះនឹងមានការបើកសួរដេញដោលសម្រាប់ឯកសារថ្មីទាំងអស់នេះនៅសវនាការពេលក្រោយ។

[០៩:១៧:៤៤]

ចំណុចទីប្រាំ ទាក់ទងទៅនឹងជំហរជាគោលការណ៍ស្តីពីកំណត់ហេតុអះអាងនានា ដែលមាននៅក្នុងឯកសារទាំងការឆ្លើយបញ្ជាក់របស់សាក្សីជាដើម ដែលចោទ ឬលើកឡើងអំពីសកម្មភាព ឬអាកប្បកិរិយារបស់ជនជាប់ចោទ យើងខ្ញុំសូមទាមទារឲ្យមានការសួរដេញដោលចំពោះអ្នកដែលបានផ្តល់នូវកំណត់ហេតុអះអាងទាំងអស់នោះ។ ដើម្បីអី? គឺដើម្បីស្វែងរកការពិតថាតើកំណត់ហេតុ កំណត់អះអាងដែលបានធ្វើឡើងដោយបុគ្គលទាំងឡាយណាដែលជាប់ពាក់ព័ន្ធ ដែលលើកចោទប្រកាន់ចំពោះអាកប្បកិរិយា ឬសកម្មភាពរបស់ជនជាប់ចោទនោះ ថាពិតដូចអ្វីដែលមាននៅក្នុងសំណេរ នៅក្នុងកំណត់ហេតុនោះដែរឬទេ?

[០៩:១៨:៤៦]

ដូច្នេះការផ្តល់ឱកាសសម្រាប់ឲ្យមេធាវីលោក ខៀវ សំផន ក៏ដូចជាក្រុមការពារដទៃទៀតធ្វើការ

ដេញដោលចំពោះកំណត់ហេតុទាំងអស់នោះវាជាការចាំបាច់ ហើយដែលមានការអនុវត្តជាគោលការណ៍ទៅលើច្បាប់អន្តរជាតិផងដែរ។

ទាក់ទងទៅនឹងឯកសារថ្មីដែលមានចំនួន៣៤១។ ឯកសារដែលខ្ញុំបានលើកអម្បាញ់មិញនេះ ក្រុមមេធាវីការពារលោក ខៀវ សំផន សូមស្នើថា សហព្រះរាជអាជ្ញាគួរពិនិត្យទៅលើឯកសារទាំងអស់នេះសាជាថ្មី ហើយមើលថា តើឯកសារថ្មីទាំងអស់នេះវាជាប់ពាក់ព័ន្ធទៅនឹងបរិបទដែលយើងត្រូវធ្វើការជំនុំជម្រះនៅក្នុងផ្នែកទីមួយនេះ ប៉ុនណា? ហើយដែលអាចគួរដកចេញនូវឯកសារណាដែលមិនជាប់ពាក់ព័ន្ធទៅនឹងសំណុំរឿងនេះ ឬក៏មិនជាប់ពាក់ព័ន្ធទៅនឹងសវនាការនាពេលនេះ ដើម្បីកាត់បន្ថយនូវចំនួនឯកសារដែលមិនចាំបាច់។

[០៩:២០:០៨]

ព្រោះថា មេធាវីការពារមិនគួរត្រូវធ្វើការជំទាស់រាល់ឯកសារទាំងអស់ដែលដាក់មកដោយសហព្រះរាជអាជ្ញានោះទេ ពីព្រោះមានគោលការណ៍ការកម្រិតនូវភាពជាប់ពាក់ព័ន្ធរបស់ឯកសារទៅនឹងដំណើរការនៃសវនាការនេះផងដែរ។ បើសិនជាឯកសារ-- បើសិនជាសហព្រះរាជអាជ្ញាយល់ឃើញថា ឯកសារដែលលោកបានដាក់មិនជាប់ពាក់ព័ន្ធនៅនឹងនីតិវិធីនាពេលនេះ លោកគួរដកចេញឲ្យហើយទៅ។ ហើយធ្វើបែបនេះ វាកាត់បន្ថយចំពោះការចំណាយពេលវេលាទៅលើការជំទាស់នេះផងដែរ។ ហើយម្យ៉ាងទៀត យើងអាចពិនិត្យទៅលើខ្លឹមសារចាំបាច់ដែលជាប់ពាក់ព័ន្ធទៅនឹងសំណុំរឿងនេះ។

[០៩:២១:០០]

ពីម្សិលមិញខ្ញុំបាន អង្គសវនាការក៏បានស្ដាប់នូវការជំទាស់របស់មេធាវីពីរក្រុមរួចហើយ ហើយដែលយើងខ្ញុំធ្វើទៅតាមកម្រិតដែលអ្វីដែលជាចំណុចថ្មីសម្រាប់ក្រុមយើងខ្ញុំ ហើយមិនលើកនូវចំណុចដដែលៗច្រើនពេកទេ ដើម្បីចៀសវាងការចំណាយពេលវេលា។ ហើយជាបន្តទៀតនេះ ខ្ញុំបាទសូមលោកប្រធានមេត្តាអនុញ្ញាតឲ្យសហភាតា មេធាវី អង់តា ហ្គីសសេ ឡើងបង្ហាញចំពោះចំណុចជាក់លាក់ដែលក្រុមយើងខ្ញុំធ្វើការជំទាស់ចំពោះឯកសារ។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកស្រីមេធាវី!

[០៩:២១:៥៧]

**លោកស្រី អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ។

ជាដំបូងខ្ញុំសូមចាប់ផ្ដើមទៅចំពោះអ្វីដែលយើងចាត់ទុកថាជាព័ត៌មានថ្មីនោះ គឺជាការជំទាស់របស់ក្រុម ខៀវ សំផន គឺថាមានលក្ខណៈខ្លីជាងអ្វីដែលយើងបានគិតទុក។ ដោយសារតែមានការជំទាស់ដែលមានភាគីការពារក្ដីផ្សេងៗទៀតបានលើករួចមកហើយ។ ដូច្នេះវាជាផលប្រយោជន៍ ដោយសារតែយើងឡើងថ្លែងជាអ្នកទីបីដូច្នេះ យើងព្យាយាមធ្វើយ៉ាងម៉េចដើម្បីឱ្យមានការខ្លី មានភាពច្បាស់លាស់។ ហើយចៀសវាងក្នុងការនិយាយច្រំដែលដដែលៗ នូវអ្វីដែលបានលើកឡើងរួចមកហើយដោយភាគីផ្សេងទៀត។

[០៩:២២:៥៧]

ដើម្បីចៀសវាងនូវការនិយាយច្រំដែលឥតប្រយោជន៍នោះ ខ្ញុំនឹងព្យាយាមគូសបញ្ជាក់អំពីធាតុផ្សំសំខាន់ ដែលយើងគិតថា មានលក្ខណៈចាំបាច់ ដោយបំពេញបន្ថែមនូវការកត់សម្គាល់ដែលបានធ្វើកាលពីម្សិលមិញនេះ។ ខ្ញុំនឹងចាប់ផ្ដើមដោយឧបសម្ព័ន្ធ A6។

ឧបសម្ព័ន្ធលេខ៦ នេះពាក់ព័ន្ធទៅនឹងឯកសារដែលមានលក្ខណៈទូទៅ ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា គឺមានប្រវត្តិរូបសង្ខេបនៃកម្ពុជាប្រជាធិបតេយ្យ។ ចំពោះឯកសារទាំងអស់នេះ គឺមានការលើកជំទាស់ជាច្រើនរួចមកហើយ ជាពិសេសខាងភាគី អៀង សារី។ ហើយយើងសូមគាំទ្រទាំងស្រុងទៅលើអ្វីដែលបានលើកឡើងដោយលោកខាង អៀង សារី ជាពិសេស គឺថាពាក់ព័ន្ធទៅនឹងសវនាការដំបូងនេះ។

[០៩:២៤:០៣]

ហើយខ្ញុំសូមគូសបញ្ជាក់បន្ថែមនូវបញ្ហាមួយ ដែលបានលើកឡើងដោយភាគីការពារក្ដីរបស់យើងនៅក្នុងអំឡុងសវនាការកាលពីខែធ្នូ ឆ្នាំមុននេះ គឺយើងមានបញ្ហាពាក់ព័ន្ធទៅនឹងខ្សែសង្វាក់នៃការថែរក្សា និងការទទួលយកឯកសារ គឺខ្សែសង្វាក់នៃការកាន់កាប់ឯកសារ បើនិយាយឱ្យចំ។ ឧទាហរណ៍ ខ្ញុំនឹងលើកឡើងនូវឯកសារ D306/7.1.8.2.9 ឯកសារ 366/7.1.8.30 ឯកសារ D366/6.1.27 ឯកសារនេះ គឺជាឯកសារដែលគេសន្មតថាជាឯកសារដែលចេញមកពីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ

ដោយយើងមិនដឹងច្បាស់ទេថា តើឯកសារទាំងអស់នេះទទួលបានពីណា? ហើយទទួល-- អ្នកណាជាអ្នកទទួលបាន? ហើយទទួលបាននៅក្នុងលក្ខខណ្ឌណាខ្លះ? ហើយការសរសេរនោះ កើតឡើង-- សរសេរនៅក្នុងលក្ខខណ្ឌណាខ្លះ? នោះយើងអត់ដឹងនោះទេ។

[០៩:២៥:៣២]

ដូចគ្នាផងដែរ យើងមានឯកសារដែលដាក់ជាឧបសម្ព័ន្ធទៅនឹងសេចក្តីថ្លែងការណ៍របស់សាក្សី គឺឯកសារ D125/138.3 ឯកសារ D125/138.5 ឯកសារទាំងពីរនេះគឺជាឧបសម្ព័ន្ធទៅនឹងសេចក្តីថ្លែងការណ៍របស់សាក្សី TCW-435 (សូមទោស) 437។ នៅពេលដែលគឺយើងវិភាគកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីនេះគឺថា យើងមិនដឹងច្បាស់លាស់ទេថា ឯកសារនេះចេញមកពីណានោះ។ ហើយនៅក្នុងសេចក្តីថ្លែងការណ៍នោះ សាក្សីបានបញ្ជាក់ថា គាត់ស្គាល់ឈ្មោះដែលមាននៅ-- មនុស្សដែលមាននៅក្នុងឯកសារទាំងអស់នេះ។

ដូច្នេះលក្ខខណ្ឌទាំងអស់នេះ យើងៗសន្និដ្ឋានថា គឺថាឯកសារទាំងអស់នោះមិនមានភាពគួរឲ្យជឿជាក់បានទេ យើងត្រូវ-- ដូច្នេះអង្គជំនុំជម្រះត្រូវតែបដិសេធចោលឯកសារទាំងអស់នេះ។

ហើយខ្ញុំសូមរំឭកថា យើងសូមជំទាស់ទៅនឹងការដាក់របាយការណ៍វិភាគរបស់លោក ក្រេក អេតឆេសាន់ ហើយខ្ញុំសូមបង្ហាញលេខយោងដែរ គឺលេខ D2-15.33, D2-15.34, D2-15.36, D2-15.37 យើងមិនមានទទួលបានព័ត៌មានអំពីរបៀបថា តើឯកសារនេះទទួលបានដោយលោក ក្រេក អេតឆេសាន់ ដោយយ៉ាងណាទេ? ហើយនៅក្នុងលក្ខខណ្ឌបែបណាទេ? ដូច្នេះ យើងខ្ញុំសូមជំទាស់ទៅនឹងការដាក់ឯកសារទាំងអស់នេះទៅក្នុងសំណុំរឿង។

[០៩:២៧:៤៦]

ខ្ញុំសូមចូលទៅដល់ឧបសម្ព័ន្ធ A7 ដែលពាក់ព័ន្ធទៅនឹងរបាយការណ៍ពាណិជ្ជកម្មរបស់កម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំសូមឲ្យអង្គជំនុំជម្រះពិនិត្យមើលទៅលើការលើកឡើងដោយលោក គង់ សំអុន កាលពីថ្ងៃទី១៦ ខែ២-- ដូច្នេះ ខ្ញុំសូមលើកឡើងអំពីការជំទាស់ដែលបាន ជំទាស់ដោយខាងមេធាវីរបស់យើង ដែលមាននៅក្នុងឧបសម្ព័ន្ធ២១។ ដូច្នេះ យើងមិនបានផ្តោតទៅលើឯកសារថ្មីនោះទេ គឺថាមានការជំទាស់រួចមកហើយ ហើយនៅពេលដែលយើងលើកអំពីឧបសម្ព័ន្ធ២១ យើងនឹងលើកការជំទាស់ដដែលនេះ។

[០៩:២៨:៣៨]

ពាក់ព័ន្ធទៅនឹងរបាយការណ៍ពាណិជ្ជកម្មនេះ គឺថាយើងសូមផ្តោតទៅលើអ្វីដែលយើងបានលើកឡើងរួចមកហើយ គឺពាក់ព័ន្ធទៅនឹងខ្សែសង្វាក់នៃការទទួល និងការថែរក្សាឯកសារនេះ វាមានបញ្ហាពាក់ព័ន្ធនឹងខ្សែសង្វាក់នេះ គឺថាមិនមានលក្ខណៈច្បាស់លាស់នោះទេ។

ខាងយើងបានលើកឡើងរួចមកហើយនូវពីអ្វីដែលយើងបាននិយាយនោះ កាលពីពេលដែលយើងវិភាគអំពីឯកសាររបស់ឌី.ស៊ី.ខេម នោះ ហើយយើងបានស្តាប់សក្ខីកម្មរបស់សាក្សីពីរនាក់ ដែលមកពីខាង ឌី.ស៊ី.ខេម។ ប៉ុន្តែខ្ញុំសូមទាក់ទាញចំណាប់អារម្មណ៍របស់អង្គជំនុំជម្រះថា ឯកសារមួយចំនួនគឺមានចំណារសរសេរដោយដៃ ហើយពាក់ព័ន្ធនឹងការសរសេរដោយដៃនេះ គឺសាក្សី TCW-583 គឺថាគាត់នឹងអាចមកផ្តល់ការបំភ្លឺបន្ថែម ប៉ុន្តែវាមានបញ្ហាខ្លាំងណាស់ ចំពោះខាងមេធាវីការពារក្តី ខៀវ សំផន ដែលថាយើងអាច-- ដែលថាគេទទួលយកឯកសារជាមួយនឹងសំណាក់-- ចំណារដៃ ដោយយើងមិនអាចដឹងថា តើនៅក្នុងលក្ខខណ្ឌណា ដែលគេសរសេរចំណារដៃនេះ? ហើយនៅក្នុងពេលណា?

[០៩:២៩:៥៧]

ហើយជាថ្មីម្តងទៀត ខ្ញុំសូមឲ្យអង្គជំនុំជម្រះពិនិត្យមើលទៅលើសក្ខីកម្មរបស់សាក្សី ដែលមកពីខាង ឌី.ស៊ី.ខេម ដែលគាត់ថា ជួនកាលគឺអាចមានការសរសេរដោយដៃរបស់បុគ្គលិក ឌី.ស៊ី.ខេម នៅលើឯកសារ។ ដូច្នេះសូមឲ្យអង្គជំនុំជម្រះមេត្តាពិភាក្សាឲ្យបានច្បាស់លាស់ទៅលើបញ្ហាឯកសារទាំងអស់នេះ គឺសូមឲ្យអង្គជំនុំជម្រះផ្តោតទៅលើឯកសារទាំងអស់នេះ។ ហើយយើងពិនិត្យមើលទៅថា តើចំណារទាំងអស់នោះ គឺថាមិនមានភាពច្បាស់លាស់នោះទេ។ ហើយយើងក៏មិនដឹងថា តើខ្សែសង្វាក់នៃការទទួល និងការរក្សាឯកសារនោះវាមានយ៉ាងម៉េចនោះដែរ?

[០៩:៣០:៣៣]

ឥឡូវនេះ ខ្ញុំសូមចូលទៅក្នុងឧបសម្ព័ន្ធ A8 ខ្ញុំនឹងនិយាយដោយសង្ខេបទេ ចំពោះចំណុចនេះ។ នេះគឺជាបណ្ណសារនៃស្រុកត្រាំកក់។ ខ្ញុំសូមរំឭកដោយខ្លី អំពីការជំទាស់ជាទូទៅពាក់ព័ន្ធទៅនឹងសវនាការដំបូងនេះ។ ខ្ញុំសូមយោងទៅលើការឡើងជំទាស់ខាងមេធាវី អៀង សារី ខាងក្រុម អៀង សារី បានលើកឡើងនូវការជំទាស់រួចមកហើយ ដោយបាន-- ហើយខ្ញុំសូមលើកឡើងម្តងទៀតថា យើងដឹងថា លោក ប៉ែន យៀវនិន បានបញ្ជាក់ថា គាត់បានធ្វើការថតចម្លងឯកសារទាំងអស់នេះ។ ដូច្នេះយើងដឹងថាមិនមានឯកសារដើមទេ នៅក្នុងដំណាក់កាលនេះ។ ដូច្នេះនៅក្នុងលក្ខខណ្ឌទាំងនេះ អង្គជំនុំជម្រះមិនគួរផ្អែកជាមូលដ្ឋានលើឯកសារទាំងអស់នេះទេ។ ដូច្នេះយើងខ្ញុំសូមជំទាស់ទៅនឹងការដាក់ឯកសារ

ទាំងអស់នេះ។

[០៩:៣១:៥០]

ខ្ញុំសូមចូលទៅឧបសម្ព័ន្ធ A9 និង A10 ខ្ញុំសូមនិយាយឧបសម្ព័ន្ធទាំងពីរនេះចូលគ្នាតែម្តង ហើយខ្ញុំនិយាយខ្លីទេ ពីព្រោះខាងមេធាវី នួន ជា ហើយនិង អៀង សារី នោះ គាត់បានលើកឡើងយ៉ាងច្បាស់លាស់រួចមកហើយពាក់ព័ន្ធទៅនឹងឧបសម្ព័ន្ធ A9, A10 ដូច្នេះខ្ញុំមិននឹងបន្ថយពេលវេលាតុលាការឲ្យវែងនោះទេ។ គឺពាក់ព័ន្ធទៅនឹងចម្លើយសារភាពដែលទទួលបានដោយការធ្វើទារុណកម្ម។ ដូច្នេះខ្ញុំសូមជំទាស់ទៅនឹងភាពពាក់ព័ន្ធនៃឯកសារទាំងអស់នេះ នៅក្នុងដំណាក់កាលដំបូងនេះ ព្រោះវាពាក់ព័ន្ធទៅនឹងមន្ទីរស-២១ នោះទេ វាមិនពាក់ព័ន្ធអ្វីដែលមាននៅក្នុងក្របខ័ណ្ឌនៃសំណុំរឿងរបស់យើងនៅក្នុងសវនាការនេះទេ។

[០៩:៣២:៤៣]

ដូច្នេះខ្ញុំសូមចូលទៅឧបសម្ព័ន្ធ A11 ដែលជាប្រតិចារឹកនៃសំណុំរឿង០០១។ ទោះបីជាបញ្ហានេះត្រូវបាននិយាយដោយខាងមេធាវី កាណាវាស រួចមកហើយក៏ដោយ ក៏ខ្ញុំសូមសង្កត់ធ្ងន់ទៅលើសារៈសំខាន់ក្នុងការច្រានចោលនូវប្រតិចារឹកទាំងអស់នេះ។

យើងស្ថិតនៅក្នុងសំណុំរឿងព្រហ្មទណ្ឌនៃការកាត់ក្តីរឿងព្រហ្មទណ្ឌ។ ដូច្នេះសិទ្ធិដាច់ខាតរបស់ជនជាប់ចោទក្នុងការតទល់ជាមួយនឹងសេចក្តីថ្លែងការណ៍ដែលចោទប្រកាន់ទៅលើគាត់ ឬក៏ដែលបង្ហាញអំពីអំពើនិងការប្រព្រឹត្តរបស់គាត់។ ដូច្នេះច្បាស់ណាស់គឺថា ប្រតិចារឹកនៅក្នុងសំណុំរឿងដែលបានលើកឡើងអំពីអំពើរបស់គាត់នោះ គឺត្រូវតែច្រានចោលទាំងអស់ លើកលែងតែយើងហៅសាក្សីនោះអ្នកដែលបានថ្លែងការណ៍នោះមកតទល់ជាមួយនឹងជនជាប់ចោទ។

[០៩:៣៣:៥០]

នេះជាចំណុចសំខាន់ណាស់ក្នុងក្របខ័ណ្ឌនៃដីកាបញ្ជូនរឿងឲ្យស៊ើបសួរ គឺឯកសារ E9/31 ខ្ញុំសូមយោងទៅលើកថាខណ្ឌ១៩ គឺគេអាចដាក់ចូលទៅនឹងឧបសម្ព័ន្ធ១១ ខ្ញុំសូមស្សូត្រកថាខណ្ឌ១៩ ប្រតិចារឹកនេះនិយាយអំពីសេចក្តីថ្លែងការណ៍ និងសក្ខីកម្មរបស់ ឌុច ហើយនិងដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីមួយចំនួនពាក់ព័ន្ធទៅនឹងស-២១ និងរបបកម្ពុជាប្រជាធិបតេយ្យ។ សក្ខីកម្មនេះបង្ហាញអំពីការពិតនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តទៅនៅមន្ទីរស-២១ ហើយនិងការចូលរួមរបស់ជនជាប់ចោទទៅក្នុងការប្រព្រឹត្តអំពើទាំងអស់នេះ។

[០៩:៣៥:០០]

ច្បាស់ណាស់លោកប្រធាន លោក លោកស្រីចៅក្រម សហព្រះរាជអាជ្ញាគឺចង់ប្រើប្រាស់ឧបសម្ព័ន្ធទាំងអស់នេះ មិនត្រឹមតែដើម្បីលើកឡើងអំពីអង្គហេតុដែលមិនពាក់ព័ន្ធនឹងសវនាការនេះទេ ថែមទាំងលើកឡើងអំពីការចូលរួមរបស់ជនជាប់ចោទទៅក្នុងប្រព្រឹត្តឧក្រិដ្ឋកម្ម។

ដូច្នេះ ក្នុងលក្ខខណ្ឌនេះ គឺយើងមានមូលហេតុពីរដែលត្រូវច្រានចោលនូវឯកសារទាំងអស់នេះ។ ខ្ញុំសូមសង្កត់ធ្ងន់ទៅលើចំណុចនោះ ពីព្រោះថាបន្ទាប់ពីការពិនិត្យផ្ទៀងផ្ទាត់ទៅ គឺមានឯកសារជាច្រើនដែលនៅក្នុងនោះ លោក ខៀវ សំផន ត្រូវបានគេនិយាយឈ្មោះ ឧទាហរណ៍ដូចជាឯកសារ D288/4.74.1 គឺជាជាសេចក្ដីថ្លែងការណ៍របស់លោក រ៉ាអ៊ូល ម៉ាកចេនណា (Raoul Marc Jennar)។ ក្នុងនោះ គឺថាគាត់បានលើកឡើងពីឈ្មោះ ខៀវ សំផន ជាច្រើនលើកច្រើនសា។ ដូចគ្នាផងដែរនៅក្នុងលក្ខខណ្ឌទាំងអស់នេះ យើងសូមជំទាស់ដាច់ខាតក្នុងការដាក់នូវសេចក្ដីថ្លែងការណ៍របស់គាត់នេះទៅក្នុងសំណុំរឿង។ ហើយប្រសិនបើសហព្រះរាជអាជ្ញាចង់ដាក់បញ្ចូលនូវសេចក្ដីថ្លែងការណ៍របស់លោក រ៉ាអ៊ូល ម៉ាកចេនណា ហើយនិងសេចក្ដីថ្លែងការណ៍សាក្សីផ្សេងទៀត សហព្រះរាជអាជ្ញាត្រូវតែស្នើសុំឲ្យអង្គជំនុំជម្រះកោះហៅសាក្សីទាំងអស់នេះមកស្ដាប់សក្ខីកម្មនៅចំពោះមុខតុលាការ ហើយនិងឲ្យភាគីផ្សេងៗទៀតសួរដេញដោល។

[០៩:៣៦:៣៦]

ខ្ញុំសូមចូលទៅឧបសម្ព័ន្ធ A14 ខ្ញុំព្យាយាមនិយាយឲ្យខ្លីបំផុត ដោយសារតែមានការលើកជំទាស់ដោយខាងក្រុមមេធាវីការពារក្ដី អៀង សារី រួចមកហើយ។ ខ្ញុំយល់ថា វាជាការសំខាន់ណាស់ក្នុងការបន្ថែមនូវធាតុផ្សំ ដើម្បីគិតទៅលើភាពពាក់ព័ន្ធនៅក្នុងសវនាការនេះ។ ខ្ញុំសូមឲ្យអង្គជំនុំជម្រះពិនិត្យទៅមើលទៅលើដីកាបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ឯកសារE9/31 ខ្ញុំសូមលើកនូវកថាខណ្ឌ២២។ នៅក្នុងកថាខណ្ឌនេះ សហព្រះរាជអាជ្ញាបានបញ្ជាក់ថាឧបសម្ព័ន្ធ១៤ ដែលខ្ញុំកំពុងតែនិយាយនេះ គឺបង្កើតនូវរបាយការណ៍៥១ នៃទីតាំងដែលកំណត់អត្តសញ្ញាណដែលធ្វើឡើងដោយការិយាល័យសហព្រះរាជអាជ្ញា ពាក់ព័ន្ធទៅនឹងទីតាំងឧក្រិដ្ឋកម្មជាក់លាក់មួយចំនួនដែលស្ថិតនៅក្នុងកម្មវត្ថុនៃការស៊ើបសួរ ហើយនិងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[០៩:៣៨:០០]

នេះជាធាតុផ្សំដ៏សំខាន់ណាស់ដែលថាខាងអង្គជំនុំជម្រះ បានសម្រេច ហើយបន្ទាប់ពីមានការសុំ

ឲ្យដឹកទៅកន្លែងកើតហេតុ ដើម្បីពិនិត្យទៅមើលភូមិសាស្ត្រ ពីរូបសណ្ឋាន ពីទីតាំងដែលពាក់ព័ន្ធ ដែលមានចែងនៅក្នុងដីកាដំណោះស្រាយនោះ អង្គជំនុំជម្រះបានបញ្ជាក់នៅក្នុងដីកាបំបែកកិច្ចស៊ើបសួរលេខ E124 នៅកថាខណ្ឌ៩ ខ្ញុំសូមដកស្រង់៖ “អង្គហេតុទាំងអស់នេះ គឺថាមិនពាក់ព័ន្ធទៅនឹងសហករណ៍ទីតាំងឧក្រិដ្ឋកម្មណានោះទេ”។ ដូច្នេះ នៅក្នុងលក្ខខណ្ឌនេះ យើងបានសម្រេចថាឯកសារដែលពាក់ព័ន្ធទៅនឹងទីកន្លែងឧក្រិដ្ឋកម្មជាក់លាក់ទាំងអស់នោះ គឺមិនពាក់ព័ន្ធនឹងសវនាការដំបូងរបស់យើងនេះទេ។ ហើយនៅក្នុងដំណាក់កាលនេះ ក៏មិនមានភាពពាក់ព័ន្ធនោះដែរ។

[០៩:៣៩:០៨]

ដូច្នេះ យើងខ្ញុំសូមជំទាស់ទៅនឹងការដាក់ឯកសារនោះ ដោយយោងទៅលើវិធាន៨៧ ចំណុចទី៣ (ក) និង (គ)។

ខ្ញុំសូមចូលទៅដល់ឧបសម្ព័ន្ធ A15 ដែលពាក់ព័ន្ធនឹងផែនទី និងរូបថតមួយចំនួន។ វាមានលក្ខណៈស្មុគស្មាញណាស់ក្នុងការឆ្លើយតបជាលក្ខណៈរួមទៅនឹងឯកសារ៤៦០ ឯកសារនោះ ហើយវាមានប្រភព ហើយនិងមានមូលដ្ឋានផ្សេងៗគ្នា។ ជាថ្មីម្តងទៀត ខ្ញុំសូមយោងទៅឯកសារ E9/31 កថាខណ្ឌ២៣នៅពេលដែលបង្ហាញអំពីឧបសម្ព័ន្ធនេះ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា ខ្ញុំសូមដកស្រង់៖ “ផែនទី ពាក់ព័ន្ធនៅកន្លែងដែលកំណត់អត្តសញ្ញាណនៅក្នុងដីកាដំណោះស្រាយ ចាត់ទុកថាជា កន្លែងឧក្រិដ្ឋកម្ម”។ ដូច្នេះ យើងអាចកំណត់បានអំពីផែនទីទាំងអស់នេះ ពីព្រោះវាបញ្ជាក់អំពីទីតាំងនៃសម័យកម្ពុជាប្រជាធិបតេយ្យ ហើយបន្តមកទៀត សហព្រះរាជអាជ្ញាបានពន្យល់ថា នេះគឺជារូបថត នៃទីតាំងឧក្រិដ្ឋកម្ម ហើយនិងហេតុការណ៍ដែលជាកម្មវត្ថុនៃដីកាដំណោះស្រាយ រួមទាំងមានមន្ទីរស-២១ ហើយមន្ទីរសន្តិសុខថ្នាក់តំបន់ ទីតាំងសម្លាប់មនុស្ស ការដ្ឋានការងារ ឧទាហរណ៍ដូចជាការដ្ឋានសាងសង់ទំនប់ប្រាំពីរមករា។ នេះ គឺឯកសារដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅស៊ើបសួររបស់សហព្រះរាជអាជ្ញា។ ហើយមានឯកសារជាច្រើន ដែលមិនពាក់ព័ន្ធទៅនឹងដំណាក់នៃសវនាការកាលដំបូងនេះទេ ហើយឯកសារទាំងអស់នេះ មិនមានភាពពាក់ព័ន្ធទេ។ ឧទាហរណ៍ ឯកសារ D108/19/1/5 នេះគឺគំនូសបំព្រួញនៃទីតាំងសម្លាប់មនុស្ស។ ខ្ញុំសូមលើកឡើងនូវឯកសារ D108/39/10 នេះគឺជាផែនទីប្រទេសកម្ពុជាដែលមានទីតាំងរណ្តៅសាកសពរួម ហើយមិនមានមន្ទីរសន្តិសុខផងដែរ។

[០៩:៤១:៥១]

ដូច្នេះ គឺវាស្ថិតនៅក្រៅក្របខ័ណ្ឌនៃដំណាក់កាលនៃសវនាការនេះ ដូច្នេះសូមអង្គជំនុំជម្រះមេត្តាច្រានចោលនូវឯកសារទាំងអស់នេះ។ ហើយយើងមានឯកសារមួយចំនួនដែលមិនមានជាផែនទីទេ គឺឯកសារដែលមានជាគំនូសបំព្រួញ ដែលអត្ថាធិប្បាយទៅដោយសាក្សីដែលត្រូវបានស្តាប់ចម្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត។ ដូច្នេះ ជាការសំខាន់ណាស់ ដែលយើងត្រូវតែសួរដេញដោលសាក្សីទាំងអស់នេះ ប្រសិនបើសក្ខីកម្មរបស់ពួកគាត់ត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងនោះ។

ខ្ញុំសូមយោងទៅលើឯកសារ D276/7.3.5 នៅក្នុងនោះមានផែនទីមួយដែលបង្ហាញអំពីការដាក់ពង្រាយទ័ពនៅក្នុងខេត្តមួយ ហើយខេត្តនេះត្រូវបានចារដោយដៃដោយសាក្សីដែលបង្ហាញអំពីការដាក់ពង្រាយទ័ព ដូច្នេះវាមិនស្ថិតនៅក្នុងក្របខ័ណ្ឌនៃសវនាការនេះទេ។ ហើយយើងត្រូវតែមានការបំភ្លឺបន្ថែមពីសាក្សីនេះ ដើម្បីអាចសួរដេញដោលសាក្សីរូបនេះ ដើម្បីទទួលយកនូវសក្ខីកម្មរបស់គាត់។

ខ្ញុំសូមនិយាយអំពីតម្រុយនៃភាពអាចជឿជាក់បាន ទៅលើឯកសារមួយចំនួនដែលបានទទួល។ ខ្ញុំនឹងលើកឡើងឧទាហរណ៍មួយចំនួនពាក់ព័ន្ធទៅនឹងផែនទី ដែលទទួលបានអំពីបណ្ណាសារនៃមជ្ឈ-មណ្ឌលវៀតណាម។

[០៩:៤៣:៣៤]

បណ្ណាសាររបស់វៀតណាម-- មជ្ឈមណ្ឌលវៀតណាមនេះ គឺជាការ-- ជាអំណោយដែលបានមកពីអតីតយុទ្ធជន ឬក៏ជាបុគ្គលឯកជន។ ហើយនៅពេលដែលយើងទៅមជ្ឈមណ្ឌលវៀតណាមនេះ សូមអភ័យទោសផងដែរ ពីព្រោះខ្ញុំនឹងលើកឡើងជាភាសាអង់គ្លេសនូវឃ្លាដែលមាននៅក្នុងកន្លែងនេះ។ ដូច្នេះជាភាសាអង់គ្លេស "បណ្ណាសារវៀតណាម មិនអាចមានអ្វីដែលយើងចង់ទៅរកនោះទេ។ ជាពិសេស ប្រសិនបើលោក លោកស្រីចង់មើលទៅលើកំណត់ហេតុនៃអង្គហេតុ"។ ច្បាស់ណាស់មជ្ឈមណ្ឌលវៀតណាមបញ្ជាក់ថា មិនមានការអនុវត្តវិធីសាស្ត្រជាលក្ខណៈបច្ចេកទេសក្នុងការប្រមូលឯកសារទាំងអស់នេះទេ។ ដូច្នេះ វាចោទឡើងនូវបញ្ហាភាពគួរឲ្យជឿជាក់នៃឯកសារ។ សហភាគាកាណាវាស បានលើកឡើងរួចមកហើយ អំពីកម្មវិធីរបស់-- អំពីកម្មវិធីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ប៉ុន្តែខ្ញុំនឹងមិននិយាយឡើងវិញទេ។ ខ្ញុំស៊ើប-- យើងមានផែនទីមួយចំនួនដែលយើងមិនដឹងអំពីប្រភពផងដែរ។ ឧទាហរណ៍ ដូចជាឯកសារD108/50/1.4 ដែលនេះគឺជាផែនទី នៃបណ្តាញផ្លូវថ្នល់ នៅជុំវិញទីក្រុងភ្នំពេញ គឺចុះឆ្នាំ២០០១ តើវាមានប្រយោជន៍អ្វីក្នុងការដាក់បញ្ចូលផែនទីបណ្តាញផ្លូវថ្នល់នៅក្នុងសំណុំរឿងនោះ? តើវាមានតម្លៃជាភស្តុតាងអីដែលត្រូវដាក់ផែនទីឆ្នាំ២០០១ នេះចូលទៅក្នុង

សំណុំរឿងនោះ?

នេះជាឧទាហរណ៍មួយចំនួនដែលខ្ញុំលើកជូនអង្គជំនុំជម្រះ ហើយខ្ញុំនឹងមិនពិនិត្យមើលទៅលើឯកសារដែលមានចំនួន៤៦១នោះទេ។ ខ្ញុំគ្រាន់តែលើកឡើងនូវឧទាហរណ៍មួយចំនួន ជាទូទៅ ដែលបង្ហាញអំពីអវត្តមាននៃភាពពាក់ព័ន្ធ ហើយនិងភាពមិនអាចទុកចិត្តបានទៅលើឯកសារទាំងអស់នេះ។

ឥឡូវនេះ ខ្ញុំសូមចូលទៅឧបសម្ព័ន្ធ A16 ដែលជាខ្សែអាត់សំឡេង និងវីដេអូ ខ្ញុំសូមសង្កត់ធ្ងន់ទៅលើភាពពាក់ព័ន្ធនៃឯកសារទាំងអស់នេះនៅក្នុងដំណាក់កាលនៃសំណុំរឿងនេះ។ ហើយដើម្បីបង្ហាញពីចំណុចនេះ ខ្ញុំសូមឱ្យអង្គជំនុំជម្រះពិនិត្យមើលវីដេអូមួយដែលមានលេខ D295/2/2.25R នេះជាវីដេអូមួយដែលបង្ហាញអំពីការហ្វឹកហាត់ទាហាន នៃកងទ័ពបដិវត្តន៍កម្ពុជា និងមានវីដេអូមួយទៀត ដែលបង្ហាញអំពីការងារដោយបង្ខំគឺវីដេអូលេខ D295/2/2.56R។

[០៩:៤៧:២៩]

ខ្សែវីដេអូទាំងពីរនេះ មិនពាក់ព័ន្ធទៅក្រុងក្របខ័ណ្ឌនៃសវនាការវគ្គដំបូងនេះទេ។ ដូច្នេះសូមអង្គជំនុំជម្រះច្រានចោលឯកសារនេះក្នុងចំណោមឯកសារទាំងអស់ផ្សេងទៀត ក្នុងចំណោមឯកសារដែលបានលើកឡើងដោយសហព្រះរាជអាជ្ញានៅក្នុងក្របខ័ណ្ឌនៃសវនាការនេះ គឺឯកសារច្រើនណាស់ដែលមិនមានភាពពាក់ព័ន្ធនោះទេ នៅក្នុងសវនាការវគ្គដំបូងនេះ។

ដូចគ្នាផងដែរ នៅក្នុងក្របខ័ណ្ឌនៃសវនាការថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០២ (ស៊ីក) ក្រុមមេធាវីខៀវ សំផន បានជំទាស់ទៅនឹងប្រតិចារឹកមួយចំនួននៃការសម្ភាសន៍។ ខ្ញុំសូមឱ្យអង្គជំនុំជម្រះពិនិត្យមើលប្រតិចារឹកសវនាការលេខ E1/45.1 ទំព័រ ៦៧ នៅពេលនោះយើងបានលើកឡើងពាក់ព័ន្ធទៅនឹងការសម្ភាសន៍មួយដែលធ្វើឡើងដោយលោក ស្ទីវ ហេឌ័រ គឺសម្ភាសលោក អ៊ិុក ប៊ុនឈឿន គឺថាយើងមិនអាចដាក់ឯកសារនេះចូលទៅក្នុងសំណុំរឿងដោយមិនបានសួរដេញដោល អ្នកដែលត្រូវបានគេសម្ភាសនោះទេ។ ហើយនៅថ្ងៃនេះទៀត សហព្រះរាជអាជ្ញាចង់ដាក់បញ្ចូលឯកសារសំឡេងនេះ គឺមានលេខយោងដូចតទៅនេះ D210/5R យើងខ្ញុំសូមជំទាស់ ទៅនឹងឯកសារខ្សែអាត់សំឡេងនេះ ដូចដែលយើងបានជំទាស់ទៅនឹងប្រតិចារឹកផងដែរ។

[០៩:៤៩:៣៧]

គឺដូចជាករណីនៃឯកសារតទៅនេះផងដែរ គឺឯកសារលេខ D269/9/1.9R ឯកសារ D269/9.10R ឯកសារ D269/9/1.11R ឯកសារ D269/9.1.12R ឯកសារទាំងអស់នេះ

គឺជាឯកសារសម្ភាសដែលធ្វើឡើងដោយលោក ប៉ែន យៀវនិន នៅក្នុងឆ្នាំ៩០។ យើងខ្ញុំ សូមជំទាស់ទៅនឹងប្រតិចារឹកដែលមានលេខយោងដូចតទៅនេះ D313/1.2.406.1 យើងខ្ញុំសូមជំទាស់ទៅនឹងឯកសារទាំងប្រតិចារឹក ទាំងខ្សែអាត់សំឡេង។ ឧទាហរណ៍ផ្សេងទៀត គឺឯកសារវីដេអូ យើងក៏សូមជំទាស់ផងដែរ ទៅនឹងការដាក់ការសម្ភាសលោក ខៀវ សំផន នៅក្នុងឆ្នាំ១៩៩៨ ដែលមានលេខយោងដូចតទៅនេះ D313.10R, D313.9R, D313.11R វីដេអូនេះគឺបានទទួល-- ខាងសហព្រះរាជអាជ្ញាទទួលពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយឯកសារទាំងអស់នេះ គឺត្រូវបានទទួលស្គាល់ដោយសហព្រះរាជអាជ្ញា ប៉ុន្តែគឺថាយើងមិនមានបានទទួលព័ត៌មានច្បាស់លាស់នោះទេ ថាតើបានទទួលពីអ្នកកាសែតណាមួយ? ហើយមានតែជាភាសាខ្មែរនោះទេ មិនមានប្រតិចារឹកជាលាយលក្ខណ៍អក្សរនោះទេ។

[០៩:៥១:៥៨]

ហើយការសម្ភាសដែលធ្វើឡើងនៅក្នុងលក្ខខណ្ឌបែបនេះ ដែលមិនមានធាតុពាក់ព័ន្ធចាំបាច់ ហើយមិនមានអត្តសញ្ញាណរបស់អ្នកកាសែតទៀតនោះ គឺមិនអាចទទួលយកបានថាជាឯកសារត្រឹមត្រូវដោយអង្គជំនុំជម្រះនោះទេ។ យើងសូមជំទាស់ទៅនឹងការដាក់ឯកសារនេះ។ ឧទាហរណ៍ផ្សេងទៀត យើងមានខ្សែអាត់សំឡេងដែលខាងសហភាគាបានលើករួចមកហើយ គឺឯកសារដែលមានចំណងជើងថា "ខេមរអ៊ីនធ័រ វីយូ"។ ខ្ញុំសូមយោងទៅលើឯកសារខ្សែអាត់សំឡេងដែលមានលេខ D269/9/1.13R ដែលថាទោះបីជាមានការពន្យល់ពីលោក ប៉ែន យៀវនិន ក៏ដោយគឺមានបញ្ហាជាច្រើនដើម្បីដឹងថាតើអ្នកណាជាអ្នកធ្វើការសម្ភាសទាំងអស់នេះ? ហើយការសម្ភាសនេះត្រូវបានធ្វើឡើងនៅក្នុងលក្ខខណ្ឌបែបណា? ហើយក៏យើងមិនបានដឹងច្បាស់អំពីអត្តសញ្ញាណនៃសាក្សីផងដែរ។ ដូច្នេះយើងមិនអាចទទួលយកឯកសារនេះបានទេ។

[០៩:៥៣:២៣]

យើងក៏សូមជំទាស់ទៅនឹងឯកសារមួយចំនួនទៀតដែលយើងចាត់ទុកថា ជាឯកសារដែលមានលក្ខណៈមិនអព្យាក្រឹត គឺឯកសារលេខ D299.1.41R យើងខ្ញុំបានជំទាស់រួចមកហើយកាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ នោះ។ គឺថាវាមានបញ្ហាចោទឡើងពាក់ព័ន្ធទៅនឹងភាពមិនលម្អៀង ហើយនិងភាពជឿជាក់បាននៃឯកសារនេះ ពីព្រោះឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមថតខ្សែភាពយន្តអាល្លឺម៉ង់។

[០៩:៥៤:១៥]

ដូច្នេះនេះជាការធម្មតាទេ ដែលខាង ខៀវ សំផន ត្រូវចោទបញ្ហាពាក់ព័ន្ធទៅនឹងភាពជឿជាក់បាននៃឯកសារទាំងអស់នេះ។ នេះគ្រាន់តែជាឯកសារ (សូមទោស) ជាភស្តុតាងដែលខ្ញុំ (សូមទោស) ជាឧទាហរណ៍ដែលយើងបានលើកឡើងពាក់ព័ន្ធទៅនឹងឧបសម្ព័ន្ធនេះ ហើយយើងមិនអាចធ្វើការអត្ថាធិប្បាយពេញលេញចំពោះឯកសារទាំងអស់នេះទេ។

ខ្ញុំសូមចូលទៅឧបសម្ព័ន្ធ A17 សូមអភ័យទោស ខ្ញុំសូមចូលទៅឧសម្ព័ន្ធ A17 ដែលមានចំណងជើងថា “ទំនាក់ទំនងអន្តរជាតិ”។ យើងបានលើកឡើងរួចមកហើយ កាលពីថ្ងៃទី១៦ កុម្ភៈ ឆ្នាំ២០១២ យើងបានលើកឡើងបញ្ហាមួយចំនួនក្នុងការកំណត់អត្តសញ្ញាណនៃប្រភពនៃឯកសារ ភាពគួរឲ្យជឿជាក់បាននៃការបកប្រែ។ ដោយសារតែក្នុងចំណោមឯកសារនោះមានការសង្ខេប ដែលធ្វើឡើងដោយជនជាប់ចោទ ហើយពាក់ព័ន្ធទៅនឹងពាក្យដែលជនជាប់ចោទបាននិយាយ។

[០៩:៥៥:៤០]

ហើយឯកសារទាំងអស់នេះត្រូវបានធ្វើឡើង ដើម្បីបង្ហាញអំពីភស្តុតាងពាក់ព័ន្ធទៅនឹងអង្គហេតុដែលប្រព្រឹត្តឡើងដោយជនជាប់ចោទ។ ដូច្នេះយើងត្រូវធ្វើយ៉ាងម៉េច ធានាថាឯកសារនេះមានភាពអាចជឿជាក់បាន។ ហើយជាក់ស្តែងណាស់ យើងមិនមានមធ្យោបាយជាក់លាក់ណាមួយក្នុងការពិនិត្យផ្ទៀងផ្ទាត់ទៅលើប្រភពនៃឯកសារទាំងអស់នេះទេ។ យើងមិនបាន យើងមិនអាចពិនិត្យបានថា តើបកប្រែត្រូវ ឬក៏អត់ទេ ព្រោះថាយើងអត់មានច្បាប់ដើមផងនុ៎ង។ ខ្ញុំសូមលើកឧទាហរណ៍ ឯកសារដូចតទៅនេះ D313/1.2.265 ឯកសារ D313/1.2.266, D313/1.2.268, D199/26.2.201។ យើងខ្ញុំសូមជំទាស់ជាថ្មីម្តងទៀតទៅលើឯកសារទាំងអស់នេះ ពីព្រោះថាយើងមិនមែនសង្ស័យទៅលើអត្ថិភាពនៃទូរលេខទាំងអស់នេះទេ គ្រាន់តែថាឯកសារទាំងអស់នោះ គឺថាមានភាពជឿជាក់តិចតួចបំផុត។

[០៩:៥៧:១៦]

សូមចូលទៅដល់ឧបសម្ព័ន្ធ A18 ជាសេចក្តីរាយការណ៍ពីសារព័ត៌មានអន្តរជាតិ។ ឯកសារទាំងអស់នេះនឹងត្រូវពិនិត្យនៅពេលក្រោយ។ ខ្ញុំសូមរំឭកថា កាលពីសវនាការថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២ យើងបានបង្ហាញការជំទាស់ជាច្រើនលើកច្រើនសាទៅលើឯកសារ *អេហ្វប៊ីស* ដូច្នេះខ្ញុំមិននិយាយដដែលៗទៀតទេ។ គឺមានការជំទាស់ជាទូទៅមួយចំនួន ដែលមានសារៈសំខាន់ណាស់ចំពោះយើង។ ជាពិសេសនៅពេលដែលយើងមានសម្រង់នៃអត្ថបទសារព័ត៌មាន គឺមិនមានការបញ្ជាក់អំពីឈ្មោះអ្នកនិពន្ធនោះទេ។ ឧទាហរណ៍យើងមានឯកសារ D56 ឯកសារ ០០១, ឯកសារ D56, 003, ឯកសារ

D366/7.1.236 (សូមទោស) D.238 ឯកសារ D366-Doc012, D300-- (សូមទោស) D56-Doc15, D366/7.1.242។ គឺមានឧទាហរណ៍ជាច្រើនទៀត ប៉ុន្តែខ្ញុំសូមនិយាយតែប៉ុណ្ណេះទេ។

[០៩:៥៩:១៥]

យើងសូមជំទាស់ទៅនឹងឯកសារ ដែលមិនមានច្បាប់ដើមទាំងស្រុង គឺឯកសារនេះគ្រាន់តែជាសេចក្តីសង្ខេបតែប៉ុណ្ណោះ មិនមានអត្ថបទទាំងស្រុងនោះទេ។ ឧទាហរណ៍ដូចជា ឯកសារ D56 Doc017, D56-Doc021, D56 Doc001...។ល។ យើងខ្ញុំសូមជំទាស់ទៅនឹងឯកសារដែលមិនមានជាភាសាខ្មែរ ឧទាហរណ៍ D313/1.2.276, D313/1.2.281 ខ្ញុំសូមបញ្ចប់ការលើកឧទាហរណ៍ ខ្ញុំសូមបន្តទៅទៀត។

[១០:០០:១៩]

យើងខ្ញុំសូមជំទាស់ទៅនឹងឯកសារ ដែលមិនមានច្បាប់ដើមជាភាសាខ្មែរ។ ដូច្នេះយើងខ្ញុំមិនអាចពិនិត្យផ្ទៀងផ្ទាត់ អនុលោមភាពនៃការបកប្រែបាននោះទេ ដោយសារតែមិនមានច្បាប់ដើម។ ឯកសារដែលមានលេខ D199/26.2.44។ ឧទាហរណ៍មួយទៀត ដើម្បីបង្ហាញអំពីបញ្ហាដែលចោទឡើង គឺថាយើងមិនអាច-- យកឯកសារនេះជាមូលដ្ឋានបានទេ។

ខ្ញុំចូលទៅឧបសម្ព័ន្ធ A19 ខ្ញុំមិនដឹងថា តើខ្ញុំអាចបន្តទៅទៀត ឬមួយក៏យើងឈប់សម្រាកសិនលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

អញ្ជើញតទៀត នៅកន្លះម៉ោងទៀត។

[១០:០១:៤២]

**លោកស្រី អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ឥឡូវនេះ ខ្ញុំចូលទៅឧបសម្ព័ន្ធ១៩ ដែលទាក់ទងនឹងអត្ថបទស្រាវជ្រាវ និងរបាយការណ៍។ ខ្ញុំសូមយោងទៅនឹងការជំទាស់ដែលបានធ្វើដោយក្រុម អៀង សារី ក៏ប៉ុន្តែខ្ញុំគ្រាន់តែសូមរំឭកចំណុចដ៏សំខាន់មួយទាក់ទងទៅនឹងឯកសារ D2-15 ដែលជារបាយការណ៍វិភាគរបស់លោក គ្រេក អេតឆេសាន់ យើងសូមជំទាស់ទៅនឹងឯកសារនេះ ដោយលោកបានមានមូលហេតុរបស់លោក កាណាវាស រួចមកហើយ។ ក៏ប៉ុន្តែយើងសូមរំឭកទៅដល់អង្គជំនុំជម្រះនូវចំណុចដ៏សំខាន់មួយដែលបានលើកឡើងដោយក្រុមការពារក្តីរបស់លោក អៀង ធីរិទ្ធ នៅក្នុងដំណាក់កាល

ស៊ើបអង្កេត។ ខ្ញុំសូមយោងទៅឯក-- សំណើ D192 ដែលនៅក្នុងឯកសារនេះមានព័ត៌មានលម្អិត និង ច្បាស់លាស់បំផុត ដោយក្រុមការពារលោក អៀង ធីរិទ្ធ បានកត់សម្គាល់នូវភាពមិនសមស្របនៃការ វិធីសាស្ត្រនៃការធ្វើរបាយការណ៍នេះ ហើយនិងសេចក្ដីសន្និដ្ឋានដែលឈរទៅលើ ជួនកាលនោះទៅលើ សក្ខីកម្មដែលទទួលបានក្នុងការធ្វើទារុណកម្ម ហើយនិងសេចក្ដីសន្និដ្ឋានជាទូទៅ ដែលឈរលើតែ សក្ខីកម្មតែមួយគត់។

[១០:០៣:១៨]

ឥឡូវ ខ្ញុំសូមនិយាយអំពីមូលដ្ឋានចម្បង ដែលភាគីការពារក្ដីរបស់ អៀង សារី បានលើកឡើង គ្រាន់តែសូមរំឭកទាញចំណាប់អារម្មណ៍របស់អង្គជំនុំជម្រះទៅលើការដែលថា របាយការណ៍នេះមាន បញ្ហា ហើយមិនអាចទទួលបានក្នុងលក្ខខណ្ឌយ៉ាងដូច្នេះនោះទេ។ ហើយបើសិនជាព្រះរាជអាជ្ញាចង់ ពិនិត្យឯកសារនេះ សូមឲ្យលោក ក្រេក អេតឆេសាន់ មកផ្ដល់សក្ខីកម្ម និងសួរដេញដោលទាក់ទងទៅ នឹងព័ត៌មានដែលមានភាពចម្រូងចម្រាសនៅក្នុងរបាយការណ៍នេះ។

[១០:០៤:០០]

ខ្ញុំសូមឈានចូលទៅដល់ឧបសម្ព័ន្ធ A20 លើរបាយការណ៍ស្ដីពីការចាត់តាំងឲ្យស៊ើបសួរជំនួស។ នៅក្នុងចំណុចនេះ ខ្ញុំសូមរំឭកថា រំឭកអំពីការជំទាស់របស់សហភាតានៃភាគីការពារក្ដីផ្សេងទៀត ក៏គ្រាន់តែសូមលើកពីយុត្តិសាស្ត្រអន្តរជាតិ យើងមិនអាចទទួលយកបាននូវសេចក្ដីប្រកាសជាលាយ លក្ខណ៍អក្សរទាក់ទងទៅនឹងអំពើរបស់ជនជាប់ចោទ ឬក៏សេចក្ដីសង្ខេប ការស្ដាប់សក្ខីកម្ម ឬក៏របស់ សាក្សី ឬក៏របស់ភាគ-- ដើមបណ្ដឹងរដ្ឋប្បវេណី ដោយមិនអាចសួរដេញដោលជនទាំងអស់នេះបានទេ។ ដូច្នេះយើងសូមជំទាស់នូវរបាយការណ៍ដីកាចាត់តាំងឲ្យស៊ើបសួរជំនួសនេះទាំងស្រុង ដែល-- ដោយ មូលហេតុថា ដោយពុំមានការសួរដេញដោល សួរតទល់គ្នា។ នេះគឺជា-- ទាំងអស់នេះគឺជាការកត់ សម្គាល់របស់យើងខ្ញុំពាក់ព័ន្ធទៅនឹងកថាខណ្ឌA6 ដល់ A20។ ទាក់ទងទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំនឹងនិយាយដោយសង្ខេបចំពោះឯកសារទាំង១០ នេះ គឺថាមានប្រាំបួនទៅហើយ ដែលមិនពាក់ព័ន្ធទៅ នឹងវគ្គទីមួយយើងនេះ។ អ៊ីចឹងយើងត្រូវតែជំទាស់ឯកសារទាំងប្រាំបួននេះចោល មានតែឯកសារតែមួយ គត់ដែលពាក់ព័ន្ធនឹងវគ្គទីមួយនេះ ហើយនេះគឺជាអត្ថបទរបស់លោក ប៉ែន យៀវនិន ដែលគាត់សរសេរ ដែលកាលណោះគាត់ទើបតែអាយុ២១ឆ្នាំទេ ខ្ញុំមិនសង្កត់ធ្ងន់ទៅលើភាពគួរឲ្យទុកចិត្តបាន ឬក៏តម្លៃជា ភស្តុតាងនោះទេ ក៏ប៉ុន្តែអត្ថបទអ្នកស្រាវជ្រាវដែល-- និស្សិតស្រាវជ្រាវនោះមិន-- អ៊ីចឹងគួរតែពិចារណា

លើអត្ថបទនេះ។ អ៊ីចឹងយើងសូមជំទាស់ទៅនឹងឯកសារទាំងភាគច្រើននេះដែលបង្ហាញដោយខាងភាគីដើមបណ្តឹងរដ្ឋប្បវេណី។

[១០:០៦:៣៧]

ខ្ញុំសូមបញ្ចប់ការជំទាស់របស់ខ្ញុំដោយរំឭកថា យើងខ្ញុំមិនមែនជំទាស់ដើម្បីតែជំទាស់នោះទេ។ គឺថាគឺជាតួនាទីរបស់ភាគីទាំងអស់គ្នា ទោះបីជាខាងសហព្រះរាជអាជ្ញា ឬក៏ដើមបណ្តឹងរដ្ឋប្បវេណី ឬក៏ខាងការពារក្តីក៏ដោយ គឺថាយើងធ្វើយ៉ាងណាកុំឱ្យឯកសារច្រើនពេក ដែលពិបាកដល់ការធ្វើការវិនិច្ឆ័យ ហើយនិងត្រូវតែរកព័ត៌មានដែលពាក់ព័ន្ធ។ ដូច្នេះសូមឱ្យអង្គជំនុំជម្រះពិនិត្យទៅលើការជំទាស់របស់យើងខ្ញុំទាំងអស់ ទៅលើឯកសារទាំងអស់នេះ។ សូមអរគុណ លោកប្រធាន។

[១០:០៧:២០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ លោកស្រីមេធាវី។

ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយដែរ អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់សាមសិបនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយនៅសវនាការបន្តទៅទៀតនោះគឺជា វេទិកាលើកឡើងនូវសេចក្តីជំទាស់របស់សហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងឯកសារដែលស្នើសុំឡើង ដាក់ឡើងដោយក្រុមមេធាវីការពារក្តី។

សូមអញ្ជើញលោកមេធាវី!

[១០:០៨:០១]

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន ហើយសូមគោរពលោកប្រធាន និងអង្គជំនុំជម្រះ លោក លោកស្រីចៅក្រម ដោយសារមូលហេតុសុខភាពលោក អៀង សារី ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមដោយផ្ទាល់ក្នុងបន្ទប់សវនាការសម្រាប់មួយថ្ងៃនេះពេញតែម្តង ក៏ប៉ុន្តែសូមចូលរួមសវនាការនៅបន្ទប់រង់ចាំខាងក្រោម។ អាស្រ័យហេតុនេះសូមលោកប្រធានមេត្តាអនុញ្ញាតតាមសំណើសុំ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

[១០:០៨:៣៧]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមអធ្យាស្រ័យចំពោះការជំទាស់នេះ ខ្ញុំមានបញ្ហាដាច់ដោយឡែកមួយដែលត្រូវលើកមកពិភាក្សា។ ការកំណត់ពេលវេលានេះគឺ ត្រូវពាក់ព័ន្ធទៅនឹងការជំទាស់ដោយសហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ យើង-- ដូច្នេះយើងខ្ញុំមិនមានការជំទាស់ទៅនឹងឯកសារ ដែលស្នើសុំដាក់ដោយមេធាវីការពារក្តីនោះទេ។ ដូច្នេះជាការឆ្លើយតបរបស់យើងខ្ញុំទៅវិញទេ ដូច្នេះ ដោយសារតែសារណាសង្ខេប ដែលលើកឡើងដោយមេធាវីការពារក្តី យើងខ្ញុំអាចបញ្ចប់នៅថ្ងៃស្អែក ឬក៏នៅព្រឹកថ្ងៃព្រហស្បតិ៍។ សូមជូនព័ត៌មាន ដើម្បីឲ្យអង្គជំនុំជម្រះមេត្តាពិចារណាទៅលើចំណុចនេះ។ សូមអរគុណ។

[១០:០៩:៣៥]

**ប្រធានអង្គជំនុំ៖**

អរគុណលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

សូមអញ្ជើញលោកសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

សូមគោរព លោកចៅក្រមប្រធាន លោក លោកស្រីចៅក្រម អង្គសវនាការទាំងមូល! ខាងដើមបណ្តឹងរដ្ឋប្បវេណីក៏សូមអនុញ្ញាតជម្រាបជូនអង្គសវនាការទាំងមូលថា ខាងដើមបណ្តឹងរដ្ឋប្បវេណី ពុំមានបំណងនឹងលើកឡើងការជំទាស់ទៅនឹងការប្រើប្រាស់ឯកសាររបស់ខាង-- ដែលស្នើឡើងដោយខាងមេធាវីការពារក្តីនោះទេ។ សូមអរគុណ។

[១០:១០:០៦]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ ដល់មេធាវីដែលបានបង្ហាញជំហរច្បាស់លាស់ ដែលជាលទ្ធភាពមួយអាចសម្រួលដល់ការរៀបចំនៅក្នុងកិច្ចពិភាក្សានៅក្នុងដំណើរការសវនាការរបស់អង្គជំនុំជម្រះ។ អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ស្នើសុំមិនចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ ពីបន្ទប់មួយខាងក្រោមបន្ទប់សវនាការ ដោយមូលហេតុ

មានបញ្ហាសុខភាពមិនអាចអង្គុយតាមដាននៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់បាន។

អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់មេធាវីការពារ-- របស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំតាមរយៈមេធាវីរបស់គាត់ សូមលះបង់សិទ្ធិមិនចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនៅក្នុងបន្ទប់សវនាការនេះ ដោយទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយនៅបន្ទប់ខាងក្រោយដែលប្រព្រឹត្តទៅតាមរយៈប្រព័ន្ធឧបករណ៍សោតទស្សន៍។ តែអង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្ដីអៀង សារី ប្រគល់មកឲ្យអង្គជំនុំជម្រះនូវលិខិតលះបង់សិទ្ធិក្នុងការចូលរួមដោយផ្ទាល់ក្នុងសវនាការថ្ងៃនេះ ដោយមានចុះហត្ថលេខា ឬផ្ដិតម្រាមដៃយ៉ាងជាក់ច្បាស់ពីជនជាប់ចោទផង។

[១០:១១:៣៨]

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ អៀង សារី ទៅកាន់បន្ទប់ខាងក្រោមដែលរៀបចំទុកស្រេច នូវឧបករណ៍សោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ ហើយនិងបង្គាប់ឲ្យផ្នែកសោតទស្សន៍ តភ្ជាប់សោតទស្សន៍សម្រាប់ជនជាប់ចោទ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងអំឡុងពេលនៃដំណើរការសវនាការចាប់ពីពេលនេះតទៅរហូតដល់ល្ងាចរសៀលនេះផងដែរ។

សូមសម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១២ នាទី ដល់ម៉ោង ១០:៣៥ នាទី)*

[១០:៣៤:១៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តាមកាលវិភាគដែលបានកំណត់នៅក្នុងកិច្ចដំណើរការសវនាការនាពេលនេះ គឺសេចក្ដីតបរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ ចំពោះឯកសារដែលបានដាក់ដោយក្រុមមេធាវីការពារក្ដី ប៉ុន្តែមុននឹងសម្រាកអម្បាញ់មិញនេះ គឺខាងសហព្រះរាជអាជ្ញា ហើយនិងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានបង្ហាញជំហរច្បាស់លាស់ ថាខ្លួនមិនធ្វើសេចក្ដីជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់

ដោយក្រុមមេធាវីការពារក្តីទេ។ ដូច្នេះ បញ្ហាបន្តទៅទៀតនេះ គឺដល់សេចក្តីតបរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងសេចក្តីជំទាស់របស់ក្រុមមេធាវីការពារក្តី ចំពោះឯកសារដែលខ្លួនបានដាក់ ស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ ហើយសវនាការបានធ្វើនៅក្នុងសប្តាហ៍នេះ គឺពីម្សិលមិញរហូតដល់ព្រឹកមិញនេះ។

[១០:៣៥:៥១]

ឥឡូវនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីធ្វើសេចក្តីឆ្លើយតបទៅនឹងការជំទាស់ទៅនឹងការដាក់ឯកសាររបស់-- ដោយក្រុមមេធាវីការពារក្តី។ ហើយមុននឹងប្រគល់ វេទិកា សូមសួរទៅតំណាងសហព្រះរាជអាជ្ញា ថាតើក្នុងការជំទាស់ហ្នឹងត្រូវការពេលវេលាប៉ុន្មានដែរ?

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណលោកប្រធាន។ អ្វីដែលយើងស្នើសុំលើកឡើងចំពោះការជំទាស់ ជាបឋមសហសេវិករបស់ខ្ញុំនឹងធ្វើការឆ្លើយតបទៅនឹងបញ្ហាមួយចំនួនស្របពេលជាមួយនោះ យើងខ្ញុំនឹងដាក់សារណា និងការឆ្លើយតបទៅនឹងឧបសម្ព័ន្ធនីមួយៗ។ យើងខ្ញុំនឹងធ្វើជាបីដំណាក់កាល បីវគ្គ ប្រហែលជាយើងបញ្ចប់វគ្គដំបូងនៅថ្ងៃនេះ ហើយវគ្គទីពីរ យើងខ្ញុំអាចចាប់ផ្តើម បន្ទាប់មកពីវគ្គទីមួយ។ ហើយចំពោះវគ្គទីពីរ និងវគ្គទីបីហ្នឹង យើងខ្ញុំប្រហែលជាអាចឆ្លើយតបនៅថ្ងៃស្អែក។ ដូច្នេះ ទំនងយើងផ្តល់វេទិកាទៅដល់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រហែលជានៅថ្ងៃស្អែកពេលជិតចប់ម៉ោង ឬក៏នៅថ្ងៃព្រហស្បតិ៍។ ហេតុដូច្នេះហើយ អានេះហើយជាអ្វីដែលយើងខ្ញុំស្នើសុំធ្វើការឆ្លើយតប។ បញ្ហាហ្នឹងហើយទើបយើងខ្ញុំលើកឡើងចំណុចហ្នឹងមុនពេលដែលយើងឈប់សម្រាក។

[១០:៣៧:៥០]

ដូច្នេះ យើងខ្ញុំនឹងបញ្ចប់-- យើងខ្ញុំទាំងអស់គ្នា ប្រហែលជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីនឹងបញ្ចប់សេចក្តីឆ្លើយតបរបស់យើងនៅក្នុងអាទិត្យនេះតែម្តង។ ដូច្នេះហើយ ប្រហែលជាខាងដើមបណ្តឹងរដ្ឋប្បវេណីអាចចាប់ផ្តើមការឆ្លើយតបរបស់ខ្លួននៅថ្ងៃព្រហស្បតិ៍បាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ! សូមផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា សូមអញ្ជើញ!

**លោក វេង ហ៊ត់៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងជម្រាបសួរលោក លោកស្រីទាំងអស់គ្នា

នៃអង្គសវនាការទាំងមូល! យើងខ្ញុំបានស្ដាប់ឮក្នុងរយៈពេលពីរថ្ងៃមកនេះ-- មួយថ្ងៃកន្លះ នៅក្នុងទស្សនៈរបស់យើងខ្ញុំ ការជំទាស់ភាគច្រើនបំផុតរបស់មេធាវីការពារក្ដីទៅនឹងការទទួលយកសម្ភារៈភស្តុតាងដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា បើយើងខ្ញុំពិនិត្យទៅលើការអនុវត្តគោលច្បាប់ អាចឲ្យគេមិនចាំបាច់ពិចារណាទៅលើការជំទាស់ចំពោះអង្គហេតុដែលពាក់ព័ន្ធនឹងប្រភពចម្បងនៃភស្តុតាងទាំងនោះឡើយ។ ការជំទាស់ជាក់លាក់របស់មេធាវីការពារក្ដី ដែលយើងខ្ញុំសូមធ្វើសេចក្ដីសន្និដ្ឋានតបដោយសង្ខេបខ្លីៗ អំពីគោលការណ៍ច្បាប់ជាធរមាន។ យើងខ្ញុំក៏ត្រូវរៀបរាប់ជាទូទៅផងដែរ អំពីភស្តុតាងដែលមាននៅចំពោះមុខអង្គជំនុំជម្រះ ទាក់ទងនឹងប្រភពចម្បងនៃសម្ភារៈផ្សេងៗដែលបានចុះក្នុងបញ្ជីឯកសារដំណាក់កាលទីមួយរបស់ព្រះរាជអាជ្ញា។ យើងខ្ញុំគិតថា ការសង្ខេបខ្លីៗនេះ អាចជាជំនួយដល់អង្គជំនុំជម្រះ ដោយហេតុថា វាជាឈុតឯកសារសវនាការចុងក្រោយសម្រាប់ឯកសារដំណាក់កាលទីមួយ ហើយចំណែកភស្តុតាងនិងការលើកអំណះអំណាងមួយចំនួនធំ ក៏អាចធ្វើរួចហើយដែរ នៅចំពោះមុខអង្គសវនាការអំឡុងពេលកន្លងមក។

[១០:៤០:៣៧]

យើងខ្ញុំសូមលើកឡើងអំពីគោលការច្បាប់។ ចំណុចចាប់ផ្ដើមពិតនោះ គឺសេចក្ដីសម្រេចរបស់លោក លោកស្រីចៅក្រមតែម្ដង ស្ដីពីការអនុវត្តវិធាន៨៧ ទាក់ទងនឹងយថាភាព ភាពពាក់ព័ន្ធ និងភាពជឿទុកចិត្តបានចំពោះឯកសារ។ លោក លោកស្រីចៅក្រមបញ្ជាក់រួចហើយថា វិធាន៨៧ មានតេស្តសាកល្បងផ្លូវច្បាប់សម្រាប់ការទទួលយកភស្តុតាងចំពោះមុខ អ.វ.ត.ក។ វិធាន៨៧(១) បានបង្កើតសច្ចធារណ៍ជាទូទៅមួយ អំពីភាពដែលអាចទទួលយកបាននៃភស្តុតាងទាំងអស់។ វិធានទូទៅនេះត្រូវបានកម្រិតដោយវិធាន៨៧(៣) ដែលចែងអំពីបញ្ជីកាលៈទេសៈទាំងអស់ ដែលអង្គជំនុំជម្រះអាចនឹងបដិសេធចោលលើសំណើដាក់ភស្តុតាងណាមួយ។

សំណុំរឿង០០១ ដើម្បីអនុវត្តបទប្បញ្ញត្តិនេះនៅក្នុងសេចក្ដីសម្រេចលេខ E43/4 និង E176 អង្គជំនុំជម្រះបានអនុម័តយកវិធីសាស្ត្រ ឬគេហៅថាអភិក្រមមួយ ដែលស៊ីសង្វាក់គ្នាទៅនឹងករណីយុត្តិសាស្ត្រអន្តរជាតិនានា។ អង្គជំនុំជម្រះបានបកស្រាយវិធាន៨៧(៣) ថា ជាវិធានមួយដែលតម្រូវឲ្យភស្តុតាងនោះត្រូវតែបំពេញទៅតាមបទដ្ឋានអប្បបរិមា ស្ដីពីភាពពាក់ព័ន្ធ និងភាពអាចជឿទុកចិត្តបាន។

[១០:៤២:២៧]

នៅក្នុងសំណុំរឿង០០២ អង្គជំនុំជម្រះបានផ្ដល់ការណែនាំបន្ថែមទៀត តាមរយៈអនុស្សរណៈ

របស់គាត់ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២ ឯកសារលេខ E162 ដោយបញ្ជាក់ថា ភស្តុតាងដែលបានស្នើឲ្យទទួលយក ត្រូវតែបំពេញបទដ្ឋានមួយក្រឡេកភ្នែក យោងតាមលក្ខណៈវិនិច្ឆ័យ ដូចជាភាពមិនពាក់ព័ន្ធ ឬភាពមិនគួរឲ្យទុកចិត្តបាន និងយថាភាព។

ហេតុដូច្នេះ អង្គជំនុំជម្រះបានបញ្ជាក់ថា បើសិនជាឯកសារមួយខ្វះនូវភាពជឿទុកចិត្តយ៉ាងច្បាស់ រួមទាំងយថាភាព ឯកសារនោះអាចនឹងត្រូវគេពិចារណាថា មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុ ដូចឯកសារនោះទេ។

[១០:៤៣:២៧]

ការនេះក៏ផ្ទុះបញ្ចាំងឲ្យឃើញផងដែរថា អំពីគោលការណ៍ច្បាប់ស្មុល ដែលសហព្រះរាជអាជ្ញាបានពឹងផ្អែកនៅក្នុងសេចក្តីសន្និដ្ឋានផ្ទាល់មាត់ និងលាយលក្ខណ៍អក្សរដែលបានធ្វើកន្លងមក។ បទដ្ឋានពាក់ព័ន្ធ និងភាពជឿទុកចិត្តបាន ភាពពាក់ព័ន្ធនឹងយថាភាពនៅដំណាក់កាលនេះ គឺអាចឲ្យគេសន្មតបានត្រឹមមួយក្រឡេកភ្នែក។ ការដែលគេអាចសន្មតបានត្រឹមមួយក្រឡេកភ្នែក មានន័យថា តាមទិដ្ឋភាពខាងក្រៅរបស់ឯកសារ វាមានន័យថា ត្រង់ចំណុចនៃការទទួលយកភស្តុតាងមិនត្រូវបានគេដាក់លក្ខខណ្ឌទាល់តែបំពេញបានថា ជាឯកសារដើមពិតប្រាកដ មានប្រភពដើមពិតប្រាកដ មានខ្សែសង្វាក់នៃការគ្រប់គ្រងឯកសារ ឬទម្រង់ឯកសារពិតប្រាកដនោះឡើយ។ ដូចជា តើវាមានច្បាប់ដើម ឬច្បាប់ចម្លងនោះទេ? អ្វីដែលលក្ខខណ្ឌទាំងអស់នេះ គឺលោក លោកស្រីចៅក្រម យោងតាមលក្ខណៈវិនិច្ឆ័យរបស់ខ្លួនដែលថា តាមទិដ្ឋភាពខាងក្រៅរបស់ឯកសារ ភស្តុតាងនោះហាក់ដូចជាពាក់ព័ន្ធ អាចជឿទុកចិត្តបាន និងមានយថាភាព។

ភាពពាក់ព័ន្ធទៅនឹងថាតើឯកសារនោះជាប់ទាក់ទងបញ្ហាណាមួយក្នុងសវនាការដែរឬអត់ និងថាតើវាមានទំនោរគាំទ្រចំពោះជំហររបស់ភាគីដែលស្នើសុំនោះដែរឬអត់? ចំពោះយថាភាព និងភាពជឿទុកចិត្តបាន យើងខ្ញុំសូមធ្វើការសន្និដ្ឋានថា ការដែលអាចឲ្យគេសន្មតបានមួយក្រឡេកភ្នែក មានន័យថា លោក លោកស្រីចៅក្រម តាមលក្ខណៈវិនិច្ឆ័យរបស់លោកថា ភស្តុតាងនោះហាក់ដូចជាទៅតាមអ្វីដូចដែលបានអះអាងមែន។ គេអាចនិយាយម្យ៉ាងទៀតថា ឯកសារនោះហាក់បីដូចជាមិនក្លែងក្លាយទេ និងថាមានកម្រិតតម្លៃភរនីយភាពអប្បបរមា។ បើតាមគ្រប់លក្ខខណ្ឌតម្រូវទាំងអស់នេះ គឺសញ្ញាបង្ហាញគ្រប់គ្រាន់ហើយស្តីពីភាពជឿទុកចិត្តបាន។

[១០:៤៥:៥០]

លោក លោកស្រីចៅក្រម ក៏បានផ្តល់នូវការបង្ហាញដ៏មានសារប្រយោជន៍មួយ អំពីបទដ្ឋាននេះ តាមរយៈអនុស្សរណៈលេខ E162។ លោក លោកស្រីចៅក្រមបានថ្លែងដូច្នេះថា បើសិនជាឯកសារមួយហាក់ដូចជា មិនក្លែងបន្លំទេនោះ ឬមិនតំណាងឲ្យភាពដើមអង្គជំនុំជម្រះត្រូវពិចារណាថា ឯកសារនោះបានដាក់នៅចំពោះមុខខ្លួន។ មានន័យថា ឯកសារនោះគឺមានយថាភាព និងភាពជឿទុកចិត្តបានដោយគ្រាន់តែឃើញមួយក្រឡេកភ្នែក ដោយសារតាមទិដ្ឋភាពខាងក្រៅរបស់វាមិនមែនជាឯកសារក្លែងបន្លំ។ នៅពេលឯកសារមួយត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ហើយបានទទួលយកជាភស្តុតាងដូចលោក លោកស្រីចៅក្រមបានបញ្ជាក់រួចហើយនៅក្នុងអនុស្សរណៈនោះ នោះការសន្និដ្ឋានបន្ថែមអំពីភាពពាក់ព័ន្ធនឹងត្រូវគិតគូរចំពោះទម្ងន់ដែលឆ្លើយតបទៅនឹងភស្តុតាងនោះ។

[១០:៤៧:០០]

ស្រដៀងគ្នានេះដែរ លោក លោកស្រីចៅក្រមបានធ្វើការសម្រេចនៅក្នុងសាលក្រមសំណុំរឿង ០០១ ត្រង់កថាខណ្ឌ៤២ ថា "ការវាយតម្លៃចំពោះតម្លៃភស្តុតាងនឹងចាប់ផ្តើមធ្វើនៅពេលណាភស្តុតាងនោះត្រូវបានទទួលយក"។ មូលហេតុដែលយើងខ្ញុំកំពុងគូសបញ្ជាក់អំពីចំណុចខុសគ្នានេះគឺដោយសារមានការសន្និដ្ឋានជាច្រើន ដែលយើងខ្ញុំស្តាប់ឮពីខាងមេធាវីការពារក្តីមិនបានលើកអំពីភាពអាចទទួលយកបាននៃភស្តុតាងទេ ប៉ុន្តែផ្ទុយពីនេះ គាត់បានលើកអំពីទម្ងន់ភស្តុតាងទៅវិញ។ ជាឧទាហរណ៍ សំណួរដែលសួរថា តើខ្លឹមសារនៃឯកសារមួយដែលរៀបរាប់អំពីព្រឹត្តិការណ៍ណាមួយយ៉ាងត្រឹមត្រូវ ឬមួយថាតើអ្នកនិពន្ធមានចំណេះដឹងដោយផ្ទាល់អំពីព្រឹត្តិការណ៍ដែលខ្លួនបានរៀបរាប់ដែរឬអត់នោះ? គឺជាសំណួរដែលសួរក្នុងន័យដាក់ទម្ងន់ ដែលជាចុងក្រោយយើងនឹងលើកពីហេតុផលចំពោះឯកសារនោះ។

[១០:៤៨:១៥]

ប៉ុន្តែសំណួរទាំងអស់នេះ មិនបានច្រានចោលជាមុននូវការទទួលយកឯកសារទេ វៀរលែងតែឯកសារនេះ មិនមានតម្លៃភស្តុតាងអ្វីបន្តិចសោះ។ ដូចបានបញ្ជាក់ពីខាងដើម ទិដ្ឋភាពមួយផ្សេងទៀតនៃគោលជំហរផ្លូវច្បាប់ស្តីពីភាពអាចទទួលយកបាននៃភស្តុតាងនៅថ្នាក់អន្តរជាតិចំពោះ អ.វ.ត.ក គឺថាគេគ្មានលក្ខខណ្ឌតម្រូវឲ្យផ្តល់ឯកសារដើមទេ។ អង្គជំនុំជម្រះបានសម្រេចថា ឯកសារដើម គឺជាវិធីសាស្ត្រនៃការបង្ហាញភស្តុតាងដែលគេចង់បាន ប៉ុន្តែពុំមែនទម្រង់តែមួយគត់ដែលភស្តុតាងនេះអាចនឹងត្រូវបានគេទទួលយកឡើយ។ គេបានទទួលស្គាល់យ៉ាងត្រឹមត្រូវក្នុងការទទួលយកច្បាប់ *ហ្វត្តូកូពី* បើសិន

ជាឯកសារហ្វូតូកូពីនោះអាចឲ្យគេជឿទុកចិត្តបាន និងមានយថាភាពត្រឹមត្រូវដោយគ្រាន់តែឃើញមួយក្រឡេកភ្នែក។

[១០:៤៩:១៨]

អង្គជំនុំជម្រះបានបញ្ជាក់ថា ច្បាប់ដើមនឹងមានទម្ងន់ច្រើនជាងច្បាប់ហ្វូតូកូពី។ សេចក្តីសន្និដ្ឋាននានារបស់យើងខ្ញុំ ប្រព្រឹត្តិកម្មគួរជាទីពេញចិត្តនេះគួរតែត្រូវបានពង្រីករហូតទៅដល់ច្បាប់ហ្វូតូកូពីផងដែរ។ បើសិនជាច្បាប់ដើមស្ថិតនៅកន្លែងណាមួយ ដែលគេបានស្គាល់ហើយគ្មានភាគីណាមួយបានដាក់ទឡ្ហីករណ៍សមហេតុផលដើម្បីបង្ហាញថា ច្បាប់ហ្វូតូកូពីទាំងនោះមិនមែនជាច្បាប់ចម្លងពីច្បាប់ដើមពិតប្រាកដ។ យើងខ្ញុំធ្វើការពន្យល់យ៉ាងលម្អិតអំពីសេចក្តីសន្និដ្ឋាននេះ នៅក្នុងការដាក់ឯកសារ E168/1 ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២។ អង្គជំនុំជម្រះក៏បានបញ្ជាក់ច្បាស់ហើយនៅក្នុងសេចក្តីសម្រេចថ្មីៗនេះរបស់ខ្លួនថា គោលបំណងនៃការទទួលយកឯកសារ គឺមិនចាំបាច់ទាល់តែកោះហៅសាក្សី ដែលមានចំណេះដឹងផ្ទាល់ឲ្យមកធ្វើការបញ្ជាក់ទៅនឹងសម្ភារៈយថាភាព ដែលមាននៅក្នុងសំណុំរឿងទេ។

[១០:៥០:៣២]

ដូចនេះដែរ គេក៏ពុំចាំបាច់កំណត់អំពីខ្សែសង្វាក់នៃការគ្រប់គ្រងឯកសារណាមួយដែរ។ ផ្ទុយទៅវិញ លោក លោកស្រីចៅក្រមបានសម្រេចថា ភស្តុតាងអំពីប្រភពដើម និងខ្សែនៃការគ្រប់គ្រងឯកសារនឹងជួយដល់អង្គជំនុំជម្រះវាយតម្លៃអំពីទម្ងន់ដែលឲ្យទៅលើភស្តុតាង។ យើងបានធ្វើសេចក្តីសន្និដ្ឋានមួយរួចហើយអំពីប្រភពដើម និងខ្សែសង្វាក់នៃការគ្រប់គ្រងឯកសារ។ តាមរយៈការដាក់ឯកសារកន្លងមកនៅក្នុងឯកសារលេខ E158 ចុះថ្ងៃ២៣ ខែធ្នូ ឆ្នាំ២០១១ និងនៅក្នុងឯកសារសវនាការមុនៗផ្សេងទៀត។

ជាការបន្ថែម ដូចដែលយើងខ្ញុំបានលើកយកមកពិភាក្សានៅក្នុងពេលបន្តិចទៀតនេះ លោក លោកស្រីចៅក្រម ធ្លាប់បានស្តាប់សក្ខីកម្មរបស់លោក ឆាំង យុ និងលោក វ៉ាន់ថាន់ ដារ៉ាពៅ រួចហើយអំពីប្រភពដើមនៃការឯកសារដែលប្រមូលបានដោយ ឌី.ស៊ី.ខេម។ ហើយនៅក្នុងវគ្គជាបន្តបន្ទាប់ខាងមុខ លោក លោកស្រីចៅក្រមនឹងស្តាប់ឮសាក្សី ដែលនិយាយអំពីការប្រាស្រ័យទាក់ទងគ្នា និងរចនាសម្ព័ន្ធរដ្ឋបាលជាច្រើននាក់ទៀតដែលបានផ្តល់ភស្តុតាងទាក់ទងនឹងឯកសារសហការនានា ដែលបានធ្វើសុំដាក់ចំពោះមុខអង្គជំនុំជម្រះ។

យើងខ្ញុំចង់និយាយថា ព័ត៌មានទាំងអស់នេះ គឺវាលើសពីគ្រប់គ្រាន់ទៅទៀត ដើម្បីកំណត់អំពីភាពពាក់ព័ន្ធ ភាពជឿទុកចិត្តបាន និងយថាភាពនៃឯកសារទាំងអស់ ដោយគ្រាន់តែឃើញមួយក្រឡេក

ភ្នែក ដែលយើងខ្ញុំបានស្នើឡើងសម្រាប់សវនាការក្នុងដំណាក់ដំបូងនេះ។

[១០:៥២:២៨]

យើងខ្ញុំសូមយោងរកអភិក្រមរបស់លោក លោកស្រីចៅក្រមនៅក្នុងការបែងចែកឲ្យដាច់ពីគ្នារវាងបញ្ហានៃភាពអាចទទួលយកបាន និងទម្ងន់នៃភស្តុតាង។ នេះគឺជាអ្វីដែលស៊ីសង្វាក់ទាំងស្រុងទៅនឹងអភិក្រមដែលតុលាការអន្តរជាតិបានទទួលបានយក។ នៅក្នុងសេចក្តីសម្រេចខុសៗគ្នាជាច្រើនរបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ អាយ.ស៊ី.ធី.វ៉ាយ ទម្លាប់នៃការអនុវត្តត្រូវបានគេបែងចែកដាច់ពីគ្នាយ៉ាងច្បាស់លាស់រវាងបទដ្ឋានឃើញមួយក្រឡេកភ្នែក ដែលអាចអនុវត្តមាននៅត្រង់ចំណុចនៃការទទួលយកភស្តុតាង និងការវាយតម្លៃលម្អិតជាការបន្តបន្ទាប់អំពីទម្ងន់ និងភវនីយភាពនៃភស្តុតាង។

[១០:៥៣:១៩]

លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព។ ឥឡូវនេះយើងខ្ញុំសូមត្រឡប់ទៅរកបទដ្ឋានស្តីពីភាពអាចទទួលយកបានវិញម្តង។ គេអាចត្រូវចាំក្នុងចិត្តថា ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌរបស់កម្ពុជាគឺជាប្រព័ន្ធច្បាប់ដែលបានកើតចេញពីប្រព័ន្ធច្បាប់ស៊ីវិល។ នីតិវិធីជាធរមាននៅ អ.វ.ត.ក គឺបានទទួលឥទ្ធិពលយ៉ាងខ្លាំងក្លាពីក្រមព្រហ្មទណ្ឌនៃប្រទេសបារាំង ដែលបញ្ចូលបង្រួមបានជាគោលការណ៍នៃការវាយតម្លៃដោយសេរីចំពោះភស្តុតាង។ គោលការណ៍នេះ អនុញ្ញាតឲ្យមានការចំណុចចាប់ផ្តើមក្នុងកម្រិតទាបមួយ ស្តីពីការទទួលយកភស្តុតាង ដោយសារតែភស្តុតាងទាំងអស់នេះជាចុងក្រោយនឹងត្រូវវាយតម្លៃដោយចៅក្រម អំពីទម្ងន់ និងភវនីយភាពពិតប្រាកដរបស់វា។

[១០:៥៤:២៣]

ដោយឡែកទាក់ទងនឹងប្រព័ន្ធច្បាប់ស៊ីវិល មូលហេតុមួយផ្សេងទៀតដែលគាំទ្រដល់ចំណុចឈានចូលដ៏ទាបបំផុតសម្រាប់ភាពដែលអាចទទួលយកបាននោះ គឺថា ភស្តុតាងមាននៅក្នុងសំណុំរឿងត្រូវគេប្រមូល និងពិនិត្យសាជាថ្មីឡើងវិញដោយចៅក្រមស៊ើបអង្កេតឯករាជ្យនិងមិនលម្អៀង។ ដូច្នេះ គ្រប់ភស្តុតាងទាំងអស់ដែលមាននៅក្នុងសំណុំរឿង សុទ្ធតែមានការពិនិត្យពិច័យតាមផ្លូវតុលាការរួចហើយ។ ការនោះត្រូវតែត្រូវទៅតាមរបៀបណាមួយនៃបទដ្ឋានមួយក្រឡេកភ្នែកនោះហើយ។

យើងនៅចាំបានថា សហចៅក្រមស៊ើបអង្កេតបានបដិសេធមិនព្រមទទួលឯកសារមួយចំនួនដាក់បញ្ចូលនៅក្នុងសំណុំរឿងទេ កាលណាពួកគាត់រកឃើញថា ឯកសារទាំងនោះមិនជាប់ទាក់ទង ឬមិននាំឲ្យមានការបង្ហាញដល់ការពិត។ ភស្តុតាងដែលបានជ្រើសរើស ត្រូវបានទទួលយកដោយសហចៅក្រម

ស៊ើបអង្កេត ឥឡូវនេះកំពុងត្រូវបានដាក់បង្ហាញជូនអង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះនេះមានសមាសភាពសុទ្ធតែជាចៅក្រមដែលមានវិជ្ជាជីវៈ និងមានគុណវឌ្ឍិ ក្នុងឋានៈជាចៅក្រមដែលមានបទពិសោធន៍ គេអាចមានលទ្ធភាពដើម្បីពិចារណាគ្រប់ភស្តុតាងនីមួយៗ ហើយតម្លៃទៅលើភស្តុតាងនោះ វាសមនឹងទទួលយកដោយគិតពីបរិបទទាំងមូលនៃភស្តុតាងជាឯកសារ ពីសក្ខីកម្មរបស់សាក្សី និងគិតពីសេចក្ដីសន្និដ្ឋានរបស់ភាគីនានា។ វាមិនមានហានិភ័យណាមួយដែលថា ការទទួលយកឯកសារភស្តុតាងមួយ ដែលនៅចុងបញ្ចប់ត្រូវបានគេរកឃើញថា វាមានតម្លៃភវនីយភាពទៀតនោះ នឹងត្រូវបានធ្វើឱ្យខូចដល់ប្រយោជន៍ជនជាប់ចោទនោះឡើយ។ ការណ៍នេះត្រូវបានគេលើកស្ទួយម្ដងហើយម្ដងទៀតដោយតុលាការអន្តរជាតិនានា។

[១០:៥៦:៣២]

នៅក្នុងករណីរដ្ឋអាជ្ញាទល់នឹង ណូមែន អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ អេស.ស៊ី.អេស.អិល បានសម្រេចនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៥ ថា “គេអាចទុកចិត្តទៅលើចៅក្រមជំនុំជម្រះនានា តែឯកឯងបានហើយ នៅក្នុងការឱ្យតម្លៃដ៏សមស្របទៅលើភស្តុតាងបន្ទាប់បន្សំនៅក្នុងបរិបទនៃភស្តុតាងទាំងមូលនោះ និងដោយយោងទៅតាមបទដ្ឋាននីតិវិជ្ជា ដែលយល់បានយ៉ាងត្រឹមត្រូវ” ហើយខ្ញុំយើងក៏យល់ស្របទាំងស្រុងដែរ។ ប៉ុន្តែថាតើអង្គជំនុំជម្រះនឹងដឹកនាំធ្វើការងារនេះដោយប្រណីតយ៉ាងដូចម្ដេច? បើត្រូវបានដកហូតនូវលទ្ធភាពក្នុងការពិនិត្យមើលគ្រប់ព័ត៌មានទាំងអស់ ដែលផ្ដល់នូវបរិបទដ៏ចាំបាច់ និងលទ្ធភាពក្នុងការសម្របសម្រួលធ្វើការវាយតម្លៃ អំពីភាពជឿជាក់ និងភាពរលូននៃភស្តុតាងនីមួយៗជាមួយនឹងឯកសារទាំងនេះ និងកំណត់ត្រានោះ។ សេចក្ដីសន្និដ្ឋានរបស់យើងខ្ញុំនៅក្នុងករណីដែលមានភាពស្មុគស្មាញជាមួយនឹងបទល្មើសព្រហ្មទណ្ឌ ដែលរួមមានធាតុផ្សំជាបរិបទសំខាន់ៗ គឺវាជាការសំខាន់ណាស់ ដែលមិនអាចដាក់កម្រិតនៃការទទួលយកខ្ពស់ពេកនោះទេ។ បើមិនដូច្នេះទេ អង្គជំនុំជម្រះអាចនឹងយល់ឃើញថា ខ្លួនឯងត្រូវបានគេដកហូតយកមិនឱ្យមានលក្ខណៈវិនិច្ឆ័យទៅលើភស្តុតាងនៃភាពគ្រប់គ្រាន់ទុកសម្រាប់ធ្វើការពិភាក្សាសម្រេចជាចុងក្រោយរបស់ខ្លួនជាមិនខាន។

[១០:៥៨:២៦]

ដូចដែលតុលាការ អាយ.ស៊ី.ធី.វ៉ាយ បានសម្រេចនៅក្នុងករណី ឌីឡាលិក កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ៩៨ ថា បទដ្ឋាននៃចំណុចឈានចូលសម្រាប់ការទទួលយកភស្តុតាងមិនត្រូវដាក់ខ្ពស់ហួសហេតុពេកនោះទេ ដោយហេតុថា ឯកសារនានាអាចនឹងមិនមានភាពចាំបាច់សម្រាប់ធ្វើជាសក្ខីកម្មចុង

ក្រោយ ថាមានពិរុទ្ធ ឬគ្មានពិរុទ្ធនោះទេ ក៏ប៉ុន្តែវាបានផ្តល់នូវបរិបទមួយ និងរូបភាពទាំងមូលដែលបង្ហាញដោយភស្តុតាង ដែលបានប្រមូល។

[១០:៥៩:០៥]

ឥឡូវនេះ ខ្ញុំសូមលើកឡើងអំពីប្រភពសំខាន់ៗនៃភស្តុតាង។ យើងខ្ញុំនិយាយអំពីប្រភពឯកសារសំខាន់ៗជាសង្ខេបនៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាសម្រាប់ដំណាក់កាលដំបូង។ យើងខ្ញុំនឹងលើកឡើងដោយឡែកអំពីឯកសារសហកាលនៅនឹងសម័យកម្ពុជាប្រជាធិបតេយ្យ ដោយហេតុថាឯកសារទាំងនេះតំណាងយ៉ាងជាក់ស្តែងនូវប្រភេទភស្តុតាងដ៏សំខាន់មួយ។ សហការីរបស់ខ្ញុំ គឺលោកថារីក គាត់នឹងលើកឡើងពិស្តារអំពីអនុប្រភេទនៃឯកសារមួយចំនួន។

ព័ត៌មានដ៏ច្រើនសន្ធឹកសន្ធាប់ ពាក់ព័ន្ធនឹងប្រភពដើម និងខ្សែសង្វាក់នៃការកាន់កាប់ឯកសារសហកាលកម្ពុជាប្រជាធិបតេយ្យមាននៅក្នុង៖ ទី១) ឯកសារនានាដែលមាននៅក្នុងសំណុំរឿង ទី២) កំណត់ហេតុស្តាប់ចម្លើយសាក្សីនានា និងទី៣) សក្ខីកម្មនានាដែលផ្តល់ដោយលោក ឆាំង យុ និងលោកវ៉ាន់ថាន់ ពៅដារ៉ា។ ភស្តុតាងនេះបង្ហាញថា ឯកសារសំខាន់ៗចំនួនបួនដែលជាឯកសារសហកាលនាសម័យកម្ពុជាប្រជាធិបតេយ្យ មានប្រភពមកពី៖ ទី១) ក្រសួងមហាផ្ទៃ ទី២) ប្រភពមកពីទួលស្លែង ទី៣) ប្រភពបណ្ណសារដ្ឋានជាតិ និងទី៤) អ្វីៗដែលគេហៅថា សមូហកម្មរបស់ប្រទេសស៊ុយអ៊ែត។

[១១:០០:៣៧]

ភាគច្រើននៃឯកសារមកពីប្រភពទាំងនេះ ត្រូវបានប្រមូលដំបូងដោយ ឌី.ស៊ី.ខេម ហើយបន្ទាប់មកត្រូវបានផ្តល់ឲ្យទៅការិយាល័យសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបសួរ។ បញ្ជីដែលយើងខ្ញុំបានបញ្ជូនទៅភាគីនានាកាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០១២ នៅក្នុងការដាក់ឯកសាររបស់យើងខ្ញុំ E161 បង្ហាញថា មានប្រមាណជា២៣៨៤ ឯកសារដែលមាននៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាសម្រាប់ដំណាក់កាលដំបូង គឺបានមកពី ឌី.ស៊ី.ខេម។ ខ្ញុំនៅចាំបានថា សម្រាប់កំណត់ត្រាដែលសាក្សី ឌី.ស៊ី.ខេម ពីរនាក់ មានលទ្ធភាពអាចរៀបរាប់យ៉ាងពិស្តារអំពីដំណើរការនៃការធ្វើកាតាឡុក និងការដាក់លេខឯកសារដែលធ្វើឲ្យគ្រប់ភាគីទាំងអស់ងាយស្រួលក្នុងការបញ្ជាក់អំពីប្រភពឯកសារនីមួយៗ។

នៅក្នុងករណីជាច្រើន ជាការងាយស្រួលដោយគ្រាន់តែរកមើលលើឯកសារមួយដោយប្រើលេខ ឌី.ស៊ី.ខេម ទៅលើទិន្នន័យរបស់ ឌី.ស៊ី.ខេម ដែលអាចរកបានជាសាធារណៈ។ យ៉ាងណាក៏ដោយ វាក៏

ជាការសំខាន់មួយផងដែរក្នុងការកក់សម្គាល់ថា ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ការិយាល័យសហចៅក្រមស៊ើបអង្កេតក៏បានទទួលផងដែរនូវឯកសារសហកាលនៅសម័យកម្ពុជាប្រជាធិបតេយ្យដោយផ្ទាល់ពីទួលស្លែងនិងពីបណ្ណសារដ្ឋានជាតិ ហើយនិងមិនពឹងផ្អែកទាំងស្រុងទៅលើប្រភព ឌី.ស៊ី.ខេម នោះទេ។

[១១:០២:១៩]

ឥឡូវនេះ ខ្ញុំសូមលើឡើងពីប្រភពឯកសារទាំងបួន ដែលយើងខ្ញុំបានពោលខាងដើមម្តងមួយៗដូចខាងក្រោម៖

យើងនិយាយអំពីប្រភពឯកសារមកពីក្រសួងមហាផ្ទៃ។ ឯកសាររបស់ក្រសួងមហាផ្ទៃត្រូវបានការិយាល័យសហចៅក្រមស៊ើបសួរ សហព្រះរាជអាជ្ញាប្រមូលមកពី ឌី.ស៊ី.ខេម។ លោកឆាំង យុ និងលោក វ៉ាន់ថាន់ ពៅដារ៉ា បានផ្តល់សក្ខីកម្មថា សម្ភារកម្មនេះមានរួមទាំងឯកសារទាក់ទងទៅនឹងសន្តិបាលជាតិផងដែរ ដូចជា៖ ចម្លើយសារភាព ការឆ្លើយឆ្លងផ្សេងៗ ប្រវត្តិរូប និងរូបថត។ ពួកគាត់បានផ្តល់សក្ខីកម្មផងដែរថា តាមការដឹង និងតាមជំនឿរបស់ពួកគាត់ឯកសារទាំងនេះត្រូវបានប្រមូលពីដំបូងដោយអ្នកជំនាញវៀតណាមមួយក្រុម។ ក្នុងផ្ទះមួយក្នុងទីក្រុងភ្នំពេញនៅក្រោយពេលដែលរបបខ្មែរក្រហមបានដួលរលំ។ ឯកសារទាំងនេះត្រូវបានប្រមូលគរទុកនៅក្នុងមន្ទីរមួយនៃក្រសួងមហាផ្ទៃរហូតទាល់តែមានការប្រគល់ទៅឲ្យ ឌី.ស៊ី.ខេម នៅឆ្នាំ១៩៩៦ ឬក៏នៅអំឡុងពេលនោះ។

[១១:០៣:៣៨]

ជាការសំខាន់ សាក្សីនានាធ្លាប់បានបញ្ជាក់ថា ឌី.ស៊ី.ខេម មានឯកសារដើមទាំងអស់នេះនៅក្នុងដៃរបស់ខ្លួន។ យើងខ្ញុំសូមឲ្យអង្គជំនុំជម្រះពិនិត្យមើលប្រតិចារឹក សក្ខីកម្មរបស់ វ៉ាន់ថាន់ ពៅដារ៉ា កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០១២ ត្រង់ទំព័រទី៧៤ រហូតទៅដល់ ៨០ នៃអត្ថបទភាសាអង់គ្លេស និងខ្មែរទំព័រ-- អត្ថបទខ្មែរទំព័រទី៦២ ដល់ ៦៦។ ហើយនិងសក្ខីកម្មរបស់លោក ឆាំង យុ កាលពីថ្ងៃទីមួយ ខែកុម្ភៈ ឆ្នាំ២០១២ ត្រង់ទំព័រទី៤៣ ទៅដល់ ៤៨។ បើយើងពិនិត្យទៅលើអត្ថបទជាភាសាខ្មែរវិញ គឺទំព័រ ៨៩-- ៣៩ ទៅ ៤៤។ សក្ខីកម្មផ្ទាល់មាត់នេះក៏ត្រូវគ្នាទៅនឹងកំណត់ហេតុស្តាប់ចម្លើយរបស់លោកឆាំង យុ ធ្លាប់បានផ្តល់សម្ភាសពីមុនជាមួយការិយាល័យសហចៅក្រមស៊ើបសួរ ហើយដែលនៅក្នុងនោះគាត់បានបញ្ជាក់បន្ថែមជាក់លាក់ថា ផ្ទះដែលគេរកឃើញឯកសារទាំងនោះជាផ្ទះដែលគេជឿថា ធ្លាប់ត្រូវបាន សុន សេន កាន់កាប់។

[១១:០៥:០០]

ខ្ញុំសូមអង្គជំនុំជម្រះមើលទៅលើឯកសារលេខ D204/4 ស្តីពីកំណត់ហេតុស្តាប់ចម្លើយរបស់លោក ឆាំង យុ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ ត្រង់ទំព័រទី៣ ជាភាសាអង់គ្លេស ហើយខ្មែរត្រង់ទំព័រទី៤។ សក្ខីកម្មទាំងនេះ ក៏ត្រូវបាន-- គ្នាផងដែរទៅនឹងព័ត៌មានដែលមាននៅក្នុងអត្ថបទដែលសហនិពន្ធដោយលោក ឆាំង យុ ដែលមានចំណងជើងថា "ឯកសារស្តីពីឧក្រិដ្ឋកម្មនៃកម្ពុជាប្រជាធិបតេយ្យ" ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៩ អត្ថបទនេះមាននៅក្នុងសំណុំរឿងដែលមានលេខឯកសារ D155.3។ យើងខ្ញុំសូមឲ្យអង្គជំនុំជម្រះពិនិត្យមើលត្រង់ទំព័រទី២២៦ រហូតទៅដល់២៣០ ដែលនិយាយអំពីប្រភេទផ្សេងៗនៃឯកសារនៅក្នុងសម្ងហកម្មក្រសួងមហាផ្ទៃ។

[១១:០៦:១២]

ស្តីពីបញ្ហាសំដៅដើម។ យើងខ្ញុំសូមធ្វើការកត់សម្គាល់ថា ក្នុងអំឡុងពេលនៃស៊ើបសួរ សំដៅដើមដែលបានមកពីសម្ងហកម្មនេះ ត្រូវបានពិនិត្យ និងស្កេនជាពណ៌ដោយមន្ត្រីផ្លូវការរបស់ការិយាល័យសហចៅក្រមស៊ើបសួរ។ សំដៅដើមជាច្រើនដែលមានស្កេនជាពណ៌ គឺនៅក្នុងសំណុំរឿង ហើយលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់ងាយស្រួលមើល។ ត្រង់ចំណុចនេះ ខ្ញុំសូមលោកពិនិត្យទៅមើលចម្លើយតបរបស់ការិយាល័យសហព្រះរាជអាជ្ញា ទៅនឹងសំណើឲ្យមានការដាក់បង្ហាញ ឯកសារសំដៅដើមរបស់ ខៀវ សំផន ដែលមានឯកសារលេខ E168/1 ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២ ត្រង់កថាខណ្ឌទី១៣ដល់១៥នៃចម្លើយតបនេះ។ សហព្រះរាជអាជ្ញាបានលើកភស្តុតាងដែលមាន នៅក្នុងសំណុំរឿងដោយបញ្ជាក់ថា សំដៅដើមបានមកពី ឌី.ស៊ី.ខេម នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ។

[១១:០៧:១៨]

ឥឡូវនេះ ខ្ញុំសូមចូលទៅដល់ប្រភពឯកសារដែលបានមកពីទួលស្លែងវិញម្តង។ ឯកសារនានាបានមកពីទួលស្លែងក្នុងចំណោមឯកសារទាំងនេះសំខាន់រួមមាន៖ ចម្លើយសារភាព កំណត់ហេតុ និងប្រវត្តិរូបអ្នកទោស ប៉ុន្តែក៏រួមបញ្ចូលទាំងឯកសារនានាដែលប្រភពដើមចេញមកពីមន្ទីរ និងក្រសួងនានានៃកម្ពុជាប្រជាធិបតេយ្យផងដែរ។ ឯកសារទាំងនេះ ទទួលបានមកពីមជ្ឈមណ្ឌល ឌី.ស៊ី.ខេម និងទួលស្លែងដោយផ្ទាល់នៅក្នុងអំឡុងពេលនៃដំណើរកិច្ចស៊ើបសួរ។

នៅក្នុងសក្ខីកម្មផ្ទាល់មាត់របស់ខ្លួន លោក វ៉ាន់ថាន់ ពៅដារ៉ា និងលោក ឆាំង យុ បានផ្តល់ព័ត៌មានស្តីពីការប្រមូលចងក្រងនេះ។ យើងខ្ញុំសូមឲ្យអង្គជំនុំជម្រះពិនិត្យទៅលើប្រតិចារឹកកាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០១២ ជាភាសាអង់គ្លេសនៃការផ្តល់សក្ខីកម្មរបស់លោក វ៉ាន់ថាន់ ពៅដារ៉ា ពីទំព័រ

ទី៧៣ ដល់៧៤ ជាភាសាអង់គ្លេស។ ហើយយើងអាចមើលភាសាខ្មែរបាន គឺទំព័រទី៦០ ដល់៦១។ និងប្រតិចារឹកនៃការផ្តល់សក្ខីកម្មរបស់លោក ឆាំង យុ កាលពីថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១២។ ពីភាសាអង់គ្លេសទំព័រទី៦៥ ទៅដល់៧០។ ភាសាខ្មែរទំព័រទី៥៧ ដល់៦១។ ឯកសារមួយទៀត ភាសាអង់គ្លេសទំព័រទី១០៥ ភាសាខ្មែរទំព័រទី៨៩ និងភាសាអង់គ្លេសទំព័រទី១១៧ ភាសាខ្មែរទំព័រ១០០។

[១១:០៩:១៧]

សាក្សីទាំងពីររូបបានផ្តល់សក្ខីកម្មថា ឌី.ស៊ី.ខេម បានយកមកពីទួលស្លែងតែឯកសារច្បាប់ចម្លងប៉ុណ្ណោះ និងថាឯកសារច្បាប់ដើមគឺស្ថិតនៅឯទួលស្លែងដដែល។ ឯកសារទាំងនេះត្រូវបានបញ្ជាក់អត្តសញ្ញាណនៅក្នុងទិន្នន័យរបស់ ឌី.ស៊ី.ខេម ដោយបានដាក់បុព្វបទជាសំខាន់ថា ធី.អេស.អិល។ បុព្វបទនេះ អាចឃើញមាននៅក្នុងឯកសារច្បាប់ចម្លងនៃឯកសារនានា ដែលបានមកពីទួលស្លែង ដែលការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យសហចៅក្រមស៊ើបអង្កេតទទួលបានពី ឌី.ស៊ី.ខេម។ រីឯចំណែកឯកសារដែលបានរកឃើញនៅទួលស្លែង មានប្រភពដើមចេញពីមន្ទីរនានារបស់កម្ពុជាប្រជាធិបតេយ្យ។ លោក ឆាំង យុ បានផ្តល់សក្ខីកម្មថា តាមបទពិសោធន៍របស់លោក ការដែលឯកសារនានាមកពីក្រសួងណាមួយនៃកម្ពុជាប្រជាធិបតេយ្យ ត្រូវបានគេរកឃើញនៅក្នុងក្រសួងណាមួយផ្សេងទៀតនោះ គឺមិនមែនជាលក្ខណៈខុសប្លែកពីធម្មតាទេ។ ឧទាហរណ៍ដូចជា ដោយសារឯកសារនោះ ត្រូវបានគេផ្ញើទៅមកក្នុងនាមជាលិខិតឆ្លើយឆ្លងគ្នា ពីក្រសួងមួយទៅក្រសួងមួយផ្សេងទៀត។

[១១:១០:៤១]

នៅក្នុងសំណុំរឿង ក៏មានដាក់បញ្ចូលនូវកំណត់ហេតុជាលាយលក្ខណ៍អក្សរ នៃការធ្វើសម្ភាសន៍របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ជាមួយអតីតបុគ្គលិកនានានៃមន្ទីរទួលស្លែងផងដែរ។ ការសម្ភាសរបស់សាក្សីទាំងនេះ បានផ្តល់នូវព័ត៌មានដ៏មានតម្លៃ ដូចជាអំពីប្រភេទនៃឯកសារដែលស្ថិតនៅក្នុងសារមន្ទីរ អំពីកាលៈទេសៈនៃការរកឃើញឯកសារទាំងនោះ និងអំពីដំណើរការក្នុងការរៀបចំចងក្រង។ ដើម្បីជាប្រយោជន៍ដល់ការចងក្រងសំណុំឯកសារនេះ យើងខ្ញុំកត់សម្គាល់ឃើញថា ចម្លើយរបស់សាក្សីនោះគឺមាន ឯកសារលេខ D108/42/1 កំណត់ហេតុស្តាប់ចម្លើយនៃសាក្សី TCW-97 ចុះថ្ងៃ២៥ ខែមីនា ឆ្នាំ២០០៨។ ឯកសារលេខ D108/32/2 កំណត់ហេតុស្តាប់ចម្លើយនៃសាក្សី TCW-368 ចុះថ្ងៃ២៦ ខែមីនា ឆ្នាំ២០០៨ និងឯកសារលេខ D108/21/12 កំណត់ហេតុស្តាប់ចម្លើយនៃសាក្សីមួយរូបដែលមិនទាន់បានដាក់របស្សនាមនៅឡើយ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៨។

[១១:១២:៤៣]

នៅក្នុងពេលនៃការធ្វើសម្ភាសន៍នេះ សាក្សី TCW-97 ដែលបានចាប់ផ្តើមធ្វើការនៅសារមន្ទីរនេះ នៅក្នុងខែឧសភា ឆ្នាំ១៩៧៩ ហើយដែលបានកាន់តំណែងមួយ នៅក្នុងសារមន្ទីរទួលស្លែងនេះ បានបញ្ជាក់ថា គាត់បានចូលរួមនៅក្នុងការប្រមូលចងក្រងឯកសារ ដែលមកពីតាមអគារនានានៅក្នុងបរិវេណ នៃស-២១ ព្រមទាំងតាមផ្ទះនានា ដែលនៅក្បែរៗនោះ។ គាត់បានផ្តល់សក្ខីកម្មថា អ្នករក្សាបណ្ណសារនៅក្រោមការគ្រប់គ្រងរបស់លោក អ៊ុំង ប៊ិច, អ៊ុំង ប៊ិច គាត់បានស្លាប់ហើយ, បានប្រមូលផ្តុំរាល់ឯកសារនានាទាំងអស់ ដែលទាក់ទងនឹងជនណាម្នាក់ជាងដែលៗ និងបានដាក់លេខរៀងតាមលំដាប់អក្សរទៅលើឯកសារទាំងនោះ។ គាត់បានផ្តល់សក្ខីកម្មយ៉ាងលម្អិតដូចជា អំពីការរក្សាទុកឯកសារច្បាប់ដើម ចាប់តាំងពីឆ្នាំ១៩៧៩ តរហូតមក។ គាត់បានរៀបរាប់អំពីកន្លែងដាក់លាក់នានា និងអំពីវិធីសាស្ត្រផ្សេងៗ ក្នុងការរក្សាទុក ដែលត្រូវបានយកមកប្រើជាច្រើនឆ្នាំមកនេះ។

[១១:១៤:០៨]

សាក្សី TCW-368 អតីតបុគ្គលិកមួយរូបបាននិយាយប្រាប់ការិយាល័យសហចៅក្រមស៊ើបសួរថា ឯកសារដែលបានរកឃើញនៅទួលស្លែង ដែលរួមទាំងការរកឃើញតាមផ្ទះដែលនៅជិតខាងនោះ ដែលរួមមានចម្លើយសារភាពនានា សៀវភៅបញ្ជីសម្លាប់ សៀវភៅបញ្ជីសួរចម្លើយ សង្ខេបចម្លើយសារភាព សៀវភៅអប់រំរៀនសូត្រ លក្ខន្តិកៈនានារបស់បក្សកុម្មុយនីស្តកម្ពុជា សុន្ទរកថា និងសារាចរណែនាំផ្សេងៗ ព្រមទាំងច្បាប់ចម្លងនៃទស្សនាវដ្តីទង់បដិវត្ត និងយុវជនបដិវត្ត។

នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ មន្ត្រីនៃការិយាល័យសហចៅក្រមស៊ើបសួរ បានធ្វើការត្រួតពិនិត្យមើល និងស្នើសុំឲ្យស្កេនឯកសារពណ៌ច្បាប់ដើម ដែលមាននៅទួលស្លែងមួយចំនួនធំ។ ឯកសារទាំងនេះកំពុងតែនៅក្នុងសំណុំរឿង និងមានបញ្ជាក់អត្តសញ្ញាណច្បាស់ថា ចម្លងចេញពីច្បាប់ដើម។

យើងខ្ញុំលើកយោងជូនលោកប្រធានអង្គជំនុំជម្រះ ដើម្បីមេត្តាពិនិត្យមើលនៅក្នុងឯកសារនានាដែលបានដាក់អនុលោមតាមដីកាចាត់ឲ្យសួរជំនួស ឯកសារលេខ D82 ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៨ និងឯកសារលេខ D159 ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០០៨។ យើងខ្ញុំក៏សូមលើកយោងជូនលោកលោកស្រីចៅក្រមនៃអង្គជំនុំជម្រះ ដើម្បីមេត្តាពិនិត្យមើលនៅក្នុងរបាយការណ៍អនុវត្តដីកាចាត់ឲ្យសួរជំនួសនានា ដែលត្រូវដាក់ព្រមជាមួយនឹងច្បាប់ចម្លងនានាដែលពាក់ព័ន្ធ។ របាយការណ៍ទាំងនេះពន្យល់អំពីកាលៈទេសៈនៃការត្រួតពិនិត្យមើល និងការចម្លងចេញពីច្បាប់ដើម។

[១១:១៦:៣០]

ឥឡូវនេះ ខ្ញុំចូលមកប្រភពឯកសារបណ្ណសារដ្ឋានជាតិវិញ។ ឯការប្រមូលចងក្រងឯកសារនៃបណ្ណសារជាតិវិញ ភាគច្រើននៃឯកសារទាំងនេះអាចត្រូវបានធ្វើការរៀបរាប់ដោយទូលំទូលាយបានថាជាសំណុំឯកសារពាណិជ្ជកម្មនៃកម្ពុជាប្រជាធិបតេយ្យ។ លោក ឆាំង យុ បានផ្តល់សក្ខីកម្មថា តាមដែលគាត់ដឹងឯកសារនៃបណ្ណសារដ្ឋានជាតិ កាលពីដំបូងគឺត្រូវបានរក្សាទុកនៅឯក្រសួងឃោសនាការនិងព័ត៌មាន។ កាលនោះលោក កែវ ចិន្តា គ្រប់គ្រងថែរក្សា។ ឯកសារទាំងនោះត្រូវបានស្ថិតក្រោមការគ្រប់គ្រងរបស់លោក កែវ ចិន្តា រហូតមកទាល់ពេលដែលបណ្ណសារជាតិត្រូវបានគេបង្កើតឡើងដែលមានតួនាទី ភារកិច្ចក្នុងការប្រមូលចងក្រងឯកសារជាតិនានា។ បន្ទាប់មកឯកសារទាំងនោះ ក៏ត្រូវបានផ្ទេរបញ្ជូនទៅឲ្យបណ្ណសារដ្ឋានជាតិ ដែលនៅទីនោះ ឯកសារត្រូវបាន ឌី.ស៊ី.ខេម ធ្វើការថតចម្លងចាប់ផ្តើមពីអំឡុងឆ្នាំ១៩៩៦ មក។

លោក ឆាំង យុ បានផ្តល់សក្ខីកម្មថា ឯកសារច្បាប់ដើមនានា ដែលត្រូវបានធ្វើការត្រួតពិនិត្យនិងចម្លងរួច ហាក់ដូចជាឯកសារកាលពីសម័យកម្ពុជាប្រជាធិបតេយ្យ និងឯកសារដើមទាំងនេះ គឺមានស្ថិតនៅក្នុងបណ្ណសារដ្ឋានជាតិដដែល។

យើងខ្ញុំសូមបង្ហាញអង្គជំនុំជម្រះជាពិសេស លើកយោងទៅលើសក្ខីកម្មរបស់ ឆាំង យុ កាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១២ ត្រង់ទំព័រចាប់ពី៥៦ ដល់ ៦២។ ភាសាខ្មែរ ទំព័រ៥០ ដល់ ៥៥ នៃប្រតិចារឹក។

[១១:១៨:៣៣]

ព័ត៌មានបន្ថែមដូចជាអំពីប្រភពដើមនៃឯកសារ ដែលនៅក្នុងបណ្ណសារដ្ឋានជាតិ មានចែងរៀបរាប់នៅក្នុងបរិបទនិពន្ធដោយលោក ឆាំង យុ ដែលខ្ញុំបានលើកយោងពីខាងដើមស្រាប់។ ឯកសារលេខ D155.3 ត្រង់ទំព័រ ២២៨ នៅក្នុងអត្ថបទមាននិយាយថា "មានកំណត់ហេតុរបស់គណៈកម្មាធិការអចិន្ត្រៃយ៍មួយចំនួន ត្រូវបានតម្កល់ទុកនៅក្នុងបណ្ណសារដ្ឋានជាតិ ដោយមន្ត្រីនានានៃរណសិរ្ស"។

ដូចគ្នានឹងឯកសារទួលស្លែងដែរ នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ មានមន្ត្រីការិយាល័យសហចៅក្រមស៊ើបសួរបានចុះមកធ្វើការត្រួតពិនិត្យ និងបានសុំយកឯកសារថតចម្លងពណ៌នៃឯកសារច្បាប់ដើមមួយចំនួន ដោយផ្ទាល់ពីបណ្ណសារដ្ឋានជាតិ។ លើចំណុចនេះ ឯកសារនានាបានដាក់ដោយអនុលោមតាមដីកាចាត់ឲ្យសួរជំនួស ឯកសារលេខ D161។ ឯកសារទាំងនេះ ត្រូវបានជូនភ្ជាប់ជាមួយនឹងរបាយការណ៍នៃការអនុវត្តដីកាចាត់ឲ្យសួរជំនួស។ ឯកសារលេខ D161/1 ចុះថ្ងៃទី០៤ ខែកុម្ភៈ

ឆ្នាំ២០០៩។

[១១:២០:០៣]

យើងខ្ញុំសូមចូលមកកម្រងឯកសារ ដែលចងក្រងដោយប្រទេសស៊ុយអែតវិញម្តង។ នៅលើឯកសារអ្វីដែលហៅថា កម្រងឯកសារចងក្រងដោយប្រទេសស៊ុយអែត។ កម្រងឯកសារនេះរាប់បញ្ចូលនូវរបាយការណ៍របស់បណ្តាបណ្តាញផ្សាយព័ត៌មាននានារបស់កម្ពុជាប្រជាធិបតេយ្យ សេចក្តីថ្លែងការណ៍ជាសាធារណៈនានា និងឯកសារផ្សេងៗដែលបានបោះពុម្ពផ្សាយដោយរណសិរ្សរួបរួមជាតិ ឬរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា កាលពីអំឡុងសហកាលជាបន្ថែមពីលើរបាយការណ៍ដែលរាយការណ៍នៅក្នុងសហកាលដោយបណ្តាញផ្សាយព័ត៌មានអន្តរជាតិនានា។ ឯកសារទាំងឡាយដែលមាននៅក្នុងកម្រងឯកសារនេះ គឺទទួលបានមកពី ឌី.ស៊ី.ខេម នៅក្នុងអំឡុងពេលនៃដំណើរការនៃកិច្ចស៊ើបសួរ។

[១១:២១:០៦]

លោក ឆាំង យុ និងលោក វ៉ាន់ថាន់ ពៅដារ៉ា បានផ្តល់សក្ខីកម្មដូចជា អំពីប្រភពដើមនៃកម្រងឯកសារនេះ។ ខ្ញុំសូមលើកយោងជូនលោក លោកស្រីចៅក្រមនៃអង្គជំនុំជម្រះដើម្បីមើលនូវសក្ខីកម្មរបស់លោក ឆាំង យុ ចុះថ្ងៃទី០១ កុម្ភៈ ឆ្នាំ២០១២ ត្រង់ទំព័រចាប់ពី៤១ ដល់ ៤២ ហើយភាសាខ្មែរទំព័រ ៣៨, ៣៩ នៃប្រតិចារឹក ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២ និងទំព័រ២០ ភាសាអង់គ្លេស ចំណែកខ្មែរទំព័រ ១៦ និងភាសាអង់គ្លេសទំព័រ៩១។ ភាសាខ្មែរទំព័រ៧៦ នៃប្រតិចារឹក។ ហើយនិងដើម្បីមើលនូវសក្ខីកម្មរបស់លោក វ៉ាន់ថាន់ ពៅដារ៉ា កាលពីថ្ងៃ២៣ ខែមករា ឆ្នាំ២០១២ ត្រង់ទំព័រភាសាអង់គ្លេស៤៧ រហូតទៅដល់៤៨។ ទំព័រជាភាសាខ្មែរ៣៨ ដល់៣៩ នៃប្រតិចារឹក។ សាក្សីទាំងពីរនាក់នេះបានផ្តល់សក្ខីកម្មថា ជាសរុបទាំងអស់នៅក្នុងកម្រងឯកសារនេះរួមមាន ប្រមាណជាពីប្រាំមួយទៅប្រាំពីរពាន់ទំព័រ។

[១១:២២:៤០]

ពួកគេថ្លែងថា ឯកសារទាំងនេះត្រូវបានរៀបចំចងក្រងជាកម្រងឯកសារដោយគណៈកម្មាធិការមិត្តភាពនៃប្រទេសឡាវ វៀតណាម កម្ពុជា ស៊ុយអែត ដែលជាសមាជិករបស់គណៈកម្មាធិការនេះ បានមកធ្វើទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យ នៅក្នុងឆ្នាំ១៩៧៨។ កម្រងឯកសារនេះបានទទួលមកពី ឌី.ស៊ី.ខេម នៅក្នុងឆ្នាំ២០០៧ បន្ទាប់ពីធ្វើសេចក្តីអំពាវនាវជាសាធារណៈរបស់ ឌី.ស៊ី.ខេម ទៅដល់អ្នកដែលប្រមូលចងក្រងឯកសារ ដែលជាឯកជនក្តី ជាសាធារណៈក្តី សូមឲ្យជួយផ្តល់នូវឯកសារនានាដែលពាក់ព័ន្ធនឹងកម្ពុជាប្រជាធិបតេយ្យ។ ឯកសារនានាត្រូវបានទទួលក្នុងនាមជាផ្នែកនៃកម្រងឯកសាររបស់

ប្រទេសស៊ុយអែត ដែលមានចំនួនដ៏ច្រើនសន្ធឹក សុទ្ធតែជាឯកសារច្បាប់ចម្លងចេញពីច្បាប់ដើម ស្ថិតនៅក្នុងសាកលវិទ្យាល័យ *លូនដ៍ យូនីវ៉ែរស៊ីធី*។

[១១:២៣:៥៤]

ជាការសន្និដ្ឋាន លោក លោកស្រីចៅក្រមនៃអង្គជំនុំជម្រះ យើងខ្ញុំបានគូសបញ្ជាក់ដោយត្រួសៗរួចហើយ អំពីគោលការណ៍នានានៃច្បាប់ជាធរមាន និងអំពីភស្តុតាងដែលមាននៅក្នុងសំណុំរឿងទាក់ទងនឹងប្រភពដើម ព្រមទាំងអំពីខ្សែសង្វាក់នៃការរក្សា គ្រប់គ្រងសម្រាប់ប្រភពឯកសារសំខាន់ៗនៃភស្តុតាងចំនួនបួន។ នៅក្នុងសេចក្តីសន្និដ្ឋានរបស់យើងខ្ញុំ ភស្តុតាងនេះ ពេលរួមបញ្ចូលជាមួយគ្នា គឺនឹងបង្កើតបានទៅជាមូលដ្ឋានដ៏រឹងមាំ និងនាំឲ្យសំណុំឯកសារទាំងនេះត្រូវបានទទួលយកក្នុងនាមជាឯកសារដែលមានយថាភាព និងដែលអាចឲ្យជឿទុកចិត្តបាន។

លោកប្រធាន លោក លោកស្រីចៅក្រម ការឆ្លើយតបរបស់យើងខ្ញុំនៅពេលនេះ គឺនឹងផ្ទេរជូនលោក ថារីក ដើម្បីធ្វើការបន្ត។ ប៉ុន្តែមុននឹងខ្ញុំបញ្ចប់ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធានមួយ ទាក់ទងនឹងលោក ម៉ែខល កាណាវាស កាលពីម្សិលមិញ ថ្ងៃទី១២ រសៀល គាត់បានលើកថា ការិយាល័យសហព្រះរាជអាជ្ញាលួចដាក់ឯកសារ។ អ៊ីចឹងការិយាល័យសហព្រះរាជអាជ្ញា សូមជំទាស់ មិនបានលួចដាក់ឯកសារទេ គឺយើងខ្ញុំបានបញ្ជូនឯកសារនេះជាផ្លូវការ។ សូមអរគុណ លោកប្រធាន។

[១១:២៥:៤១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព សូមគោរពអស់លោក លោកស្រី មេធាវីការពារក្តី និងភាគី។

ដូចដែលសហសេវិករបស់ខ្ញុំបានបញ្ជាក់ នៅពេលនេះ ខ្ញុំសូមនឹងឆ្លើយតបដោយជាក់លាក់ទៅការជំទាស់ ដែលឮរយៈពេលពីរថ្ងៃរួចមកហើយ ដោយក្រុមមេធាវីការពារក្តី។ ហើយខ្ញុំនឹងធ្វើការឆ្លើយតបក្នុងពីររបៀប។ ទីមួយ ជាបឋម ខ្ញុំនឹងលើកឡើងបញ្ហាប្រធានបទមួយៗដែលបានលើកឡើង ហើយគឺការលើកឡើងនេះ គឺធ្វើឡើងដោយក្រុមមេធាវីការពារក្តី។ បន្ទាប់មក ទីពីរនោះ គឺខ្ញុំនឹងចូលទៅដល់ឧបសម្ព័ន្ធនីមួយៗ បន្ទាប់មកធ្វើការសន្និដ្ឋាននិងឆ្លើយតបទៅលើការជំទាស់ដែលពាក់ព័ន្ធទៅនឹងឧបសម្ព័ន្ធ

នីមួយៗទាំងអស់នោះ។

[១១:២៦:៥៨]

ជាបឋម ខ្ញុំសូមបន្តធ្វើការឆ្លើយតបទៅលើប្រធានបទនីមួយៗ ដែលបានជំទាស់ ហើយបន្តទៅលើសេចក្តីសន្និដ្ឋានរបស់សហសេវិករបស់ខ្ញុំ ដោយលើកឡើងអំពីជំហរផ្លូវច្បាប់ដាក់ជូនចំពោះមុខអង្គជំនុំជម្រះ ជាពិសេសទៅលើប្រភពនៃភស្តុតាងដែលប្រមូលបាន ហើយបន្ទាប់មកនៅពេលរសៀល ខ្ញុំនឹងបន្តចូលទៅដល់ឧបសម្ព័ន្ធជាក់លាក់ចំនួនបី គឺឧបសម្ព័ន្ធ៧, ១៥ និង១៩ ដែលមាននៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញា។ បន្ទាប់មក ខ្ញុំនឹងផ្តល់វេទិកាទៅដល់ក្រុមសហព្រះរាជអាជ្ញាបន្ទាប់ទៀត ហើយខ្ញុំសូមអនុញ្ញាតឲ្យលោកប្រធានអនុញ្ញាតឲ្យក្រុមរបស់យើងខ្ញុំបន្តធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ទាំងអស់ទៅលើចម្លើយតបរបស់យើង។

[១១:២៧:៥៣]

ជាបឋម ខ្ញុំអាចចាប់ផ្តើមលើកឡើងចំណុចមូលដ្ឋានដែលបានលើកឡើងកាលពីម្សិលមិញ ដែលលើកឡើងដោយមេធាវីការពារក្តី អៀង សារី មានការលើកឡើងថា ខាងសហព្រះរាជអាជ្ញាព្យាយាមធ្វើឲ្យប៉ះពាល់ទៅដល់កិច្ចដំណើរការនីតិវិធី ដោយការប្រើប្រាស់ឯកសារទាំងអស់នេះ។ គោលបំណងនិងវិជ្ជាជីវៈរបស់យើងខ្ញុំនោះ គឺគេលើកឡើង ដោយចោទជាបញ្ហា។ ខ្ញុំគិតថា ការលើកឡើងដូច្នេះ គឺជាការលើកឡើងមួយដែលយើងមិនទាមទារឲ្យលើកឡើងដូច្នោះនោះទេ។ ខាងសហព្រះរាជអាជ្ញាបានលើកឡើងសំណើរបស់ខ្លួនរួចមកហើយ ហើយសាក្សីបញ្ជីសាក្សីរបស់យើង E9/4.1 បញ្ជីនេះ គឺមានសាក្សីប្រហែលជាជិត៣០០នាក់ ដែលយើងបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ សាក្សីទាំងអស់នោះ គឺ ៨០ ទៅ៩០ នាក់ពាក់ព័ន្ធទៅនឹងប្រតិបត្តិការនៃរបបនេះ កាលៈទេសៈដែលកំណត់ហេតុកម្ពុជាប្រជាធិបតេយ្យបានបង្កើតឡើង...។ល។ ដូច្នេះ យើងមិនព្យាយាមធ្វើឲ្យមានការប៉ះពាល់ទៅដល់សក្ខីកម្មនូវអ្វីដែលយើងបានព្យាយាមធ្វើនោះទេ។ អ្វីដែលយើងព្យាយាមធ្វើនោះ គឺដាក់នៅកម្រងឯកសារទាំងឡាយដែលយើងបានដាក់ថាជាសក្ខីកម្ម។

ចំពោះកំហុសទាំងឡាយដែលបានលើកឡើង ខាងសហសេវិករបស់ខ្ញុំនឹងលើកឡើងឆ្លើយតប។ យើងនៅតែគោរពទៅតាមវិជ្ជាជីវៈរបស់យើង។ ឧទាហរណ៍ ដែលបានលើកឡើងដោយក្រុមមេធាវីការពារក្តីគឺមិនត្រឹមត្រូវនោះទេ ក៏ប៉ុន្តែខ្ញុំទុកចំណុចហ្នឹងឲ្យសហសេវិករបស់ខ្ញុំម្នាក់ទៀតជាអ្នកឆ្លើយតប។

[១១:៣០:១៣]

ខ្ញុំសូមចូលទៅដល់ប្រធានបទចម្បងដែលយើងបានឮក្នុងរយៈពេលពីរថ្ងៃចុងក្រោយនេះ ពាក់ព័ន្ធទៅនឹងបញ្ហាដែលថា ឯកសារវាពាក់ព័ន្ធ ឬក៏មិនពាក់ព័ន្ធ។ មេធាវីការពារក្តីនីមួយៗបានលើកឡើងទៅលើចំណុចនេះ ដូច្នេះយើងខ្ញុំសូមឆ្លើយតប ដោយដកស្រង់សម្តីរបស់មេធាវីការពារក្តី នួន ជា ដែលលើកឡើងថា "មានតែទីតាំងបទល្មើសតែពីរតែប៉ុណ្ណោះ ដែលបានបញ្ចូលនៅក្នុងសវនាការវគ្គដំបូង ដែលទីកន្លែងចំនួនពីរនោះ វាជាការគំរាមកំហែង និងជាបទល្មើស"។ ដូច្នេះហើយអង្គជំនុំជម្រះត្រូវតែធ្វើការអនុវត្តវិធីសាស្រ្តរបស់ខ្លួនឲ្យបានត្រឹមត្រូវ ដោយពិនិត្យទៅលើភស្តុតាងដែលស៊ីសង្វាក់ទៅនឹងហេតុការណ៍ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

មេធាវីការពារក្តីទាំងអស់បានស្នើឡើងថា ឯកសារជាច្រើននៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញាមិនពាក់ព័ន្ធនោះទេ ដោយសារតែឯកសារទាំងអស់នោះមិនលើកឡើងអំពីការផ្លាស់ទីលំនៅដោយបង្ខំទៅលើប្រជាជននៅមុនឆ្នាំ១៩៧៥ ឬក៏នៅក្នុងដំណាក់កាលទីពីរ។

[១១:៣១:៣៧]

ខ្ញុំនឹងឆ្លើយតបលម្អិតទៅលើចំណុចទាំងអស់នេះ ដោយសារតែវាសំខាន់ណាស់ ដើម្បីឲ្យយើងយល់អំពីភាពពាក់ព័ន្ធនៃឯកសារ។ យើងខ្ញុំលើកឡើងថាវាសំខាន់ យើងត្រូវតែយល់ឲ្យបានច្បាស់ថា តើយើងមកដល់ត្រឹមនេះដោយរបៀបណា? ហើយយើងកំពុងតែដោះស្រាយ ចាត់ចែងទៅលើបញ្ជីឯកសារដែលក្នុងនេះមានឯកសារជាច្រើនត្រូវបានជំទាស់។ ខ្ញុំសង្ឃឹមថាមេធាវី ខៀវ សំផន នោះគឺគាត់បានលើកឡើងថាបញ្ជីទាំងអស់នេះបានដាក់មុនពេលដែលអង្គជំនុំជម្រះចេញដីកាបង្គាប់បំបែកនីតិវិធី។ បញ្ជីរបស់យើងនោះបានដាក់មុនថ្ងៃទី២១ ខែកក្កដា ដូច្នេះហើយមិននៅ-- មិនមែនមុនដំណាក់កាលបំបែកកិច្ចដំណើរការនីតិវិធីនោះទេ។ យើងខ្ញុំបានឆ្លើយតបទៅនឹងប្រធានបទមួយចំនួនដែលអង្គជំនុំជម្រះបានបញ្ជាក់ហើយថាវាពាក់ព័ន្ធទៅនឹងដំណាក់កាលសវនាការវគ្គដំបូង គឺមុនពេលកិច្ចដំណើរការនីតិវិធី។

អង្គជំនុំជម្រះបានបញ្ជាក់រួចមកហើយ បានលើកឡើងនៅក្នុងការដាក់ឯកសារនានា អង្គជំនុំជម្រះបានបញ្ជាក់អំពីប្រធានបទ៖ ទី១) គឺរចនាសម្ព័ន្ធកម្ពុជាប្រជាធិបតេយ្យ ទី២) គឺតួនាទីរបស់ជនជាប់ចោទនីមួយៗមុនពេលបង្កើតកម្ពុជាប្រជាធិបតេយ្យ ទី៣) តួនាទីរបស់ជនជាប់ចោទនីមួយៗនៅក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ការទទួលខុសត្រូវរបស់ពួកគេ អំណាចរបស់ពួកគេ និងខ្សែទំនាក់ទំនងក្នុងរយៈពេលកាលដែលអង្គជំនុំជម្រះមានយុត្តាធិការ។

ចំណុចចុងក្រោយ គឺគោលនយោបាយកម្ពុជាប្រជាធិបតេយ្យដែលលើកឡើងនៅក្នុងដីកាបញ្ជូន

រឿងទៅជំនុំជម្រះ។ ទាំងអស់នេះហើយគឺវិសាលភាពនៃចំណុចទាំងអស់ ដែលវាពាក់ព័ន្ធទៅនឹងឯកសារនៅក្នុងបញ្ជីសហព្រះរាជអាជ្ញាវគ្គដំបូង។

[១១:៣៣:៤៥]

នៅខែកក្កដា ឆ្នាំ២០១១ នេះគឺអ្វីដែលយើងបានលើកឡើង។ នៅបន្ទាប់មក អង្គជំនុំជម្រះបានសម្រេចបំបែកកិច្ចដំណើរការនីតិវិធីជាផ្នែក ជាវគ្គៗ។ យើងឃើញមាននៅក្នុងឯកសារE124 គឺចុះថ្ងៃទី --

**អ្នកបកប្រែ៖**

សូមលោកប្រធានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាបញ្ជាក់ថ្ងៃឡើងវិញទៅលើឯកសារ។

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញាដូចជាលឿនពេកបន្ថយល្បឿនបន្តិច ហើយអំមិញឯកសារ E124 អំមិញខាងចុះថ្ងៃខែឆ្នាំណានោះ គឺខាងអ្នកបកប្រែស្តាប់មិនទាន់ទេ សូមលោកបញ្ជាក់ឡើងវិញ។

[១១:៣៤:៤២]

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណលោកប្រធាន ហើយខ្ញុំសូមអភ័យទោសចំពោះអ្នកបកប្រែផងដែរ និងអ្នកដែលធ្វើកំណត់ប្រតិចារឹកទៅលើព័ត៌មានទាំងអស់នេះ។ ខ្ញុំនិយាយអំពីដីកាបំបែកកិច្ចដំណើរការនីតិវិធី ឯកសារ E124 ខ្ញុំបានបញ្ជាក់ថា នៅពេលដែលអង្គជំនុំជម្រះបំបែកកិច្ចដំណើរការនីតិវិធី ហើយសម្រេចដំណើរការនីតិវិធីជាបឋមដោយផ្តោតទៅលើទីតាំងបទល្មើស ពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅដោយបង្ខំ អង្គជំនុំជម្រះនៅតែរក្សានូវធាតុផ្សំបរិបទនានាផងដែរ។ ដីកាសម្រេចរបស់លោក លោក លោកស្រីចៅក្រម ខែកញ្ញា ឆ្នាំ២០០៧ នៅក្នុងកថាខណ្ឌ៥ គឺបានបន្ថែមទីតាំងបទល្មើស និងបទចោទផ្សេងទៀត ដែលជាកម្មវត្ថុនៃការជំនុំជម្រះសវនាការវគ្គដំបូង។

[១១:៣៥:៤៧]

ជាការពិត យើងបានចាំទាំងអស់គ្នាហើយនៅកថាខណ្ឌ៦ អង្គជំនុំជម្រះបានបញ្ជាក់ថា អង្គជំនុំជម្រះបានបញ្ជាក់ថា អង្គជំនុំជម្រះអាចសម្រេចបញ្ចូលនៅក្នុងសវនាការវគ្គដំបូងនេះនៅផ្នែកណាមួយដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះផងដែរ។

ដោយពិចារណានូវអ្វីដែលយើងពិចារណានៅទីនេះ ពាក់ព័ន្ធទៅនឹងភាពពាក់ព័ន្ធនៃឯកសារ យើង

អាចសង្ឃឹមថា យើងនឹងឃើញមានការជំទាស់ពីមេធាវីការពារក្តី លើកឡើងចំពោះបញ្ហានេះ ដើម្បីការជំទាស់ចំពោះការបញ្ចូលធាតុផ្សំបរិបទនានា ដែលវាពាក់ព័ន្ធទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងរយៈកាលនេះ និងការបញ្ចូលគោលនយោបាយនៃកម្ពុជាប្រជាធិបតេយ្យ។ លោក លោកស្រីចៅក្រមនឹងឮនូវការជំទាស់ដូចគ្នានេះដែលនៅក្នុងសប្តាហ៍នេះ។

[១១:៣៦:៤៨]

មេធាវីការពារក្តី នួន ជា លើកឡើងនៅក្នុងការឆ្លើយតបរបស់ខ្លួនទៅនឹងដីកាបំបែកនីតិវិធី យើងបានដាក់សំណើសុំឲ្យពិចារណាឡើងវិញ។ ជាចម្បង សុំឲ្យអង្គជំនុំជម្រះបញ្ចូលនូវទីតាំងបទល្មើសបន្ថែម ហើយមេធាវីការពារក្តីបានដាក់ចម្លើយតបទៅនឹងសំណើរបស់យើងខ្ញុំ។ នេះជាចំណុចដែលខ្ញុំដកស្រង់ចេញពីចម្លើយតបនោះ គឺឯកសារឆ្លើយតបនោះ គឺ E124/5 កថាខណ្ឌ៣ គឺខ្ញុំសូមលើកឡើងចំណុចដែលពាក់ព័ន្ធមួយពីចម្លើយតបនោះ។ ខ្ញុំដកស្រង់សម្តីមេធាវីការពារក្តី៖ "មេធាវីការពារក្តីជំរុញឲ្យអង្គជំនុំជម្រះរក្សាជំហររបស់ខ្លួនចំពោះដីកាបំបែកដំណើរការនីតិវិធីដោយមិនពិចារណានូវអ្វីផ្សេងទៀតដែលលេចចេញពី អ.វ.ត.ក នេះ"។ ដូច្នេះ នេះគឺវាពាក់ព័ន្ធទៅនឹងការរៀបចំសវនាការជំនុំជម្រះ។ ដូចគ្នានេះដែរ មេធាវីការពារក្តី អៀង សារី ក៏បានគាំទ្រវិធីសាស្ត្ររបស់អង្គជំនុំជម្រះផងដែរ។

[១១:៣៨:១៣]

នៅពេលតវ៉ាអះអាងអំពីយុត្តិសាស្ត្រអន្តរជាតិ ពាក់ព័ន្ធទៅនឹងការបំបែកនីតិវិធីថា វាពាក់ព័ន្ធ ឬមិនពាក់ព័ន្ធនោះនៅក្នុងរឿងក្តី វ៉ាឌិក ដែលជាកម្មវត្ថុនៃសេចក្តីសម្រេចចំពោះដីកាបំបែកកិច្ចដំណើរការនីតិវិធីនោះ ក្រុមមេធាវីការពារក្តី អៀង សារី បានលើកឡើងថា ខុសពីរឿងក្តីហ្នឹង សំណុំរឿង០០២ មិនមានសហឧក្រិដ្ឋកម្មរួមនោះទេ សំណុំរឿង០០២ មានបញ្ហាពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋកម្មរួម។ ខ្ញុំអានចេញពីកថាខណ្ឌ៣ នៃឯកសារ E124/6។ មេធាវីការពារក្តក៏បានលើកឡើងផងដែរនៅក្នុងកថាខណ្ឌ១៤ ខ្ញុំសូមលើកឡើងនៅសម្តីនោះ៖ "ការបោះចោល ការច្រានចោលផ្នែកនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺវាផ្ទុយទៅនឹងគោលការណ៍ច្បាប់ស៊ីវិលឡក្នុងការស្វែងរកការពិត។ ការបំបែកតាមវិធាន៨៤ ស្ទួនពីរ គឺបានន័យថា ជនជាប់ចោទនឹងធ្វើការប្រឈមទៅនឹងការចោទកាន់នានាទៅលើបទចោទទាំងឡាយដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ"។ អង្គជំនុំជម្រះបានយល់រួចមកហើយទៅលើវិធីសាស្ត្រដែលខ្លួនបានព្យាយាមបញ្ជាក់បំភ្លឺ។ យើងឃើញមានការយោងទៅលើទស្សនទានដែលថាសហឧក្រិដ្ឋកម្មរួម គឺជាសហឧក្រិដ្ឋកម្មរួមមួយតែមួយតែប៉ុណ្ណោះ។

លោក លោកស្រីចៅក្រមអាចពិនិត្យមើលទៅលើកថាខណ្ឌ១៧ និងកថាខណ្ឌ១៨ នៃឯកសារដដែលនោះ។ ចំណុចដែលមេធាវីការពារក្តី អៀង សារី បានលើកឡើងនោះ គឺដីកាបំបែកសំណុំរឿង គឺមិនមែនបន្ថយវិសាលភាពនៃសំណុំរឿងនោះឡើយ គឺដើម្បីរៀបចំលំដាប់លំដោយនៃបទចោទដែលត្រូវយកមកដេញដោលតែប៉ុណ្ណោះ។ សំខាន់ណាស់ដែលយើងត្រូវដឹងថា ក្រុមមេធាវីការពារក្តី នួន ជា និង អៀង សារី បានគាំទ្រទៅលើវិធីសាស្ត្របំបែកកិច្ចដំណើរការនីតិវិធីនេះ។

លោក លោកស្រីចៅក្រម ជាទីគោរព បានផ្តល់បំភ្លឺបញ្ជាក់រួចមកហើយទៅលើសំណើរបស់យើងខ្ញុំសុំឲ្យពិចារណាឡើងវិញ ទៅលើដីកាបំបែកកិច្ចដំណើរការនីតិវិធី គឺឯកសារ E124/7។ លោក លោកស្រីចៅក្រម នៅក្នុងនោះក៏បានអនុវត្តនូវសំអាងហេតុដូចគ្នា។ ខ្ញុំសូមដកស្រង់ចេញពីកថាខណ្ឌ៨ នៃឯកសាររបស់លោក អៀង សារី “គឺការដែលបំបែកសំណុំរឿងនេះ គឺបំបែកសំណុំរឿងនៃការជំនុំជម្រះទៅតាមដំណាក់កាល”។ ដូច្នេះហើយ សេចក្តីសម្រេចវគ្គដំបូងនេះ គឺផ្អែកទៅលើបទចោទដែលបានដេញដោលដំបូង។ កថាខណ្ឌ១០ អង្គជំនុំជម្រះបានបញ្ជាក់នូវការពិចារណាមួយចំនួន ដែលជំរុញឲ្យអង្គជំនុំជម្រះយកមកពិចារណានៅក្នុងពេលបំបែកកិច្ចដំណើរការនីតិវិធី ការពិចារណាស្រដៀងគ្នានេះ គឺការបំបែកវគ្គតូចៗឲ្យអាចគ្រប់គ្រងបាន ដើម្បីធ្វើយ៉ាងណាថាការជំនុំជម្រះវគ្គដំបូងនេះគឺធ្វើការពិនិត្យដេញដោលឲ្យបានហ្មត់ចត់ទៅលើបទចោទ ដែលបានចោទប្រកាន់ទៅលើជនជាប់ចោទ និងដើម្បីផ្តល់ជាមូលដ្ឋាននូវការពិនិត្យឲ្យបានហ្មត់ចត់ទៅលើបទចោទ និងអង្គហេតុដែលបានចោទប្រកាន់ទៅលើជនជាប់ចោទ នៅក្នុងការជំនុំជម្រះដំណាក់កាលក្រោយ។

[១១:៤២:២៩]

ដូច្នេះ ពាក់ព័ន្ធទៅនឹងចំណុចនេះ អង្គជំនុំជម្រះបានបញ្ជាក់បំភ្លឺក្នុងកថាខណ្ឌ១១។ អង្គជំនុំជម្រះនៅក្នុងវគ្គដំបូង គឺវគ្គដែលយើងកំពុងតែដេញដោលនេះ អង្គជំនុំជម្រះនឹងពិចារណាទៅលើតួនាទី និងការទទួលខុសត្រូវរបស់ជនជាប់ចោទ ពាក់ព័ន្ធទៅនឹងគោលនយោបាយ ដែលពាក់ព័ន្ធទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូល។ ដូច្នេះ អង្គជំនុំជម្រះក៏បានបញ្ជាក់ផងដែរថា ការពិចារណាអង្គហេតុលម្អិតនៅក្នុងវគ្គដំបូងនេះ គឺនឹងធ្វើឡើងទៅលើការអនុវត្តសហឧក្រិដ្ឋកម្មរួម ដែលវាពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ។ ក៏ប៉ុន្តែអង្គជំនុំជម្រះក៏បានបញ្ជាក់ផងដែរ សវនាការវគ្គដំបូងនេះ គឺជាមូលដ្ឋានមួយ និងជាការបង្ហាញនូវភស្តុតាងពាក់ព័ន្ធទៅនឹងរយៈកាលទាំងមូល។

[១១:៤៣:២៥]

នៅក្នុងកថាខណ្ឌ១២ នៃសេចក្តីសម្រេចដដែល អង្គជំនុំជម្រះបានលើកឡើងថា ខ្លួនមិនបានដកចេញនូវលទ្ធភាពក្នុងការបញ្ចូលបទចោទបន្ថែមនោះទេ។ យើងខ្ញុំសូមលើកឡើងថា នេះមានន័យថា អង្គជំនុំជម្រះអាចធ្វើការបញ្ចូលបាន ក្នុងករណីដែលអង្គជំនុំជម្រះស្តាប់នូវភស្តុតាងដែលបានជំទាស់ទៅនឹងរចនាសម្ព័ន្ធ និងប្រព័ន្ធទំនាក់ទំនងនៃកម្ពុជាប្រជាធិបតេយ្យ។ ចំណុចនេះ គឺនឹងអាចឲ្យបញ្ចូលនូវទីតាំងបទល្មើសបន្ថែមបាន។ ដូច្នេះ អ្វីដែលយើងយល់ពីវិធីសាស្ត្ររបស់អង្គជំនុំជម្រះ អង្គជំនុំជម្រះប្រើវគ្គសវនាការដំបូងនេះ ជាមូលដ្ឋានសម្រាប់សវនាការវគ្គបន្ទាប់ទៀត។

ដូច្នេះជាការចាប់អារម្មណ៍ គឺយើងបានជំទាស់ទៅនឹងវិធីសាស្ត្រនេះ ហើយមេធាវីការពារក្តីទាំងអស់បានគាំទ្រទៅលើវិធីសាស្ត្ររបស់អង្គជំនុំជម្រះ។ វិធីសាស្ត្ររបស់អង្គជំនុំជម្រះ គឺទាមទារឲ្យជនជាប់ចោទឆ្លើយតបទៅនឹងបទចោទទាំងអស់។ ដូច្នេះហើយទើបអង្គជំនុំជម្រះបានបង្គាប់ឲ្យយើងធ្វើសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់ទៅលើបទចោទទាំងអស់ ដែលមាននៅក្នុងដីការបញ្ជូនរឿងទៅជំនុំជម្រះ។ វិធីសាស្ត្ររបស់អង្គជំនុំជម្រះ គឺក៏ចង់បញ្ចូលនូវទីតាំង នូវបទល្មើសបន្ថែមផងដែរ ដែលអង្គជំនុំជម្រះបានចែងនៅក្នុងដីកាសម្រេចរបស់ខ្លួន។

[១១:៤៥:00]

ដូច្នេះ រចនាសម្ព័ន្ធនេះគឺមិនពាក់ព័ន្ធទៅនឹងឯកសារប៉ុណ្ណោះនោះទេ គឺវាក៏ពាក់ព័ន្ធទៅនឹងសាក្សីផងដែរ ដែលអង្គជំនុំជម្រះបានជ្រើសរើសសាក្សីទាំងអស់នោះ។ ដូច្នេះ គឺយើងបានស្តាប់ឮការជំទាស់ពីខាងមេធាវីការពារក្តី ពាក់ព័ន្ធទៅនឹងការជ្រើសរើសសាក្សីដោយអង្គជំនុំជម្រះ។ ជាថ្មីម្តងទៀត យើងអាចគិតឃើញថា សាក្សីដែលកោះហៅមកផ្តល់សក្ខីកម្មទៅលើរចនាសម្ព័ន្ធ និងប្រតិបត្តិការនៃកម្ពុជាប្រជាធិបតេយ្យនោះ គឺអាចមានការជំទាស់ដោយក្រុមមេធាវីការពាក្តី ប្រសិនបើជំហររបស់ពួកគេផ្តោតលើតែការផ្លាស់ទីលំនៅដោយបង្ខំតែប៉ុណ្ណោះនោះ។ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការដែលបានរៀបចំឡើងនោះ បានបញ្ជាក់ច្បាស់រួចមកហើយ យើងអាចចំណាយពេលនៅក្នុងឆ្នាំនេះស្តាប់ទៅលើសក្ខីកម្ម និងភស្តុតាង គឺសក្ខីកម្ម និងភស្តុតាងដែលពាក់ព័ន្ធជាចម្បងទៅនឹងរចនាសម្ព័ន្ធនៃរបប គោលនយោបាយ និងរចនា ទំនាក់ទំនង ក៏ដូចជាស្តាប់ទៅលើភស្តុតាងសក្ខីកម្ម ពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទដែលមានចោទប្រកាន់ នៅក្នុងបទល្មើសនៃការផ្លាស់ទីលំនៅដោយបង្ខំ។

[១១:៤៦:២៤]

ដូចគ្នានេះផងដែរ យើងអាចកត់សម្គាល់ឃើញថាក្រសួងដែលយើងនឹងស្តាប់ភស្តុតាងនានានោះ

គឺបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៧៦ ក្រោយពេលដែលបទល្មើសបានបញ្ចូលនៅក្នុងដីការបស់យើង។ ដូច្នេះបានន័យថា របបនេះគឺវាបង្កើតក្រសួងជាចម្បងនៅក្នុងខែមករា ឆ្នាំ១៩៧៦ ទៅតាមភាពចាំបាច់។ ដូច្នេះ វាពាក់ព័ន្ធទៅនឹងបញ្ហានានាដែលវាកើតឡើងក្រោយពីហេតុការណ៍ ឬក៏អង្គហេតុដែលយើងបានចោទប្រកាន់។ យើងឃើញមានសាក្សីចំនួន៥២ ដែលបានលើកឡើងអំពីបរិបទទាំងអស់នេះ។ ដូច្នេះ យើងខ្ញុំសូមបញ្ជាក់ថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងឯកសារ គួរតែអនុវត្តទៅតាមលក្ខណៈជាក់ស្តែង ទៅតាមដីកាបំបែកសំណុំរឿង។

[១១:៤៧:៣៦]

លោក លោកស្រីចៅក្រមបានចងចាំរួចមកហើយ បញ្ជីរបស់យើងដាក់មុនពេលបំបែកដំណើរការនីតិវិធី ហើយអង្គជំនុំជម្រះបានស្នើសុំឱ្យភាគីកែប្រែនូវបញ្ជីរបស់ខ្លួន។ អង្គជំនុំជម្រះបានបង្គាប់ថា បញ្ហាបរិបទនោះ គឺជាផ្នែកនៃសវនាការវគ្គដំបូង។ ដូច្នេះ វាមិនមែនពាក់ព័ន្ធទៅនឹងបញ្ហាភាពពាក់ព័ន្ធនៃឯកសារទាំងអស់នេះទេ គឺវាពាក់ព័ន្ធទៅនឹងខ្លឹមសារដែលបង្ហាញអំពីបទល្មើស ដោយយើងមិនទាន់គិតអំពីវិធីសាស្ត្ររបស់អង្គជំនុំជម្រះនោះទេ។

[១១:៤៨:២៤]

យើងគឺមានបន្ទុកក្នុងការបង្ហាញភស្តុតាងអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលថាមានការវាយប្រហារដោយទូលំទូលាយ និងប្រព័ន្ធដែលបទល្មើសទាំងអស់នេះបានប្រព្រឹត្តឡើង។ ធាតុទាំងអស់នេះហើយដែលយើងបង្ហាញឱ្យឃើញនៅក្នុងកថាខណ្ឌ១៣៥២ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលើកឡើងថា ការវាយប្រហារដោយប្រព័ន្ធ និងដោយទូទៅធ្វើឡើងដោយ-- ចំពោះប្រជាជនកម្ពុជា។ ការលើកឡើងរបស់មេធាវីការពារក្តី អៀង សារី គឺយើងខ្ញុំសូមបញ្ជាក់ថា យើងមិនអាចដកចេញនូវសហឧក្រិដ្ឋកម្មរួមនោះទេ ដែលថាឧក្រិដ្ឋកម្មនេះបានធ្វើឡើងគោលដៅចំពោះប្រជាជនកម្ពុជា ហើយបានធ្វើឡើងនិងប្រព្រឹត្តឡើងនៅក្នុងរយៈកាលដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[១១:៤៩:២១]

បញ្ហាមួយចំនួនដែលយើងត្រូវតែបង្ហាញនូវភស្តុតាងដើម្បីឱ្យហួសពីមតិសង្ស័យថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានប្រព្រឹត្តឡើងនោះ គឺយើងត្រូវបង្ហាញអំពីលក្ខណៈវាយប្រហារជាទូទៅ និងជាប្រព័ន្ធទៅលើប្រជាជនស៊ីវិល ហើយត្រូវបង្ហាញថាការវាយប្រហារជាទូទៅ និងជាប្រព័ន្ធត្រូវតែបង្ហាញឱ្យឃើញដោយយោងទៅលើភស្តុតាង ដែលបង្ហាញអំពីអំពើដែលប្រព្រឹត្តឡើងក្នុងរយៈកាលនោះទាំង

មូល និងនៅដែលបានប្រព្រឹត្តឡើងនៅប្រទេសនេះស្ទើរតែគ្រប់កន្លែង។ យើងមិនបង្ហាញអំពីបទល្មើសតែប៉ុណ្ណោះទេ យើងត្រូវបង្ហាញអំពីការវាយប្រហារជាទូទៅ និងជាប្រព័ន្ធដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនោះ ហើយនិងប្រព្រឹត្តនៅលើទីតាំងដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ទឡ្ហីករណ៍ដូចគ្នានេះដែរ ដូចដែលខ្ញុំលើកឡើង ក៏យើងសុំលើកឡើងចំពោះ នូវបទល្មើសផ្សេងទៀតផងដែរ។ ការដែលចោទប្រកាន់ចំពោះសហឧក្រិដ្ឋកម្មរួមនោះ អង្គជំនុំជម្រះបានបញ្ចូលទៅក្នុងវគ្គសវនាការដំបូងនេះ គឺបញ្ចូលនូវកថាខណ្ឌដែលពាក់ព័ន្ធទៅនឹងអត្ថិភាព និងវិសាលភាពនៃសហឧក្រិដ្ឋកម្មរួម។ យើងឃើញមាននៅក្នុងកថាខណ្ឌ គឺសហឧក្រិដ្ឋកម្មរួមនេះ ឃើញមាននៅក្នុងកថាខណ្ឌ១៥៦ ដល់ ១៥៩ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ អង្គជំនុំជម្រះបានបញ្ជាក់រួចមកហើយថា ការអនុវត្តសហឧក្រិដ្ឋកម្មរួម គឺតម្រូវឲ្យពាក់ព័ន្ធទៅនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ។ ក៏ប៉ុន្តែសហឧក្រិដ្ឋកម្មរួមនេះ គឺជាផ្នែកមួយនៃសហឧក្រិដ្ឋរួមទាំងមូល។

[១១:៥១:១៦]

នៅកថាខណ្ឌ១៥៧ ក្នុងនោះមានចែងគោលនយោបាយចំនួនប្រាំ។ ទី១) គឺការជម្លៀសប្រជាជនម្តងហើយម្តងទៀត។ ទី២) ការបង្កើតសហករណ៍និងទីតាំងធ្វើការ។ ទី៣) ការអប់រំសមាសភាពមិនល្អ និងការសម្លាប់ខ្មាំង។ ទី៤) ការគោលដៅទៅលើក្រុមជាក់លាក់។ ទី៥) គឺការរៀបចំនូវអាពាហ៍ពិពាហ៍។ ដូច្នេះ ដូចទៅនឹងការវាយប្រហារដោយបង្ខំ និង-- ការវាយប្រហារជាទូទៅនិងដោយប្រព័ន្ធសហឧក្រិដ្ឋកម្មរួម គឺវាបានកើតឡើងនៅក្នុងឆ្នាំ១៩៧៥ ហើយបន្តប្រព្រឹត្តឡើងនៅក្នុងរយៈកាលដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[១១:៥២:០៣]

កថាខណ្ឌ១៥៨ ដែលជាផ្នែកមួយនៃការជំនុំជម្រះវគ្គដំបូង កថាខណ្ឌនោះគឺបានលើកឡើង អំពីគោលនយោបាយ ដែលពាក់ព័ន្ធទៅនឹងការកើនឡើងនូវវិសាលភាពនៃការប្រព្រឹត្តបទល្មើសនៅក្នុងរបបនោះ។

យើងខ្ញុំសូមលើកឡើងថា អ្វីដែលមេធាវីការពារក្តីព្យាយាមធ្វើនេះ គឺព្យាយាមចងដៃរបស់យើងកុំឲ្យយើងបង្ហាញភស្តុតាងឲ្យបានគ្រប់គ្រាន់ បង្ហាញអំពីអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម ដែលសហឧក្រិដ្ឋកម្មរួមនេះ គឺវាមានវិសាលភាពធំធេងណាស់ដែលបានប្រព្រឹត្តឡើង។ ដូច្នេះហើយភស្តុតាងទាំងអស់គឺវាមានច្រើន។ រឿងក្តីនេះក៏វាមិនពាក់ព័ន្ធទៅនឹងការជម្លៀសដោយបង្ខំ ការផ្លាស់ទីលំនៅដោយបង្ខំ

នោះផងដែរ។ វាមានលក្ខណៈស្មុគស្មាញពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋកម្មរួម។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់លាស់ថា យើងខ្ញុំមិនស្នើឡើងថា យើងព្យាយាមបង្ហាញបទល្មើសតែទៅលើទីតាំងចម្បងនៃបទល្មើសនោះទេ យើងអនុវត្តទៅការបង្គាប់របស់អង្គជំនុំជម្រះ។ ក៏ប៉ុន្តែធ្វើយ៉ាងណា យើងខ្ញុំត្រូវតែបង្ហាញឲ្យឃើញនូវការវាយប្រហារដោយទូលំទូលាយនិងដោយប្រព័ន្ធ ហើយនិងអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម។ យើងធ្វើដូច្នេះតាមរយៈបញ្ចូលឯកសារជាច្រើនដែលឆ្លុះបញ្ចាំងនូវអត្ថិភាពនៃគោលនយោបាយ និងការវាយប្រហារទៅលើប្រជាជនស៊ីវិល។

[១១:៥៣:៤១]

យើងឃើញមានវិធីមួយទៀត ដែលយើងអាចធ្វើការពិនិត្យមើលទៅលើភាពពាក់ព័ន្ធនៃឯកសារនៅពេលដែលយើងពិចារណាអំពីគោលនយោបាយចំនួនប្រាំ។ ដូចដែលខ្ញុំបានបញ្ជាក់អ៊ីចឹង ដែលថាវាជាផ្នែកមួយនៃសហឧក្រិដ្ឋកម្មរួម។ មេធាវីការពារក្ដីលើកឡើងដោយត្រឹមត្រូវបញ្ជាក់ថា វាជាសហឧក្រិដ្ឋកម្មរួមមួយសំខាន់។ ជាការពិត ភស្តុតាងដែលបង្ហាញតាមការសន្និដ្ឋានរបស់យើងខ្ញុំនោះ គឺផ្នែកនៃសហឧក្រិដ្ឋកម្មរួម ជាការពិតទៅ គឺវាមានភាពពាក់ព័ន្ធគ្នាទៅវិញទៅមក។ ខ្ញុំសូមផ្ដល់ឧទាហរណ៍ដោយត្រង់ៗ ថាតើគោលនយោបាយទាំងអស់នេះ គឺវាពាក់ព័ន្ធគ្នាយ៉ាងម៉េច? ហើយវាសំខាន់យ៉ាងម៉េចដើម្បីឲ្យយើងយល់ពេញលេញទៅគោលនយោបាយទាំងប្រាំ ហើយអាចឲ្យយើងយល់អំពីឧក្រិដ្ឋកម្មជាក់លាក់ គឺការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ។ ខ្ញុំនឹងអានដោយសង្ខេបចេញពីឯកសារ D199/26.2.35។

លោកប្រធាន ខ្ញុំសូមអនុញ្ញាតធ្វើការបង្ហាញនូវឯកសារនេះតាមអេក្រង់ ដើម្បីឲ្យយើងអាចតាមដានទាំងអស់គ្នា គឺឯកសារ D199/26.2.35។ តើអាចដែរឬទេលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបញ្ជាក់ថា ឯកសារនេះ គឺសុន្ទរកថាធ្វើឡើងដោយ ប៉ុល ពត នៅប៉េកាំង ថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៧៧។ នៅក្នុងសុន្ទរកថានោះ ប៉ុល ពត លើកឡើងអំពីចំណុចដែលសំខាន់ ពិចារណាទៅលើការជម្លៀសប្រជាជននៅដើមឆ្នាំ១៩៧៥។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតបញ្ចាំងឯកសារនេះនៅលើអេក្រង់។

[១១:៥៦:១៦]

*(មានបញ្ហាបច្ចេកទេស)*

ប្រហែលជាបញ្ហាបច្ចេកទេស ដូច្នេះហើយ គឺខ្ញុំសូមអានចេញពីឯកសារនេះ។ ERN ជាភាសាអង់គ្លេស 00390921។ ខ្មែរ គឺ00633021។ បារាំង គឺ00602498។ គឺមានដំណកស្រង់ដូចតទៅ៖

"កត្តាមួយដើម្បីជោគជ័យនៃបដិវត្តន៍នៅក្នុងប្រទេសកម្ពុជា គឺការជម្លៀសប្រជាជននៅក្នុងក្រុងទៅតាមទីជនបទ។ គេបានសម្រេចនៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៥ ដោយសារតែយើងដឹងថា មុនពេលការបំផ្លិចបំផ្លាញនេះ គឺកងកម្លាំងរបស់យើងមិនមាំនោះទេក្នុងការការពារបដិវត្តន៍របស់យើង"។ ហើយបន្ទាប់មកលើកឡើងទៀតថា ខ្ញុំសូមអភ័យទោសដែលថារូបភាពនេះមិនច្បាស់ "ភ្នាក់ងារសម្ងាត់របស់ខ្មាំង គឺមានសភាពទាបណាស់នៅប្រទេសរបស់យើង។ ក៏ប៉ុន្តែនៅពេលដែលយើងបំផ្លាញពួកគេ វាពិបាកសម្រាប់ពួកគេក្នុងការធ្វើការប្រយុទ្ធជាមួយនឹងយើង។ កងកម្លាំងរបស់យើង គឺមាននៅគ្រប់ទីកន្លែងនៅតាមសហករណ៍។ យើងមានគំនិតផ្តួចផ្តើមនៅក្នុងដៃរបស់យើង ខ្មាំងគឺមិនប៉ានវាយយើងពីខាងក្រៅនោះទេ"។

[១១:៥៨:១១]

យើងខ្ញុំសូមបញ្ជាក់ថា នៅក្នុងចំណុចនេះ គឺយើងឃើញមានភាពពាក់ព័ន្ធរវាងគោលនយោបាយទៅលើខ្មាំង សេចក្តីសម្រេចនៃការជម្លៀសប្រជាជននៅក្នុងក្រុងទៅតាមទីជនបទ និងការប្រើប្រាស់សហករណ៍ដើម្បីធ្វើការដាក់ប្រជាជនឲ្យទៅជាទាសករ។ អ្វីដែលសំខាន់ និងគួរកត់សម្គាល់នោះ គឺយើងឃើញមានការចង្អុលយោងទៅលើហេតុផលនានា នៅពីក្រោយការជម្លៀសប្រជាជន។

ចំណុចមួយគាំទ្រទៅលើចំណុចនេះ គឺមាននៅក្នុងឯកសារ D213.2 ឯកសារ E3/16 ERN ពាក់ព័ន្ធ អង់គ្លេស គឺ00498300។ ខ្មែរERN គឺ0038093(ស៊ីក) ដល់ 94។ បារាំង គឺ0064397(ស៊ីក)។ ដោយសារតែពេលវេលាខ្ញុំនឹងអានដោយខ្លីនោះទេ។

ផ្នែកដែលមាននៅក្នុងសៀវភៅរបស់លោក ខៀវ សំផន ដែលលោក ខៀវ សំផន បានពិចារណាអំពីការជម្លៀសប្រជាជននៅក្នុងក្រុងផងដែរ។ គាត់បានលើកឡើងនៅចំណុចដែលបានលើកឡើងដោយអ្នកស្រាវជ្រាវ។ លោកបានលើកឡើងថា "គេចោទប្រកាន់ទៅលើ ប៉ុល ពត អំពីការជម្លៀសប្រជាជននៅក្នុងទីក្រុងភ្នំពេញ ហើយនិងនៅតាមទីកន្លែងផ្សេងៗ។ ការចោទប្រកាន់ទាំងអស់នេះ នៅពេលដែលគេចោទប្រកាន់ទាំងអស់នេះ គេមិនដឹងអំពីអំពើហិង្សាដែលបានធ្វើឡើង និងដែលមានចំពោះអាជ្ញាធរ

និងអំណាចរបស់រដ្ឋ”។ លោក ខៀវ សំផន បានបន្តលើកឡើងអំពីបញ្ហាការអត់ឃ្លាននៅក្នុងទីក្រុង។ គាត់បានលើកឡើងថា “បញ្ហាដែលវានាំទៅដល់គ្រោះថ្នាក់ទៅលើអំណាចរដ្ឋក្មេងខ្ចីនេះ គឺយើងឃើញថា ប្រជាជនរាប់ម៉ឺននាក់បានស្លាប់រួចមកហើយ។ គឺបានន័យថា វាបន្តកាប់-- បន្តធ្វើឲ្យមនុស្សទាំងអស់នេះ ស្លាប់ពីមួយទៅមួយ។ ដូច្នេះហើយ វាអាចឲ្យភ្នាក់ងារ សេ.អ៊ី.អា ធ្វើការបំផ្លិចបំផ្លាញ រួមជាមួយនឹង កងកម្លាំង លន់ នល់ ធ្វើការបំផ្លិចបំផ្លាញយើង”។ នៅចំណុចខាងក្រោម គាត់និយាយថា “គ្រោះថ្នាក់ ដែលសំខាន់នោះ គឺការបះបោរដែលនឹងកើតឡើង ហើយបង្កើតឱកាសទៅដល់វៀតណាមធ្វើការ អន្តរាគមន៍ពីខាងក្រៅ ហើយរឹបអូសប្រទេសកម្ពុជាពីអាមេរិកាំង ក្រោមលេសថា មកជួយយើង។ នៅពេលនោះ ពេញចិត្ត ឬក៏មិនពេញចិត្ត សេ.អ៊ី.អា និងកុម្មុយនីស្តវៀតណាម នឹងបន្តរួមដៃគ្នាសម្លាប់ អំណាចរបស់រដ្ឋដែលក្មេងខ្ចីនេះ”។

នេះគឺអ្វីដែល ប៉ុល ពត និង ខៀវ សំផន បានលើកឡើងអំពីភាពពាក់ព័ន្ធក្នុងការជម្លៀសប្រជាជន និងការមើលឃើញអំពីគ្រោះថ្នាក់ពីខ្មាំងដែលត្រូវតែចាត់វិធានការទៅលើពួកគេ។

លោក លោកស្រីចៅក្រម ខ្ញុំគិតថា ខ្ញុំគួរតែឈប់នៅត្រឹមនេះសិន ហើយខ្ញុំនឹងបន្តទៀតនៅក្រោយពេលដែលយើងឈប់សម្រាក។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ពេលវេលាសមល្មមនឹងសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ កិច្ចដំណើរការសវនាការនឹងចាប់ផ្តើមចូលវិញនៅរសៀលនេះ ចាប់ផ្តើមពីម៉ោងមួយកន្លះ។

សូមអញ្ជើញលោកមេធាវី!

[១២:០២:១១]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ អរុណសួស្តី ខ្ញុំសូមលើកឡើងដោយខ្លី លោក នួន ជា សូមដកខ្លួននៅក្នុងរសៀលនេះ សូមទៅបន្ទប់រង់ចាំខាងក្រោមតាមដាននីតិវិធីវិញ។ យើងខ្ញុំបានរៀបចំឯកសាររបស់យើងខ្ញុំរួចហើយ យើងខ្ញុំនឹងដាក់ជូនក្រឡាបញ្ជីនៅពេលខាងមុខឆាប់ៗនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោកមេធាវី។ បានស្តាប់សំណើសុំជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាម

រយៈមេធាវីការពារក្ដីរបស់គាត់ សុំមិនចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ នៅរសៀលនេះ ដោយបន្តទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍នៅបន្ទប់ខាងក្រោមបន្ទប់សវនាការនេះ ដោយមូលហេតុសុខភាពមិនអាចអង្គុយស្ដាប់កិច្ចដំណើរការសវនាការបាន។ ដោយសារសន្យាថានឹងប្រគល់មកឱ្យអង្គជំនុំជម្រះនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ដោយមានហត្ថលេខា ឬក៏ផ្ដិតស្នាមម្រាមដៃជនជាប់ចោទជាក់ច្បាស់។ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ ដែលធ្វើឡើងតាមរយៈមេធាវីរបស់ខ្លួន ក្នុងការលះបង់សិទ្ធិក្នុងការចូលរួមកិច្ចដំណើរការដោយផ្ទាល់នៅរសៀលនេះ ហើយតាមដានកិច្ចដំណើរការសវនាការពីចម្ងាយនៅបន្ទប់ខាងក្រោម ដែលមានបំពាក់ដោយឧបករណ៍សោតទស្សន៍។

[១២:០៣:៤០]

ហើយក្រុមមេធាវីត្រូវប្រគល់មកឱ្យអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិ ដែលបានរៀបចំរួចហើយនោះ ហើយនិងបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងពីររូបទៅបន្ទប់រង់ចាំខាងក្រោមហើយរសៀលនេះ បង្គាប់ឱ្យនាំខ្លួនជនជាប់ចោទ ខៀវ សំផន ឡើងមកកាន់សាលសវនាការ។ ដោយឡែក នួន ជា គឺទុកឱ្យគាត់បន្តការតាមដានកិច្ចដំណើរការសវនាការនៅបន្ទប់សម្រាប់គាត់ ដែលមានឧបករណ៍រៀបចំឧបករណ៍សោតទស្សន៍សម្រាប់គាត់រួចហើយ។ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់នូវប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ តាមដានកិច្ចដំណើរការសវនាការពីចម្ងាយហើយសម្រាប់ពេញមួយរសៀលនេះ។

សូមសម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៤នាទី ដល់ម៉ោង ១៣:៣២នាទី)*

[១៣:៣២:១៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ជាបន្តទៅនេះ អង្គជំនុំជម្រះសូម

ផ្តល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ក្នុងការធ្វើសេចក្តីឆ្លើយតបទៅនឹងសេចក្តីជំទាស់លើឯកសាររបស់ក្រុមមេធាវីការពារក្តីជាបន្ត។

សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីកៈ**

សូមអរគុណ លោកប្រធាន! សូមគោរពលោក លោកស្រីចៅក្រម!

ខ្ញុំនឹង-- យើងខ្ញុំនឹងបន្តការឆ្លើយតបរបស់យើងទៅតាមប្រធានបទនីមួយៗ។ មុននឹងយើងខ្ញុំចាប់ផ្តើមទៅតាមប្រធានបទនីមួយៗនេះ ខ្ញុំសូមឈានចូលទៅដល់សេចក្តីសន្និដ្ឋាននៃការ-- នៃសំណើសុំរបស់ខ្ញុំ។ យើងខ្ញុំស្នើសុំថា គឺបញ្ហាពាក់ព័ន្ធទៅនឹងវិសាលភាពនៃសហឧក្រិដ្ឋកម្មរួម និងការវាយប្រហារជាប្រព័ន្ធ ដែលជាផ្នែកមួយនៃរឿងក្តីនេះ ហើយនិងឯកសារមួយចំនួនធំទៀត។

[១៣:៣៤:០២]

មុននឹងយើងខ្ញុំលើកឡើងពីបញ្ហាដែលពាក់ព័ន្ធនេះ សហការីរបស់ខ្ញុំបានបញ្ជាក់ពីខាងដើមហើយថាលក្ខខណ្ឌគតិយុត្តិ គឺមានលក្ខណៈខុសគ្នារវាងយើងខ្ញុំហើយនិងមេធាវីការពារក្តី។ ឧទាហរណ៍ប្រសិនណាវាពាក់ព័ន្ធទៅនឹងលក្ខខណ្ឌគតិយុត្តិនោះ ឧទាហរណ៍៖ នៅក្នុងឯកសារ E1144 ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១១ ក្រុមមេធាវីការពារក្តី អៀង សារី លើកឡើងនូវលក្ខខណ្ឌគតិយុត្តិដែលពាក់ព័ន្ធដែលជាទូទៅគឺថា វាស៊ីសង្វាក់គ្នាជាមួយខាងយើងខ្ញុំ គឺភាពពាក់ព័ន្ធនេះត្រូវបានកំណត់ថា ភស្តុតាងដែលបង្ហាញ ឬមិនអាចបង្ហាញទៅដល់ឯកសារជាភស្តុតាងណាមួយនោះ គឺវាអាចនឹងមានអត្ថិភាពតិចឬច្រើនទៅលើអង្គហេតុទាំងនោះ។ យើងខ្ញុំក៏បានលើកឡើងពីខាងមុខសម្រាកផងដែរ ថាសហឧក្រិដ្ឋ-កម្មរួម គឺស្ថិតនៅក្នុងយុត្តាធិការនៃប្រទេសកម្ពុជាពីឆ្នាំ៧៥ ចន្លោះ៧៥ ទៅ៧៩។ ហើយដែល វាជា-- ដោយសារវាជាអត្ថិភាពនៃការវាយប្រហារជាប្រព័ន្ធ។ ហើយមេធាវីការពារក្តីក៏បានជំទាស់ទៅលើបញ្ហានេះ ដូច្នេះ នៅក្នុងសំណើសុំរបស់យើងខ្ញុំទៅលើបញ្ហាដែលពាក់ព័ន្ធនេះ គឺថាភស្តុតាងត្រូវតែមានភាពពាក់ព័ន្ធគ្នា ប្រសិនណាជាត្រូវការគាំទ្រទៅដល់អង្គហេតុ-- ទៅដល់គោលនយោបាយ ទាំងប្រាំនេះ ហើយនិងសហឧក្រិដ្ឋកម្មរួម។

យើងខ្ញុំមិនចង់ចូលទៅដល់បញ្ហាពាក់ព័ន្ធទៅនឹងផ្នែកមួយរបស់មេធាវីការពារក្តី ដែលជាចេតនាក្នុងការកម្រិតនៅក្នុងការពិនិត្យទៅលើឯកសារនៅក្នុងសវនាការនេះនោះទេ។ ហើយទាក់ទងទៅនឹងដីកាបំបែកដំណើរការនីតិវិធី ដីកាបំបែកដំណើរការនីតិវិធីនោះ ហើយដែលវាជាផ្នែកមួយនៃសំណុំរឿង០០២

នេះ។ យើងខ្ញុំសូមលើកឡើងថា យើងខ្ញុំសូមលើកឡើងទៅដល់ឯកសារយោង នៅចំពោះមុខតុលាការទាក់ទងទៅនឹងបទល្មើសដែលប៉ះពាល់ទៅដល់អាយុជីវិតមនុស្សរាប់លាននាក់។

[១៣:៣៧:០២]

យើងខ្ញុំសូមស្នើសុំឲ្យសហការី-- សូមមេធាវីការពារក្តីគឺថាកុំលើកឡើងនូវបញ្ហានេះ។ នេះមិនមែនបញ្ជាក់ទៅដល់វិសាលភាព ហើយនិងភាពស្មុគស្មាញនៃរឿងក្តីមួយនេះទេ។ ខ្ញុំសូមចូលទៅដល់បញ្ហាដើម ជាសង្ខេបទេ ដូចសហការីខ្ញុំបានលើកឡើងខាងដើមហើយ ហើយអង្គជំនុំជម្រះបានសម្រេចថា មិនមានលក្ខខណ្ឌតម្រូវ ដែលត្រូវឲ្យបង្ហាញនូវឯកសារដើម ដើម្បីឲ្យទទួលយកនូវឯកសារទាំងនេះនោះបាននោះទេ។ ហើយនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ គឺមានឯកសារយោងទៅលើឯកសារដើមពីរ។ ហើយសហការីរបស់ខ្ញុំក៏បានយោងទៅលើឯកសារមួយចំនួននៅក្នុងសំណុំរឿង ដែលមានភស្តុតាងបញ្ជាក់ថា វាជាកិច្ចការដែលធ្វើដោយសហចៅក្រមស៊ើបអង្កេតដែលបានកំណត់ និងបានស្កេននូវពីឯកសារដើម ហើយយើងខ្ញុំនឹងបង្ហាញនូវកំណត់ត្រាដែលពាក់ព័ន្ធ។

ប៉ុន្តែដើម្បីជាការកត់ត្រាឲ្យបានត្រឹមត្រូវនោះ គឺយើងខ្ញុំយោងទៅលើឯកសារ D ដែលពាក់ព័ន្ធទៅនឹង-- គឺឯកសារ D161។ ដែលពាក់ព័ន្ធទៅនឹងការប្រមូលឯកសារពីបណ្ណសារដ្ឋានជាតិ។ និងទីពីរឯកសារបីដែលទាក់ទងទៅនឹងការប្រមូលឯកសារពីមជ្ឈមណ្ឌលឯកសារកម្ពុជា និងមកពីសារមន្ទីរទួលស្លែង គឺឯកសារ D248, D82 និងD159។ ហើយប្រសិនណាជាមើលទៅលើ-- អ្នកគេទៅមើលឯកសារនេះ គឺហ្នឹងគេនឹងឃើញអំពីលេខនីមួយៗគឺមានលេខស៊េរីរបស់វា ដែលបញ្ជាក់ថា តើឯកសារទាំងអស់នេះ ត្រូវបានមករបៀបណា? តើត្រូវស្កេន ឬក៏បានមកពីការថតពីឯកសារដើម ឬក៏ថាឯកសារនេះ ត្រូវបានយកដោយរបៀបណា ដើម្បីមកដាក់នៅក្នុងសំណុំរឿងនោះ?

[១៣:៣៩:៣៩]

ហើយបន្ទាប់មក ខ្ញុំនឹងលើកឡើងការជំទាស់មួយទៀត ដែលខ្ញុំបានស្តាប់ឮពីក្រុមមេធាវីការពារទាំងបីក្រុម។ វាអាចជាលក្ខខណ្ឌវិនិច្ឆ័យពាក់ព័ន្ធទៅនឹងអំពើ ហើយនិងសកម្មភាពរបស់ជនជាប់ចោទនីមួយៗ។ ចំណុចមួយ គឺមេធាវីការពារក្តីបានលើកឡើងត្រឹមត្រូវតែមួយចំណុចនេះ គឺលក្ខណៈវិនិច្ឆ័យទាក់ទងទៅនឹងអំពើ និងសកម្មភាពរបស់ជនជាប់ចោទអាចយកមកអនុវត្តបាន តែក្នុងពេលណាដែលទទួលបាននូវចម្លើយដើម ចម្លើយដើមតែប៉ុណ្ណោះ។ ដូច្នេះ វាជាប់ពាក់ព័ន្ធទៅនឹងការដាក់ឯកសារ E96 គឺសំណើសុំរបស់ខ្ញុំនៅក្នុងឯកសារលេខ៩៦នេះបញ្ជាក់ច្បាស់ហើយថា ករណីយុត្តិសាស្ត្ររបស់តុលាការ

ព្រហ្មទណ្ឌអន្តរជាតិ គឺទាក់ទងទៅនឹងការទទួលយកចម្លើយរបស់សាក្សី ហើយខ្ញុំសូមចូលទៅដល់សេចក្តីសម្រេចមួយចំនួននៃតុលាការ អាយ.ស៊ី.ធី.វ៉ាយ គឺសាលាឧទ្ធរណ៍នៃតុលាការ អាយ.ស៊ី.ធី.វ៉ាយ និងសេចក្តីសម្រេចមួយរបស់តុលាការ អាយ.ស៊ី.ធី.អ័រ។

[១៣:៤១:០៩]

ឃ្លាដែលពាក់ព័ន្ធទៅនឹងអំពើ និងសកម្មភាពនេះ គឺអាចរកឃើញនៅក្នុងវិធាន៩២ស្ទួន នៃវិធានផ្ទៃក្នុងរបស់តុលាការ អាយ.ស៊ី.ធី.វ៉ាយ។ យើងខ្ញុំគិតថា លោក លោកស្រីចៅក្រម អាចជ្រាបអំពីវិធាននេះ។ ហើយប្រភេទនៃសក្ខីកម្មជាភស្តុតាងដែលអាចទទួលយកបាននោះ គឺត្រូវបានកត់ត្រាទៅក្នុងប្រតិចារឹក។ ជំហររបស់តុលាការ អាយ.ស៊ី.ធី.វ៉ាយ គឺស្រដៀងគ្នាទៅនឹង អ.វ.ត.ក ដែរ គឺថាមានវិធានទូទៅមួយថា ភស្តុតាងអស់អាចទទួលយកបាន ឲ្យតែភស្តុតាងនេះមានភាព មានមូលដ្ឋាននៃភាពគួរឲ្យជឿជាក់បាន។ ហើយនៅក្នុងសេចក្តីសម្រេចនេះ គឺមានចេតនាចង់ឲ្យទទួលយកមកដាក់ក្នុងសំណុំរឿងនូវចម្លើយរបស់សាក្សីនៅក្នុងដំណើរការនីតិវិធី ដោយសារថាតុលាការនេះគឺថាបានអនុវត្តនូវវិធីទាក់ទងទៅនឹងការប្រមូលនូវចម្លើយរបស់សាក្សី។ អ៊ីចឹងទម្រង់នៃចម្លើយរបស់សាក្សីដែលភាគីបានធ្វើឡើងជាមួយនឹងការទុក-- ទទួលស្គាល់ថា ដែលចម្លើយរបស់សាក្សីបែបនេះមិនអាចទទួលយកបានតែក្នុងករណីដែលវាមិនមានភាពគួរឲ្យជឿជាក់បានជាមូលដ្ឋាន គឺវិធាន៩២ស្ទួន។

[១៣:៤២:៤២]

ដូច្នេះ វិធាននេះគឺថាបានកម្រិតភាពទទួលយកបាននៃចម្លើយរបស់សាក្សី បើប្រៀបធៀបទៅនឹងប្រភេទនៃភស្តុតាងដទៃៗទៀត។ ខ្ញុំសូមដកស្រង់ជាសង្ខេបពីសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ អាយ.ស៊ី.ធី.វ៉ាយ ដែលរឿងក្តីរវាងសហព្រះរាជអាជ្ញា តទល់ជាមួយ ហ្គាលិក គឺG-A-L-I-C ជាសេចក្តីសម្រេចចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៦ ទាក់ទងទៅនឹងចម្លើយរបស់សាក្សី ហើយតុលាការបានសម្រេចថា នៅក្នុងកថាខណ្ឌ៣១។ វិធាន៣១ស្ទួន គឺជាការដែលកំណត់ឲ្យទទួលយកនូវចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សីក្រៅពីវិសាលភាពនៃវិធាន៩១(គ) ដែលមានលក្ខណៈទៅនឹងវិធាន៨៧(១)នៅទីនេះ។

[១៣:៤៣:៤៧]

នេះគឺជាបទប្បញ្ញត្តិដែលកំណត់ជាក់លាក់ពាក់ព័ន្ធទៅនឹងចម្លើយសាក្សី ដូច្នេះគេអាចនិយាយបានថា តើស្អីជាចម្លើយសាក្សី? ហើយខ្ញុំគិតថាមេធាវីការពារក្តីបានលើកឡើងនូវឯកសារមួយចំនួនធំដែលថា គួរតែចាត់ទុកថាជាចម្លើយសាក្សី គឺមានឯក-- ដោយសារមានការថតជាសំឡេង ឬក៏កត់ត្រា

ទុក។ ដូច្នេះឯកសារបែបនេះមានចរិតលក្ខណៈដូចចម្លើយរបស់សាក្សីដូច្នេះដែរ។ និយមន័យនៃពាក្យថាចម្លើយសាក្សី គឺជាកម្មវត្ថុដែលត្រូវបានលើកឡើងនៅក្នុងសេចក្ដីសម្រេចរបស់តុលាការកម្រិតអន្តរជាតិមួយចំនួន។ ហើយខ្ញុំគិតថាវាជាការត្រឹមត្រូវណាស់ វាជាដែលមានសណ្ឋានដូចគ្នា។ ប៉ុន្តែគេច្បាស់ហើយ ចម្លើយសាក្សីមិនមែនមានន័យថា ឯកសារណាដែលពាក់ព័ន្ធទៅនឹង-- គឺរាល់ឯកសារទាំងឡាយណាដែលមានពាក្យសម្ដីរបស់មនុស្សណាម្នាក់និយាយនោះទេ។

នៅក្នុងរឿងរបស់រដ្ឋអាជ្ញា តទល់ជាមួយ *ប្លាសគិក* គឺឯកសារ B-L-A-S-K-I-C សេចក្ដីសម្រេចចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០០ របស់តុលាការ អាយ.ស៊ី.ធី.វ៉ាយ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ដែលបានសម្រេចថា យើងមើលទៅលើនិយមន័យ នៃពាក្យថា ចម្លើយសាក្សី កថាខណ្ឌ១៥ សូមដក ស្រង់សម្ដី "និយមន័យធម្មតានៅក្នុងដំណើរការនីតិវិធី គឺជាការរៀបរាប់រឿងរ៉ាវទៅលើដំណើររឿង ដែលបានកើតឡើង ដោយយោងទៅតាមការស៊ើបអង្កេតនៅក្នុងរឿងក្ដីនេះ"។ ដូច្នេះ គំនិតយោបល់ នៃពាក្យថាចម្លើយសាក្សីត្រូវបានកម្រិតនៅក្នុងកម្រិតអន្តរជាតិ ដើម្បីជាគំនិតមួយសម្រាប់ជាកម្មវត្ថុ នៃការស៊ើបអង្កេត ពាក់ព័ន្ធទៅនឹងលក្ខណៈវិនិច្ឆ័យ ទៅនឹងអំពើ ហើយនិងសកម្មភាព ដូចជា ឯកសារដូចជាសៀវភៅជាដើម។

[១៣:៤៦:០២]

ដូច្នេះសំអាងហេតុជាចម្បងនេះ ដែលត្រូវបានលើកឡើងដោយ អាយ.ស៊ី.ធី.អ័រ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៅថ្ងៃទី១៨ ខែកញ្ញា ២០១១ គឺរឿងក្ដីរវាងរដ្ឋអាជ្ញា តទល់ជាមួយ នៀម៉ាធូ ហ៊ីហ្គោ។ ខ្ញុំគិតថាបើសិនណាជា ការអំណានឈ្មោះនេះ វាមិនត្រឹមត្រូវក៏សូមអធ្យាស្រ័យ។ ចុះថ្ងៃទី១៨ ខែកញ្ញា ២០០១ នៅកថាខណ្ឌ៩ គឺអង្គជំនុំជម្រះសាលាដំបូង បានលើកឡើងថា "ចម្លើយដែលទទួលបាននៅក្នុងដំណើរការនីតិវិធីគឺត្រូវ-- ដែលរដ្ឋអាជ្ញាបានទទួលបានគឺត្រូវជាកម្មវត្ថុ នៃការមកផ្ដល់សក្ខីកម្ម ដោយសាក្សីនោះនៅក្នុង នៅចំពោះមុខអង្គជំនុំជម្រះ"។ ដូច្នេះវិធាននេះ គឺវាពាក់ព័ន្ធដែលកម្រិតនេះ គឺពាក់ព័ន្ធទៅនឹងអំពើ និងសកម្មភាពរបស់ជនជាប់ចោទ គឺពាក់ព័ន្ធតែចម្លើយសាក្សីដែលយកមកដើម្បីមូលហេតុនៃដំណើរការនីតិវិធីនោះ។

[១៣:៤៧:១៣]

លោក លោកស្រីចៅក្រម គឺថាមានឯកសារបន្ទាប់បន្សំជាច្រើន ដែលទាក់ទងទៅនឹងអំពើ និងសកម្មភាពរបស់ជនជាប់ចោទ។ វាមានឯកសារដែលកើតនៅសម័យកម្ពុជាប្រជាធិបតេយ្យ អំឡុង

កម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាឯកសារសារព័ត៌មាន សៀវភៅ ឯកសារវិភាគ និងឯកសារមួយចំនួនធំទៀត។ អ្វីដែលយើងខ្ញុំលើកឡើងនេះ គឺសូម្បីតែឯកសារដែលវានិយាយទៅដល់អំពើ និងសកម្មភាពរបស់ជនជាប់ចោទក៏ដោយ គឺថាអាចទទួលយកបានដោយមិនបាច់កោះអញ្ជើញអ្នកនិពន្ធ ឬក៏សាក្សីគ្រប់រូបមកផ្តល់សក្ខីកម្មនោះទេ។ ជំហររបស់យើងខ្ញុំបានលើកឡើងនៅក្នុងសារណា ជាលាយលក្ខណ៍អក្សររបស់យើងខ្ញុំរួចមកហើយ។

[១៣:៤៨:១២]

ហេតុអ្វីបានខ្ញុំលើកឡើងនូវជំហរនេះ ដោយសារថា សៀវភៅ ឬក៏ឯកសាររបាយការណ៍ យើងខ្ញុំស្នើសុំឲ្យអង្គជំនុំជម្រះ ទទួលយកនូវអ្វីដែលបានសរសេរនៅក្នុងសៀវភៅ ឬរបាយការណ៍វិភាគនោះដែលវាចង្អុលបង្ហាញថា វាជាឯកសារភស្តុតាងនោះ ដើម្បីជួយទៅដល់ការពិនិត្យអំពីនយោបាយ គោលនយោបាយបរិបទទាំងឡាយ គឺយើងបានដាក់វាដោយមានការស៊ីសង្វាក់គ្នា ទៅនឹងឯកសារដែលកើតនៅសម័យកាលនោះដែរ។ ហើយដូចដែលសហការីរបស់ខ្ញុំលើកឡើងហើយថា ជាមួយនឹងអង្គជំនុំជម្រះ ដែលមានចៅក្រមវិជ្ជាជីវៈនេះគឺ គេអាចទទួលយកបាននូវឯកសារបន្ទាប់បន្សំនេះបាន ហើយត្រូវយកមកពិចារណានៅក្នុងលក្ខណៈមួយសមស្រប។

[១៣:៤៩:១៤]

មេធាវីការពារក្តីរបស់ អៀង សារី បានលើកឡើងពីម្សិលមិញហើយថា ប្រភេទឯកសារឯកសារប្រភេទនេះ គឺនិយាយអំពីប្រព័ន្ធឯកសារ នៃប្រព័ន្ធសារព័ត៌មាននេះឯង។ បើសិនណាជាវាមានការស៊ីសង្វាក់គ្នា មានន័យថា ស៊ីសង្វាក់គ្នាទៅលើអ្វីដែលលើកឡើងមកនិយាយ ឬក៏អង្គហេតុដែលកើតនោះគឺថា ជាការគួរឲ្យជឿជាក់បាន។ នេះគឺជាអ្វីដែលយើងខ្ញុំក៏បានដាក់ជូនអង្គជំនុំជម្រះ នេះហើយយើងអាចមើលទៅលើឯកសារនេះទាំងមូលតែម្តង ដើម្បីឲ្យដឹងថាតើឯកសារសារព័ត៌មានបែបនេះ វាស៊ីសង្វាក់គ្នាដែរ ឬក៏យ៉ាងណានោះ?

ដោយសារថា លោក លោកស្រីចៅក្រមទាំងអស់ អាចនឹងពិចារណានៅក្នុងមធ្យោបាយ មួយសមស្រប។ ខ្ញុំសូមចូលទៅដល់សៀវភៅនានា ប៉ុន្តែខ្ញុំសូមបញ្ចប់ឯកសារនេះត្រឹមនេះ គ្រាន់តែរំឮកឡើងវិញជាសង្ខេបទេ ទាក់ទងទៅនឹងបញ្ហាដែលពាក់ព័ន្ធទៅនឹងការកោះហៅសាក្សី ដើម្បីឲ្យមកផ្តល់នូវយថាភាពទៅដល់បណ្តាឯកសារទាំងហ្នឹង។ នៅក្នុងកថាខណ្ឌ៧ នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ E162 គឺមិនមានតម្រូវលក្ខខណ្ឌនៅចំពោះ-- ដើម្បីឲ្យហៅសាក្សីដើម្បីឲ្យមកបញ្ជាក់អំពីយថាភាពនៃ

ឯកសារនីមួយៗទេ។ ហើយអង្គជំនុំជម្រះក៏បានលើកឡើងផងដែរ គឺវាអាស្រ័យទៅលើខ្សែចង្វាក់នៃការរបៀបរបបនៃការរក្សាទុក និងការទទួលបាននៃឯកសារនេះ។

[១៣:៥១:០៨]

មុននឹងយើងខ្ញុំចូលទៅដល់សាក្សីដែលត្រូវមក ត្រូវផ្ដល់សក្ខីកម្មនោះ ទាក់ទងទៅដល់កាលៈ-ទេសៈ គឺវានៅដំណាក់កាលនៃសវនាការបន្តបន្ទាប់ ដែលយើងត្រូវកោះហៅសាក្សីយ៉ាងច្រើន គឺថានឹងត្រូវមកផ្ដល់ភស្តុតាងប្រភេទនេះហើយ។ ខ្ញុំមើលទៅលើបញ្ជីនេះ គឺយើងមានជាមួយនឹង ឌុច មុនគេហើយគាត់នឹងនិយាយអំពីការទំនាក់ទំនងមួយស៊េរីនៅក្នុងរបបនោះ ហើយនិងឯកសារពាក់ព័ន្ធទៅនឹងពាណិជ្ជកម្ម ការឯកសារឃោសនាផ្សព្វផ្សាយ ហើយនិងរចនាសម្ព័ន្ធបណ្ដាក្រសួងនានា។ នេះគឺជាឯកសារដែលមាននៅចំពោះមុខអង្គជំនុំជម្រះហើយ។ ខ្ញុំនឹងលើកឡើងសង្ខេប ទាក់ទងទៅនឹងចម្លើយសារភាព ដោយសារតែមានហេតុផលមួយចំនួនទាក់ទងទៅនឹងឧបសម្ព័ន្ធផ្សេងៗ។ ខ្ញុំនិយាយអំពីការហាមឃាត់មិនឲ្យមានអំពើទារុណកម្មនៅក្នុងមាត្រា១៥។

[១៣:៥២:៣០]

មេធាវីការពារក្ដីរបស់ នួន ជា បានយោងទៅលើសេចក្ដីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០១។ សេចក្ដីសម្រេចនេះគឺមាននៅក្នុង-- កត់ត្រានៅក្នុងប្រតិចារឹក។ នៅកថាខណ្ឌនេះ អ្វីដែលបានលើកឡើងពីម្សិលមិញមិននោះ មិនមែនជារឿងរ៉ាវមួយពេញលេញនោះទេ មិនមែនជារឿងមួយពេញលេញទៅលើករណីជាក់លាក់បែបនេះនោះទេ។ អង្គជំនុំជម្រះក៏បានសម្រេចជារួមមួយរួចហើយ គឺការសម្រេចជាទូទៅនេះថា សហព្រះរាជអាជ្ញាក៏បានលើកឡើងថា ការយល់ឃើញរបស់យើងខ្ញុំ គឺសេចក្ដីសម្រេចដ៏ច្បាស់លាស់មួយ ទាក់ទងទៅនឹងអនុសញ្ញាហាមឃាត់មិនឲ្យធ្វើទារុណកម្ម។

[១៣:៥៣:២៩]

ទោះបីជា ភាគីណាមួយសំអាងទៅលើឯកសារណាមួយ ពាក់ព័ន្ធទៅនឹងការធ្វើទារុណកម្មនេះក៏ដោយ។ យើងខ្ញុំសូមបញ្ជាក់ថា នេះជាបញ្ហាមួយដែលស្មុគស្មាញ ហើយយើងខ្ញុំសូមលើកថាត្រូវតែបើមានការសម្រេចទៅលើបញ្ហានេះ គឺត្រូវពិចារណាឲ្យបានច្បាស់លាស់។ ចៅក្រម លោកស្រីចៅក្រម ខាតវ៉ាយថ៍ គាត់បានលើកឡើងហើយ គឺថាបានផ្ដល់សិទ្ធិទៅឲ្យភាគីដើម្បីលើកឡើងអំពីបញ្ហានេះ។ ទាក់ទងទៅនឹងនីតិវិធីដែលពាក់ព័ន្ធទៅនឹងឯកសារ ដែលបានលើកឡើងនៅចំពោះមុខតុលាការ ហើយ

ដែលត្រូវបានសម្រេចទៅតាមនោះ។ លោក លោកស្រីចៅក្រម នឹងបានស្តាប់ឮពីសហការីរបស់ខ្ញុំ អំពីភាពដែលអាចទទួលយកបានក្នុងការប្រើប្រាស់នៃឯកសារទាំងនេះ។ មិនមានលក្ខខណ្ឌគតិយុត្តិណាមួយដែលនិយាយថា ឯកសារទាំងឡាយណាដែលប្រឡាក់ប្រឡូសដោយ ការធ្វើទារុណកម្មត្រូវតែច្រានចោលទេ ដោយសារឯកសារប្រភេទនេះ គឺជាឯកសារដែលមានមុខព្រួញពីរ។

[១៣:៥៤:៥០]

ដូច្នេះការយកឯកសារជាចម្លើយនេះ ដែលត្រូវតែហាមឃាត់នេះទេ លើកលែងតែមានលក្ខខណ្ឌណាមួយត្រូវបានបំពេញ ទៅដល់ការធ្វើទារុណកម្មបែបនេះ។ តាមការពិតមានការប្រើប្រាស់ដ៏ត្រឹមត្រូវនូវឯកសារបែបនេះ ដែលសហការីរបស់ខ្ញុំ គាត់នឹងលើកឡើងឲ្យលម្អិតជាងនេះទៅទៀត។

ចូលទៅដល់ចំណុចមួយផ្សេងទៀត ដែលទាក់ទងទៅនឹងឯកសារថ្មីៗ។ មេធាវីការពារក្តីរបស់ខៀវ សំផន បានលើកឡើងថា តាមការយល់របស់ពួកគាត់ គឺឯកសារថ្មីត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធ២១ នៃបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញានោះ គឺមិនមែនជាកម្មវត្ថុនៃសវនាការក្នុងដំណាក់កាលនេះទេ។ ខ្ញុំគិតថា ត្រឹមត្រូវហើយ-- ខ្ញុំគិតថា មិនត្រឹមត្រូវ ដោយសារឯកសារនេះមិនមែនជាឯកសារថ្មីទេ វាគ្រាន់តែជាឯកសារដែលយើងខ្ញុំបានដាក់នៅក្នុងខែមេសា ឆ្នាំ២០១១ ដើម្បីឆ្លើយតបទៅនឹងសេចក្តីសម្រេចអំពីការកំណត់ពេលវេលាសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង។ នៅពេលនោះ គឺថាវាមិនទាន់មាននៅក្នុងសំណុំរឿងមែន។ ហើយខ្ញុំសូមស្នើថា ឲ្យដាក់បញ្ចូលនៅក្នុងសំណុំរឿងនេះ ហើយគេបានពិនិត្យមើលទៅលើឧបសម្ព័ន្ធទាំង២៨នេះ គឺមាននៅក្នុងឧបសម្ព័ន្ធ២១នេះ។

[១៣:៥៦:៣៧]

ឧបសម្ព័ន្ធ២១ ជាបញ្ជីឯកសារសម្រាប់បង្កលក្ខណៈងាយស្រួលទៅដល់ឯកសារទាំងឡាយណាដែលនៅពេលនោះយើងចាត់ទុកជាឯកសារថ្មីមែន។ ការដែលដាក់ឈ្មោះថា ឯកសារនេះថ្មីនេះ គឺមិនត្រឹមត្រូវទេ នៅពេលដែលសវនាការចាប់ផ្តើមឡើងជាមួយសវនាការបឋម។ បន្ទាប់ពីសវនាការបឋម វិធាន៨៧.៤ គឺនិយាយអំពីការហាមមិនទទួលយកនូវឯកសារថ្មី។ ខ្ញុំគិតថា ឯកសារទាំងអស់នេះ គឺកំណត់ថា ជាឯកសារមួយថ្មីនៅក្នុងបញ្ជីរបស់យើងខ្ញុំ គឺនៅក្នុងឯកសារ-- យើងខ្ញុំបានដាក់ជូនមួយរយៈកាលកន្លងមកហើយ។ ហើយខ្ញុំសូមអញ្ជើញឲ្យអង្គជំនុំជម្រះមេត្តាពិនិត្យ និងពិចារណាទទួលយកឯកសារដែលដាក់នៅក្នុងឧបសម្ព័ន្ធនេះ។

[១៣:៥៧:៤២]

ចូលទៅដល់បញ្ហាមួយផ្សេងទៀត។ នេះគឺពាក់ព័ន្ធទៅនឹងការពិចារណា ឬក៏ការចោទអំពីថាមានភាពលម្អៀងពីសំណាក់មជ្ឈមណ្ឌលឯកសារកម្ពុជា។ យើងបានឮប៉ុន្មានខែមកនេះ គឺថាយើងបានស្តាប់ឮជាញឹកញាប់ដែរ ប៉ុន្តែនៅក្នុងឱកាសនេះក្រុម ខៀវ សំផន បានលើកឡើងអំពីភាពលម្អៀងនេះ។ ហើយខ្ញុំបានកត់សម្គាល់ឃើញថា ក្រុមមេធាវីការពារក្តីរបស់ នួន ជា ហាក់បីដូចជាឈប់លើកឡើងពីចំណុចនេះហើយ។ ខ្ញុំ យើងខ្ញុំមិនចង់ចំណាយពេលវេលាច្រើនទេ នេះវាជាភស្តុតាងផ្ទាល់។ ជំហររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា អាណត្តិការងារ ការខិតខំប្រឹងប្រែង និងការទទួលខុសត្រូវ ក៏ដូចជាការកត់ត្រានូវប្រវត្តិសាស្ត្រ គឺមិនពាក់ព័ន្ធទៅនឹងឯកសារដែលយើងបានប្រមូលពី ឌី.ស៊ី.ខេម នោះទេ។ មិនមែនជា ឌី.ស៊ី.ខេម ដែលត្រូវស៊ើបអង្កេតឧក្រិដ្ឋកម្មនេះទេ ដោយសារស្ថាប័ននេះ គឺជា គឺការស៊ើបអង្កេត គឺត្រូវធ្វើឡើងស្ថាប័នតុលាការដែលឯករាជ្យ។ ហើយយើងខ្ញុំដឹងថា សក្ខីកម្មរបស់លោក យុ ឆាំង បានបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកទ្វារផ្តល់លទ្ធភាពទៅដល់ភាគីទាំងអស់ ក៏ដូចជាអ្នកចូលរួមនៅក្នុងដំណើរការនីតិវិធីនេះទាំងអស់ ដើម្បីឲ្យមជ្ឈមណ្ឌលផ្តល់នូវឯកសារណាមួយដែលមាននៅក្នុងបណ្ណសារដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

[១៣:៥៩:៣៦]

ជំហរពិសេសនោះត្រូវបានទទួលយកពីសំណាក់សហចៅក្រមស៊ើបអង្កេតនៅក្នុងឯកសារពីរ ខ្ញុំសូមលើកឡើងសង្ខេបទេ គឺឯកសារ A110/II គឺ A110/II និងឯកសារ D164/2។ ឯកសារទាំងពីរនេះបានបង្ហាញច្បាស់ហើយ ជាពិសេសឯកសារទីពីរនេះតែម្តង គឺភាគីមានសិទ្ធិដោយសេរី ក្នុងចូលទៅមើលបណ្ណាល័យ ឬក៏ប្រភពឯកសារណាមួយ និងស្នើសុំឯកសារណាមួយ ដែលភាគីនោះ យល់ឃើញថាមានការពាក់ព័ន្ធ ដើម្បីឈានទៅដល់ការបង្ហាញនូវការពិត។ មិនត្រូវមានទីកន្លែងឯកសារណាមួយ ឬក៏មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវច្រានចោល ឬក៏ត្រូវហាមឃាត់មិនឲ្យមានការពិគ្រោះយោបល់ជាសាធារណៈនោះទេ។

ដូច្នេះយើងខ្ញុំយល់ឃើញថា មិន-- មេធាវីការពារក្តីគឺថាលើកឡើងមិនសមស្របទេ ចោទប្រកាន់ ការចោទប្រកាន់នេះមិនសមស្របទេនៅក្នុងដំណើរការនីតិវិធីនេះ។ ជាការពិត គឺមជ្ឈមណ្ឌលឯកសារកម្ពុជាមានការកត់ត្រាប្រវត្តិសាស្ត្រគួរឲ្យមានចិត្ត-- ការចាប់អារម្មណ៍។ ដូច្នេះហើយ គឺថាឯកសារដែលទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា គឺអាចនឹងទទួលយកបាន។

[១៤:០១:១៧]

នៅពេលនេះ ខ្ញុំសូមលើកឡើងឧបសម្ព័ន្ធចំនួនបី ខ្ញុំលើកឡើងដោយខ្លីៗ ដោយសារតែខាងមេធាវីការពារក្តីលើកឡើងការជំទាស់របស់ខ្លួននោះ គឺមិនមានលក្ខណៈលម្អិតទៅលើឧបសម្ព័ន្ធទាំងបីនេះនោះឡើយ។ ជាដំបូងឧបសម្ព័ន្ធប្រាំពីរ ដែលឧបសម្ព័ន្ធនេះមានកំណត់ហេតុក្រសួងពាណិជ្ជកម្ម។ នៅក្នុងឧបសម្ព័ន្ធនេះ ខ្ញុំនឹកឃើញថា នួន-- ក្រុម នួន ជា បានទទួលស្គាល់ និងទទួលយក ហើយក្រុមមេធាវីការពារក្តី អៀង សារី ទុកឲ្យអង្គជំនុំជម្រះមានឆន្ទានុសិទ្ធិសម្រេចថា តើឯកសារប្រភេទនេះ គួរតែទទួលយក ឬក៏យ៉ាងណា? មានតែក្រុមមេធាវី ខៀវ សំផន តែប៉ុណ្ណោះដែលធ្វើការជំទាស់ទៅលើឯកសារទាំងបីនេះ ដែលបានទទួលយកដោយអង្គជំនុំជម្រះ។ មូលដ្ឋានមួយក្នុងចំណោមហ្នឹង គឺដោយសារតែមជ្ឈមណ្ឌលឯកសារកម្ពុជាមានការចូលរួមក្នុងការធ្វើរៀបចំឯកសារហ្នឹង ការតវ៉ាទៅលើឯកសារហ្នឹងគឺៗតវ៉ាទៅលើខ្សែសង្វាក់នៃការកាន់កាប់ឯកសារ ហើយគេក៏បាននិយាយយោងអំពីចំណារដែលបានសរសេរនៅលើឯកសារទាំងអស់នេះផងដែរ។

[១៤:០២:៤៩]

នៅពេលនេះ ខ្ញុំសូមរឭកឡើងវិញ អង្គជំនុំជម្រះបានសម្រេចរួចមកហើយ ថាខ្សែសង្វាក់នៃការកាន់កាប់នោះមិនមែនជាលក្ខខណ្ឌក្នុងការទទួលយកសម្ភារៈឯកសារ នៅពេលដែលយើងបង្ហាញអំពីភស្តុតាងដំបូង។ ដូច្នេះហើយយើងខ្ញុំសូមលើកឡើងថា គ្មានអ្វីសង្ស័យទេ ថាឯកសារទាំងអស់នេះមានយថាភាព និងអាចទុកចិត្តបាន។ យើងនិយាយដូច្នេះដោយសារតែយើងឃើញមានភស្តុតាងយ៉ាងច្រើននៅក្នុងសំណុំរឿងអំពីប្រភព និងភាពដើមនៃឯកសារទាំងអស់នេះ។ មេធាវី ខៀវ សំផន បាននិយាយអំពីសេចក្តីប្រកាសរបស់សាក្សី TCW-583 ដែលថាបានលើកឡើងអំពីសេចក្តីប្រកាសរបស់សាក្សីនេះ។ សាក្សីរូបនេះមាននៅក្នុងបញ្ជីសាក្សី ហើយសាក្សីរូបនេះនឹងមកផ្តល់សក្ខីកម្ម។ ហើយយើងជឿថាឯកសារនេះ ត្រូវបានបង្កើតទៅតាមអត្ថន័យរបស់វា។

[១៤:០៣:៥៥]

ខ្ញុំចង់ប្រើប្រាស់ឧបសម្ព័ន្ធនេះដើម្បីឆ្លុះបញ្ចាំងអំពីចំណុចដែលយើងបានលើកឡើងខាងដើម អំពីការព្យាយាមរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការរកឯកសារដើម។

លោកប្រធាន លោក លោកស្រីជាទីគោរព! ប្រសិនបើអនុញ្ញាតនោះ គឺខ្ញុំសូមធ្វើការបញ្ចាំងឯកសារចំនួនពីរ ឬក៏បី ដែលពាក់ព័ន្ធទៅនឹងកំណត់ហេតុក្រសួងពាណិជ្ជកម្ម និងវិធីដែលគេប្រមូលឯកសារទាំងពីរ ឬក៏បីនេះ។ ប្រសិនបើអនុញ្ញាត គឺខ្ញុំសូមឲ្យបញ្ចាំង។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ប្រសិនបើអាចបញ្ចាំងនៅលើអេក្រង់ គឺឯកសារ១លេខ D161 យើងបានយោងទៅលើឯកសារនេះ បន្តិចរួចមកហើយខាងដើមនោះ។ ឯកសារD161 ជាដីកាចាត់ឲ្យស៊ើបសួរជំនួស ចេញដោយសហចៅក្រមស៊ើបអង្កេត។ ខ្ញុំសូមអភ័យទោស ដោយសារតែខ្ញុំបញ្ចាំងឯកសារជាភាសាអង់គ្លេសនៅទីនេះ ដោយសារតែវាងាយស្រួលសម្រាប់ឲ្យខ្ញុំនេះអាចអានតាមអេក្រង់។ ប្រសិនបើយើងទាញចុះក្រោមទៅដល់ទំព័រទីពីរ អ្វីដែលយើងបានធ្វើឡើងនេះ គឺយើងបានដកឈ្មោះចៅក្រមស៊ើបអង្កេតចេញ លុបចោល ដោយសារហេតុផលផ្សេងៗ។ សំណុំរឿងទាំងមូល ឯកសារនេះទាំងមូលមាននៅក្នុងសំណុំរឿងហើយ ផ្នែកដែលគួសពណ៌គឺបង្ហាញអំពីបេសកកម្មដែលសហចៅក្រមស៊ើបអង្កេតបានផ្តល់ភារកិច្ចទៅដល់អ្នកស៊ើបអង្កេត គឺពួកអ្នកស៊ើបអង្កេតត្រូវតែទាក់ទងជាមួយនឹងបុគ្គលដែលទទួលខុសត្រូវបណ្ណសារដ្ឋានជាតិ ដើម្បីស្នើសុំការសហការ ពិគ្រោះយោបល់ និងការថតចម្លងឯកសារ ឯកសារសោតទស្សន៍ ឬក៏សម្ភារៈផ្សេងទៀត។

[១៤:០៦:១៣]

នៅក្នុងកថាខណ្ឌទីពីរ អ្នកស៊ើបអង្កេតត្រូវតែពិគ្រោះយោបល់អំពីឯកសារទាំងអស់នេះ ហើយស្នើសុំផ្តល់ជូននូវឯកសារថតចម្លងជាអេឡិកត្រូនិក ឬជាឯកសារក្រដាស។ នៅពេលនេះ ខ្ញុំសូមចូលទៅដល់ឯកសារD161/1 ឯកសារនេះគឺឆ្លុះបញ្ចាំងអំពីសេចក្តីសន្និដ្ឋានរបស់ខ្ញុំខាងដើម អំពីការងាររបស់សហចៅក្រមស៊ើបអង្កេតដែលគាត់បានធ្វើនៅក្នុងការិយាល័យរបស់ខ្លួន គឺសហចៅក្រមស៊ើបអង្កេតព្យាយាមរកឯកសារដើម ហើយព្យាយាមពិគ្រោះរកឯកសារដើម។ នៅក្នុងទំព័រដំបូងនេះត្រង់ចំណុចគួសពណ៌គឺមានថ្ងៃចំនួនពីរ គឺចំនួនពីរថ្ងៃគឺអ្នកស៊ើបអង្កេតបានធ្វើការទៅបណ្ណសារដ្ឋានជាតិ ហើយធ្វើការស្កេនថតរកឯកសារដើម។ ឯកសារចំនួន៥១ ត្រូវបានថតចម្លងទាំងស្រុង ហើយប្រសិនបើយើងមើលទំព័របន្ទាប់មានសរសេររៀបរាប់ថា ឧបសម្ព័ន្ធទៅនឹងឯកសារទាំងអស់នេះ គឺស្កេនជា*ក្លូល័រ*ទៅលើ-- ស្កេនអំពីទូរសារដើម និងលិខិតឆ្លើយឆ្លងផ្សេងៗ។

[១៤:០៧:៣៧]

ខ្ញុំលើកឡើងអំពីឯកសារនេះ ដោយសារតែកំណត់ហេតុឯកសារដែលប្រមូលពីខាងបណ្ណសារ

ដ្ឋានជាតិនោះគឺជាកំណត់ហេតុក្រសួងពាណិជ្ជកម្ម។ ហើយដែលបានធ្វើឡើងតាមដីកាបង្គាប់ ដីកាចាត់ឲ្យសួរជំនួសនេះ។

ចំពោះភាពដើមនៃឯកសារនេះថា តើចូលមកបណ្ណសារដ្ឋានជាតិយ៉ាងដូចម្ដេចនោះ ឆាំង យុ គាត់បានផ្ដល់ព័ត៌មានខ្លះនៅក្នុងឯកសារដែលមានលេចD150 ដែលក្នុងនោះលោក ឆាំង យុ បានបញ្ជាក់លើកឡើងថា ឯកសារទាំងអស់នោះគឺបានយកទៅដាក់នៅបណ្ណសារដ្ឋានជាតិដោយសមាជិករណសិរ្ស។

[១៤:០៨:២៨]

ខណៈដែលយើងនិយាយអំពីឧបសម្ព័ន្ធ៧ ទោះបីជានៅពេលនេះមិនបានលើកឡើងដោយលម្អិតក៏ដោយ វាអាចមានសារៈសំខាន់ ប្រសិនបើខ្ញុំចង្អុលបញ្ជាក់អំពីភាពពាក់ព័ន្ធនៃឯកសារទាំងអស់នេះ មានឯកសារចំនួន១៦៩ ឯកសារនៅក្នុងឧបសម្ព័ន្ធ៧។ នៅពេលដែលយើងមើលឡើងវិញ យើងឃើញថាមាន២៦ គឺរបាយការណ៍ជូនបងហែម ដែលជាលោកខៀវ សំផន។ បន្ថែមទៅលើចំណុចនេះបន្ថែមទៅលើរបាយការណ៍ចំនួន២៦ ឯកសារប្រហែល៩៨ ជាកំណត់ហេតុក្រសួងពាណិជ្ជកម្ម ដែលមានចំណារបញ្ជូនទៅបងហែម។ ជាធម្មតា យើងឃើញមានចំណារបង្ហាញថា តើឯកសារនេះបញ្ជូនទៅបុគ្គលរូបណា?

[១៤:០៩:៣៣]

ហើយជាទូទៅ គឺយើងឃើញបញ្ជូនទៅលោក ខៀវ សំផន។ ឯកសារទាំងអស់នេះ គឺពាក់ព័ន្ធដោយសារតែហេតុផលមួយចំនួនរួមទាំងឯកសារទាំងនេះ ដែលបង្ហាញអំពីដំណើរការអំពីរបបនោះ ហើយនិយាយអំពីអំណាចរបស់លោក ខៀវ សំផន ពាក់ព័ន្ធទៅនឹងក្រសួងពាណិជ្ជកម្ម ហើយនិងបញ្ហាផ្សេងទៀតដែលបានបញ្ចូលនៅក្នុងឯកសារនេះ ដែលពាក់ព័ន្ធនៅក្នុងសវនាការវគ្គដំបូង។ នៅពេលនេះ ខ្ញុំក៏សូមអនុញ្ញាតបញ្ចាំងនូវឯកសារមួយទៀត គឺឯកសារ D366/7.1.841។ ឯកសារនេះ គឺជាឯកសារនៅក្នុងឧបសម្ព័ន្ធ៧ ដដែល ហើយយើងនឹងបញ្ចាំងជាភាសាខ្មែរ ដើម្បីបង្ហាញនូវទម្រង់បែបបទឯកសារនេះ ជាឯកសារជាភាសាដើម។

សូមអនុញ្ញាតបញ្ចាំងឯកសារ D366/7.1.841!

លោក លោកស្រីចៅក្រម ជាទីគោរព! ឯកសារនេះ គឺជាតារាងដែលកត់ត្រានូវការផ្គត់ផ្គង់ស្រូវ និងចំណូលនៅក្នុងខែមីនា ឆ្នាំ១៩៧៧ ដែលក្នុងនោះ មានទិន្នផលជាច្រើនបញ្ជូនទៅទីក្រុងភ្នំពេញ ហើយទិន្នផលជាច្រើនបានមកពីខាងនិរតី បស្ចិម បូព៌ា និងឧត្តរ និងពាយ័ព្យ (សូមអភ័យទោស)។ យើងខ្ញុំ

ក៏សូមបញ្ចាំងឯកសារនេះជាភាសាអង់គ្លេសផងដែរ ប្រហែលជាភាសាអង់គ្លេស អាចឲ្យបុគ្គលដែលមិនអាចចេះភាសាខ្មែរនោះ អាន និងចាប់អារម្មណ៍។ ឯកសារនេះ សាជាថ្មីគឺមានចំណារ ដែលក្នុងនេះបញ្ជូនទៅបង ហែម ដែលជាខៀវ សំផន។ ឯកសារនេះ គឺពាក់ព័ន្ធ ដោយសារតែមានចំណុចដែលពាក់ព័ន្ធនៅក្នុងរង្វង់ក្រហម នៅរង្វង់ក្រហមខាងឆ្វេង សរសេរថា "បញ្ជូនទៅបង ហែម"។

[១៤:១២:០៦]

ដូច្នេះ យើងខ្ញុំសូមបញ្ជាក់នៅក្នុងសេចក្ដីសន្និដ្ឋានថា គឺរដ្ឋាភិបាល ឬក៏គណៈមជ្ឈិមគឺទទួលបន្ទុកនៅក្នុងការបញ្ជូនរបាយការណ៍ពាក់ព័ន្ធទៅនឹងទិន្នផលដែលធ្វើបានផងដែរ។ ពាក់ព័ន្ធទៅនឹងចំណារៗចំណារនេះ គឺបានលើកឡើងផងដែរ ដែលចំណារមានលើឯកសារចំនួន៩៨។ ពាក់ព័ន្ធទៅនឹងបញ្ហានេះ យើងខ្ញុំសូមលើកឡើងថា ចំណារទាំងអស់នេះ គឺវាមិនពាក់ព័ន្ធទៅនឹងការទទួលយកឯកសារនោះទេ។ យើងឃើញថា វាមានចំណារពាក់ព័ន្ធទៅនឹង វ៉ាន់ រិទ្ធ ដែលគាត់ជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនៃកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំគ្រាន់តែចង់លើកឡើងថា ឯកសារទាំងអស់នេះ គឺជាចំណារដែលមាននៅក្នុងក្រសួងពាណិជ្ជកម្ម ដែលយើងមើលទៅគឺទំនងដូច្នោះ។ ហើយចំណារទាំងអស់នេះ គឺបានធ្វើឡើងនៅពេលដែលក្រសួងពាណិជ្ជកម្មនេះ ធ្វើការងាររបស់ខ្លួន។ ដូច្នេះ ហើយចំណារទាំងអស់នេះ វាមិនអាចមានការពាក់ព័ន្ធថា មិនឲ្យយើងទទួលយកឯកសារទាំងអស់នេះ ដោយរបៀបណានោះទេ ដែលថាវាមិនមែនជាឯកសារដើម ដោយសារតែយើងស្កេនវាយកមកពីឯកសារផ្សេងនោះ។

[១៤:១៣:៥៣]

ចំពោះឧបសម្ព័ន្ធ១៥ ខ្ញុំលើកឡើងដោយសង្ខេប។ ឧបសម្ព័ន្ធ១៥ នេះ គឺមានរូបថត និងផែនទី។ យើងសូម-- យើងខ្ញុំសូមកត់សម្គាល់ថា ឯកសារភាគច្រើននៅក្នុងឧបសម្ព័ន្ធនេះ គឺយើងមិនគួរ-- យើងមិនឃើញការជំទាស់ទៅនឹងឯកសារនេះភាគច្រើននោះទេ។

ឯកសារមួយចំនួនបានលើកឡើងដោយមេធាវីការពារក្ដី ហើយមេធាវីការពារក្ដីបានទទួលពេលវេលាច្រើន ក៏ប៉ុន្តែការលើកឡើងរបស់ខ្លួននោះ គឺតិចជាងពេលដែលខ្លួនផ្ដល់ឲ្យ។ មេធាវីការពារក្ដី នួនជា បានលើកឡើងថា ឯកសារទាំងអស់នៅក្នុងឧសម្ព័ន្ធនេះ មិនពាក់ព័ន្ធទេ។ មេធាវីការពារក្ដី អៀង សារី បានផ្ដល់ជាអត្ថាធិប្បាយទៅលើរូបថត ដោយលើកឡើងថា ប្រសិនបើគេសន្មតថា រូបថតទាំងអស់នោះ វាជារូបថតដែលថតឡើងនៅក្នុងឆ្នាំ១៩៧៥ ឬក៏រូបថតនោះ វាកើតឡើងនៅក្នុង១៩៧៥ គួរតែកោះហៅសាក្សីមកផ្ដល់សក្ខីកម្មអំពីរូបថតផែនទីដែលបានគួរ។

យើងខ្ញុំសូមបញ្ជាក់ថា ការលើកឡើង ដូច្នេះ គឺមិនត្រឹមត្រូវតាមផ្លូវច្បាប់ គ្មានលក្ខខណ្ឌណាមួយទាមទារឲ្យធ្វើដូច្នេះនោះទេ។ រូបថតជាច្រើន មាននៅក្នុងសំណុំរឿង ហើយភាគច្រើននោះ គឺបានថតក្រោយឆ្នាំ ទសវត្សរ៍ឆ្នាំ១៩៧០។ អស់លោក លោកស្រីចៅក្រមអាចមានលទ្ធភាពពិនិត្យមើលទៅលើប្រភេទរូបថតដូច្នេះបាន។ ក្រោយពីសាក្សីផ្តល់សក្ខីកម្មនោះ គឺលោកចៅក្រមអាចផ្តល់ទម្ងន់ទៅលើរូបថត និងផែនទីទាំងអស់នេះ។ យើងខ្ញុំសូមលើកឡើងថា រូបថតទាំងអស់នេះ គឺមិនមែនវាបង្ហាញអំពីអាគារដែលវាមានសភាពដើមនៅក្នុងឆ្នាំ១៩៧៥ និង៧៩នោះទេ។ រូបថតទាំងអស់នេះ គឺបានថតឡើងក្រោយពេលដែលយើងទៅសាកសួរសាក្សី ហើយយើងចាត់ទុកថា វាជាទីតាំងពាក់ព័ន្ធ។ សាក្សីនានាផ្សេងទៀត អាចរៀបរាប់អំពីទីតាំងទាំងអស់នេះនៅក្នុងអំឡុងពេលដែលពាក់ព័ន្ធ។

[១៤:១៦:២៧]

យើងមានពេលវេលាកម្រិត ដូច្នេះហើយ ខ្ញុំនឹងមិនចូលទៅលើឯកសារនីមួយៗនោះទេ។ មានឯកសារចំនួនប្រាំមួយ ដែលមេធាវីការពារក្តីបានលើកឡើង។ ចំពោះឯកសារ D108/39/8 ប្រសិនបើអនុញ្ញាតនោះ គឺខ្ញុំសូមឲ្យបញ្ចាំងដោយខ្លី ដោយសារតែមេធាវីការពារក្តីមួយចំនួននោះ បានចង្អុលបញ្ជាក់ទៅលើឯកសារ D108/38/8 នេះ។ មេធាវីការពារក្តីលោក អៀង សារី បានលើកឡើងអំពីឯកសារមួយនេះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

[១៤:១៧:១៨]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ឯកសារនេះនឹងបង្ហាញចេញតាមអេក្រង់ ក្នុងពេលឆាប់បន្តិចទៀតនេះ។ មេធាវីការពារក្តីបានលើកឡើងសេចក្តីសន្និដ្ឋានលម្អិត អំពីកម្មវិធីដែលផលិតផែនទីរូបថតនេះ គឺកម្មវិធីគម្រោងប្រល័យពូជសាសន៍។ មេធាវីការពារក្តីបានលើកឡើងសេចក្តីសន្និដ្ឋានរបស់ខ្លួន ហើយសង្កត់ធ្ងន់ទៅលើពាក្យប្រល័យពូជសាសន៍។ ហើយក៏បានលើកឡើងអំពីវិធីសាស្ត្រ ដែលគេបានអនុវត្តនៅក្នុងការបង្កើតផែនទីទាំងអស់នេះ។

ទាំងអស់នេះ គឺជាផែនទី យោងតាមដីកាបញ្ជូនរឿងទៅស៊ើបសួរ។ ទាំងអស់នេះគឺជាផែនទីដែលមានបំណងបង្ហាញភូមិសាស្ត្រទីតាំងបទល្មើសដែលគេសង្ស័យថា វាជាទីតាំងបទល្មើស វាមិនមែន

ជាផែនទីមួយលម្អិតដែលយើងដាក់លើកឡើងថា ជាភស្តុតាងមួយគ្មានវិមតិសង្ស័យនោះទេ ក៏ប៉ុន្តែយើងត្រូវតែពិនិត្យទៅលើធាតុផ្សំបរិបទ។

[១៤:១៨:៣០]

សេចក្តីផ្តើមនៃឯកសារនេះ គឺពន្យល់ថាតើទីតាំងនេះ គេកំណត់ដោយវិធីណា ហើយមានប្រភពព័ត៌មានមួយចំនួនផងដែរ ដែលក្នុងនោះគឺមានការសម្ភាសទៅលើសាក្សី អ្នករាយការណ៍នៅតាមមូលដ្ឋាន ហើយការប្រើប្រាស់ឯកសាររបស់កម្ពុជាប្រជាធិបតេយ្យ និងរបាយការណ៍ផ្សេងៗទៀតដែលគេយកមកប្រើប្រាស់។ នេះគឺជារបាយការណ៍វិភាគ យើងខ្ញុំបានលើកឡើងសេចក្តីសន្និដ្ឋានថាវាមានតម្រុយឲ្យយើងជឿជាក់បាន ថាតើនៅចុងក្រោយ លោក លោកស្រីចៅក្រមឯកភាពជាមួយនឹងទីតាំង និងការកំណត់ផែនទី ឬក៏យ៉ាងណានោះ វាជាឆន្ទានុសិទ្ធិ និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះក្រោយពេលសវនាការ និងក្រោយពេលពិនិត្យទៅលើភស្តុតាង ដែលបានដាក់ចំពោះមុខអង្គចៅក្រម។ យើងគ្មានជំទាស់នោះទេ ប្រសិនបើអង្គចៅក្រមយល់ឃើញថា សមស្របក្នុងការកោះហៅអ្នកដែលជាអ្នករៀបចំឯកសារនេះមកផ្តល់សក្ខីកម្ម។ ហើយនៅពេលដែលមានសំណើដូច្នោះនោះ គឺយើងខ្ញុំមិនជំទាស់នោះទេ។

ឯកសារនេះ នៅពេលនេះឃើញតាមរយៈអេក្រង់រួចហើយ។ លោក លោកស្រីចៅក្រម អាចឃើញដែលបង្ហាញនូវទីតាំងផ្សេងៗ អាចទំនងជាទីតាំងបទល្មើស។

[១៤:២០:០០]

ឯកសារប្រភេទនេះ យើងខ្ញុំសូមបញ្ជាក់ថា គឺពិតជាពាក់ព័ន្ធដោយសារតែវាបង្ហាញអំពីការវាយប្រហារជាប្រព័ន្ធ និងទូលំទូលាយនៅក្នុងប្រទេសកម្ពុជា វាពាក់ព័ន្ធដោយសារតែភាពចាំបាច់ ក្នុងការបង្ហាញ អំពីការអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម ក្នុងការស្វែងរក និងកម្ទេចខ្មាំងនៅទូទាំងប្រទេស។ ចំណុចនេះ គឺដូចគ្នាទៅនឹងឯកសារផ្សេងទៀត ដែលបានជំទាស់យ៉ាងជាក់លាក់ ដោយមេធាវីការពារក្តីឯកសារ D108/19/1/5 និងឯកសារ D108/39/10។ សាជាថ្មីម្តងទៀត ឯកសារទាំងពីរនេះគឺជាផែនទី ហើយយើងសូមបញ្ជាក់ថា ឯកសារទាំងអស់នេះគឺពាក់ព័ន្ធ ហើយវាមានភាពទុកចិត្តបានតាមភស្តុតាងពីមួយក្រឡេកភ្នែក ឬក៏ភស្តុតាងបឋម។

[១៤:២១:០៨]

នៅពេលដែលយើងចូលទៅដល់ឯកសារឧបសម្ព័ន្ធ១៩។ ឯកសារនៅក្នុងឧបសម្ព័ន្ធនេះ គឺរួម

មានសៀវភៅ យើងខ្ញុំបានលើកសេចក្ដីសន្និដ្ឋានកាលពីលើកមុន អំពីភាពអាចទទួលយកបាននៃប្រភេទ ឯកសារនេះ និងភាពមិនអាចអនុវត្តបានចំពោះលក្ខខណ្ឌតេស្ត ដែលបានលើកឡើង។

មេធាវីការពារក្ដីលោក អៀង សារី បានលើកឡើងថា ដើម្បីទទួលយកសៀវភៅបាននោះ ត្រូវតែកោះហៅអ្នកនិពន្ធ។ យើងខ្ញុំសូមលើកឡើងថា ការលើកឡើងដូច្នេះ គឺមិនមែនជាជំហរតាមផ្លូវ ច្បាប់ត្រឹមត្រូវនោះទេ ដោយសារតែលោក លោកស្រីចៅក្រមបានកោះហៅអ្នកជំនាញមួយចំនួនហើយ ដែលជាអ្នកសរសេរសៀវភៅ។ ដូច្នេះហើយការស្ដាប់សក្ខីកម្មរបស់អ្នកនិពន្ធនោះ មិនមែនជាបុរេ លក្ខខណ្ឌនោះឡើយ ក្នុងការទទួលយកសៀវភៅ ដោយសារតែសៀវភៅនេះ គឺជាសៀវភៅដែលយើង ពិនិត្យទៅតាមបរិបទ និងភស្តុតាងដែលយើងយកមកប្រៀបធៀប ឲ្យស៊ីសង្វាក់គ្នាទៅនឹងគោល នយោបាយតែប៉ុណ្ណោះ។ ក្នុងករណីភាគច្រើនវាមិនមែនជាភស្តុតាងចម្បងនោះឡើយ។

[១៤:២២:៣៧]

ជាការពិត លោក លោកស្រីចៅក្រម នៅពេលដែលយើងមើលបញ្ជីរបស់ក្រុមមេធាវីការពារក្ដី ដែលគេបានស្នើឡើង ឯកសារនៅចំពោះមុខអង្គសវនាការ យើងឃើញមានសៀវភៅជាច្រើនដែលបាន ស្នើឡើង។ ខ្ញុំសូមកត់សម្គាល់ថា ឯកសារទាំងអស់នេះ យើងដឹងអំពីភាពពាក់ព័ន្ធរបស់វាទៅតាមបរិបទ ដែលវាពាក់ព័ន្ធទៅនឹងភស្តុតាងផ្ទាល់ ដែលដាក់នៅចំពោះមុខអង្គសវនាការ។ បញ្ជីដែលពាក់ព័ន្ធរបស់ សម្រាប់លោកមេធាវីការពារក្ដី អៀង សារី គឺឯកសារ 109/6.2 គឺពាក់ព័ន្ធទៅនឹងសៀវភៅដែលដាក់ នៅចំពោះមុខអង្គសវនាការ ដូចគ្នាដែរចំពោះក្រុមមេធាវីការពារក្ដី លោក ខៀវ សំផន។ លោកអាច ឃើញនូវសៀវភៅ និងអត្ថបទស្រាវជ្រាវ ដែលមាននៅក្នុងឯកសារ E9/29.2 ដាក់នៅក្នុងឆ្នាំ២០១១ និងឯកសារមួយទៀត E109/1.1។

[១៤:២៨:១៣]

យើងឃើញមានបញ្ជីមួយទៀត ដែលយើងជឿថា អង្គសវនាការគួរតែពិចារណាផងដែរនៅ ពេលដែលពិចារណាទៅលើការជំទាស់ គឺបញ្ជីដាក់ជូនដោយក្រុមមេធាវីការពារក្ដី អៀង សារី ដែល បានដាក់នៅក្នុងខែមេសា រួមបញ្ចូលជាមួយនឹងបញ្ជីភស្តុតាង គឺឯកសារ E9/25.2 វាជាឯកសារមួយ ដែលមានច្រើនទំព័រ មានប្រហែលជា១០០ទំព័រ ហើយមានឯកសាររាប់ពាន់ ដែលថា សុំបញ្ចូលដាក់ ជាឯកសារភស្តុតាង ហើយនៅក្នុងហ្នឹងគឺមានឯកសារជាច្រើនចេញមកពីសារព័ត៌មានសៀវភៅ អត្ថបទ វិភាគ ឯកសាររបស់ ស៊ី.អាយ.អេ ឯកសាររបស់រដ្ឋាភិបាលបរទេស និងឯកសារដែលបានបង្កើត

ឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

យើងមិនបានជំទាស់ទៅនឹងឯកសារទាំងអស់នោះទេ វាសំខាន់ណាស់ប្រសិនបើមេធាវីការពារក្តីចង់ធ្វើការដាក់បញ្ចូលឯកសារទាំងនោះរួមជាមួយនឹងសាក្សីនោះ គឺធ្វើសំណើមក យើងចាត់ទុកថាវាជាឯកសារសំខាន់ ហើយវាជាការសំខាន់ដែលមេធាវីការពារក្តីត្រូវតែបង្ហាញភស្តុតាង និងឯកសារក្នុងការការពារក្តីរបស់ខ្លួនផងដែរ។

យើងខ្ញុំសូមកត់សម្គាល់ថា នៅពេលដែលមេធាវីការពារក្តីដាក់បញ្ជីវែងដូច្នោះ គឺគាត់គួរពិចារណាទៅលើការកោះហៅអ្នកនិពន្ធផងដែរ។ បើសិនជាគាត់ស្នើថាឲ្យកោះហៅគ្រប់អ្នកនិពន្ធទាំងអស់នោះ នោះគឺថាសវនាការនេះនឹងមិនចប់នោះទេ ក្នុងរយៈពេលខ្លីខាងមុខនេះ។

[១៤:២៥:៥៤]

នៅពេលនេះ ខ្ញុំសូមបញ្ចប់ ក៏ប៉ុន្តែខ្ញុំសូមលើកឡើងឯកសារមួយដែលគិតថា មេធាវីការពារក្តីមិនគ្រប់ក្រុមនោះទេ លើកឡើងឯកសារនេះ គឺឯកសារវិភាគដែលរៀបចំដោយលោក ក្រេក អេតធេសាន់ គឺ D2-15។ លោក ក្រេក អេតធេសាន់ បានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គចៅក្រម នៅក្នុងសំណុំរឿង ០០១។ លោក លោកស្រីចៅក្រមចាត់ទុកថា បទពិសោធន៍របស់គាត់មានភាពគ្រប់គ្រាន់អាចនាំគាត់មកផ្តល់សក្ខីកម្មអំពីរចនាសម្ព័ន្ធរបបកម្ពុជាប្រជាធិបតេយ្យ។ ជាការពិតយើងគាំទ្រសំណើសុំរបស់ក្រុមមេធាវីការពារក្តីមួយផ្នែក ដោយសារតែលោករូបនេះ គឺជាអ្នកជំនាញល្បីទៅលើប្រធានបទមួយនេះនៅក្នុងពិភពលោក ហើយលោក លោកស្រីចៅក្រមទុកចិត្តទៅលើអ្នកជំនាញរូបនេះ។

[១៤:២៦:៥៤]

មេធាវីក្រុមការពារក្តី អៀង សារី បានលើកឡើងហើយថា គឺគាត់មានវត្តមានអាចមកផ្តល់សក្ខីកម្មបាន។ ហើយយើងអាចលើកឡើងថា យើងរីករាយណាស់ ហើយយើងអាចទទួលយកនូវសក្ខីកម្ម និងឯកសាររបស់គាត់ដោយមិនមានអ្វីដែលយើងពន្យារពេលនោះទេ ប្រសិនបើចង់ស្នើឲ្យគាត់មកផ្តល់សក្ខីកម្មនោះ។

លោក លោកស្រីចៅក្រម ខ្ញុំសូមបញ្ចប់នូវសេចក្តីសន្និដ្ឋានរបស់ខ្ញុំត្រឹមនេះ។ នៅពេលដែលខ្ញុំពិនិត្យទៅមើលៗទៅលើពេលវេលាខ្ញុំនឹងផ្តល់វេទិកាទៅដល់សហសេវិករបស់ខ្ញុំ គឺលើកឡើងអំពីឯកសារ A-- ឧបសម្ព័ន្ធ១៤, ឧបសម្ព័ន្ធ២០ និងឧសម្ព័ន្ធ១៧។ ហើយខ្ញុំគិតថា នៅពេលនេះប្រហែលជាអង្គចៅក្រមចង់ធ្វើការសម្រាក ដោយសារតែយើងដល់ពេលវេលាហើយ។ សូមអរគុណ។

[១៤:២៧:៤៨]

**ប្រធានអង្គជំនុំ៖**

អរគុណតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:២៨ នាទី ដល់ម៉ោង ១៤:៥៣ នាទី)*

[១៤:៥៣:២៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសូមផ្តល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញាដើម្បីឡើងធ្វើសេចក្តីតបជាបន្ត។

សូមអញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

សូមអរគុណលោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព។

[១៤:៥៤:១០]

បាទ ខ្ញុំនឹងនិយាយអំពីឧបសម្ព័ន្ធទី១៤, ២០ និងឧបសម្ព័ន្ធ១៧។ ឧបសម្ព័ន្ធទី១៤ គឺទាក់ទងទៅនឹងរបាយការណ៍កំណត់អត្តសញ្ញាណទីតាំង គឺទាក់ទងទៅនឹងអត្ថបទពីរ គឺថាខាងការពារក្តីបាននិយាយដល់យូរលើឯកសារទាំងពីរនេះ។ គឺថាមានតែឯកសារទាំងពីរនោះទេ ប៉ុន្តែមិនមានដល់១៥១ នោះទេ។ របាយការណ៍នេះត្រូវបានជ្រើសរើសដោយការិយាល័យសហព្រះរាជអាជ្ញាថា មានភាពពាក់ព័ន្ធទាក់ទងទៅនឹងវគ្គទីមួយនៃការជម្រះសេចក្តីយើងនេះ។ យថាភាពនៃឯកសាររបាយការណ៍ទាំងពីរនេះ មិនអាចលើកជាបញ្ហាតាមវិចារណញាណបាននោះទេ ពីព្រោះថាអ្នកស៊ើបអង្កេតធ្វើឡើងដោយអ្នកស៊ើបអង្កេត

នៅការិយាល័យសហចៅក្រមស៊ើបអង្កេត គឺថាដោយសារមានចំណុចសម្គាល់ ឧទាហរណ៍ដូចជាពាក្យពេចន៍នៅលើក្បាលទំព័រ កាលបរិច្ឆេទ ឈ្មោះអ្នកស៊ើបអង្កេត ឬយោងទៅលើដីកាចាត់តាំង-- ចាត់ឲ្យស៊ើបជំនួស។ ហើយលើសពីនឹងទៅទៀត អ្នកស៊ើបអង្កេតទាំងអស់នោះសុទ្ធតែត្រូវបានទទួលស្គាល់ថា ជាអ្នកស៊ើបអង្កេត ដែលខ្លួនបានស្បថរួចហើយ។ អ៊ីចឹងរបាយការណ៍ទាំងអស់នេះ ត្រូវបានទទួលស្គាល់ថា យកជាការបានដោយសហចៅក្រមស៊ើបអង្កេត ដែលបានដាក់ចូលទៅក្នុងសំណុំរឿងតាមនីតិវិធីសមស្រប។

[១៤:៥៥:៥៣]

ដូច្នេះ ការជំទាស់របស់ភាគីការពារក្ដីទាក់ទងទៅនឹងភាពទទួលយកបាន ទុកចិត្តបាន និងតម្លៃជាភស្តុតាងនៃឯកសារទាំងពីរនេះ ដែលថាគេត្រូវតែផ្ដល់តម្លៃជាភស្តុតាងឲ្យ។ ក្រុមលោក សុន អរុណ បាននិយាយម្ដងទៀតនៅក្នុងសវនាការនូវឈ្មោះសាក្សី ដែលអាចនឹងហៅ នឹងកោះហៅមកបាន ដែលមាននៅក្នុងបញ្ជីសាក្សីដែលស្នើដោយភាគី គឺជាសាក្សី TCW-729 ដែលការកោះហៅរបស់គាត់មិនបានកោះហៅដោយសហព្រះរាជអាជ្ញាទេ ក៏ប៉ុន្តែដោយភាគីការពារក្ដីលោក ខៀវ សំផន។ ដូច្នេះ ការនិយាយឈ្មោះសាក្សីដែលនឹងកោះហៅមកនេះនៅក្នុងសវនាការសាធារណៈ មិនគួរត្រូវអត់ឱនឲ្យបានទេ ពីព្រោះថាកាលណាដែលនិយាយហើយ ហួសពេលហើយ ហើយកំហុសនោះបានធ្វើហើយ។ ដូច្នេះ ខាងសហព្រះរាជអាជ្ញាពិបាកនឹងធ្វើការជំទាស់ឲ្យមានប្រយោជន៍ណាស់។

[១៤:៥៦:៥៨]

អ៊ីចឹង ដូច្នេះយើងខ្ញុំសូមឲ្យអង្គជំនុំជម្រះធ្វើយ៉ាងណាកុំឲ្យការអនុវត្តបែបនេះត្រូវបានធ្វើឡើងម្ដងទៀត ហើយនិងសូមឲ្យព្រមានដល់ភាគីការពារក្ដីកុំឲ្យធ្វើដូច្នេះ ហើយនិងសូមរក្សាឈ្មោះអាថ៌កំបាំងរបស្សនាមរាល់សាក្សីណាដែលថា អាចនឹងកោះហៅនៅថ្ងៃអនាគត។ ដូច្នេះសូមឲ្យក្រុមមេធាវីការពារក្ដីលោក នួន ជា នេះត្រូវបានព្រមានដោយអង្គជំនុំជម្រះ។

ឯកសារទីមួយដែលមានលេខកូដ D232/108 ដែលធ្វើឡើងនៅថ្ងៃ០៧ មករា ឆ្នាំ២០១០ អនុលោមទៅតាមដីកាចាត់ឲ្យស៊ើបសួរជំនួសនៅថ្ងៃទី២៤ កក្កដា ឆ្នាំ២០០៩ នៅ--។ នេះ គឺជាបញ្ជីនៃទីតាំង និងអគារចំនួន២៦ នៅទីក្រុងភ្នំពេញដែលមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយដែលអ្នកស៊ើបអង្កេតបានព្យាយាមកំណត់អត្តសញ្ញាណ និងកំណត់ទីកន្លែងយ៉ាងច្បាស់លាស់ ហើយនិងថតរូបទៀតផង។

[១៤:៥៨:១៧]

ដូច្នេះវាមានជាការសំខាន់ណាស់ក្នុងការកត់សម្គាល់ថា របាយការណ៍នេះត្រូវបានធ្វើឡើងដើម្បីឆ្លើយតបទៅនឹងសំណើរបស់ភាគីការពារក្តីរបស់អ្នកស្រី អៀង ធីរិទ្ធ កាលពីថ្ងៃទី១៦ កញ្ញា ឆ្នាំ២០០៩ គឺដែលមានលេខកូដ D209។ ហើយទាក់ទងទៅនឹងខ្លឹមសារនៃរបាយការណ៍នេះ គឺរបាយការណ៍នេះបានពន្យល់យ៉ាងច្បាស់ថា ទីកន្លែង ឬក៏អគារមួយចំនួនមិនត្រូវបានកំណត់អត្តសញ្ញាណ ឬក៏កំណត់ទីតាំងដោយមិនអាចប្រកែកបាននោះទេ ពីព្រោះថាមានសក្ខីកម្មមួយចំនួនដែលមានភាពចម្រូងចម្រាស។ របាយការណ៍នេះក៏បានបង្ហាញផងដែរ នៅរាល់ពេលដែលអគារមួយដែលថាទំនងត្រូវបានធ្វើការកែប្រែទ្រង់ទ្រាយ ឬក៏បំផ្លាញទាំងស្រុងចាប់ពីឆ្នាំ១៩៧៩។

ឯកសារនេះក៏បង្ហាញផងដែរនៅប្រភពសាក្សី ឧទាហរណ៍ដូចជា សេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ ឬក៏សាក្សីដែលនឹងត្រូវកោះហៅមកផ្តល់សក្ខីកម្ម។ ហើយដូច្នេះរបាយការណ៍នេះ គឺថាមានលក្ខណៈសត្យានុម័ត ហើយនិងមានលក្ខណៈសុច្ឆន្ទៈ ហើយនិងមានភាពពាក់ព័ន្ធទៅក្នុងវគ្គទីមួយនៃការជម្រះសេចក្តីយើងនេះ។ ពីព្រោះវាពាក់ព័ន្ធទៅនឹងអគារដែលទាក់ទងទៅនឹងរចនាសម្ព័ន្ធរដ្ឋបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ឧទាហរណ៍យើងអាចរកឃើញៗ រូបថត ឬក៏របស់ការិយាល័យ ក-១, ក-៣ ដែលជាការិយាល័យរបស់លោក នួន ជា។ ការិយាល័យ ប-១ ដែល ឬក៏របស់ក្រសួងការបរទេស ហើយនិងក្រសួងផ្សេងទៀត។ ឧទាហរណ៍ដូចជាមន្ទីរ បេ-៣២ ក៏ដូចជាកន្លែងផ្សេងទៀតនៃរបបកម្ពុជាប្រជាធិបតេយ្យនោះ។ ឧទាហរណ៍ដូចជា មន្ទីរកា-១៥ វ៉ារទេះភ្លើង ឬក៏ស្ពាតអូឡាំពិក ឬក៏ជាអាសនៈនៃកងទ័ពបដិវត្តន៍កម្ពុជា ទាក់ទងទៅនឹងប្រព័ន្ធទំនាក់ទំនង ដូចជាមន្ទីរ ក-៧, ក-១៨ ជាដើម។ ដូច្នេះឯកសារទាំងអស់នេះនឹងអាចយកមកប្រើនៅពេលដែលភាគីចង់ចោទសំណួរទៅនឹងសាក្សី។

ដែលអ្វីដែលៗរបាយការណ៍នេះនាំផ្តល់មកនូវការពិភាក្សាក្នុងការពិភាក្សា គឺជាការធ្វើឲ្យយើងឃើញទីកន្លែង និងអគារទាំងអស់នេះ។ ដែលថាជាទូទៅ យើងនិយាយនៅក្នុងសវនាការ កន្លែង និងអគារទាំងអស់នេះត្រូវបានកំណត់ដោយឈរលើមូលដ្ឋាននៃសក្ខីកម្ម ហើយនិងត្រូវបានគាំទ្រ និងដោយឯកសារផ្សេងៗទៀត ហើយនេះអង្គជំនុំជម្រះជាអ្នកសម្រេចលើតម្លៃនៃឯកសារនេះ។

[១៥:០១:៥១]

ឥឡូវនេះ យើងមិនត្រូវនិយាយអំពីភាពទទួលយកបាននៃឯកសារនោះ ជាការពិភាក្សាលើភាពទទួលយកបាននៃឯកសារ ក៏ប៉ុន្តែមិននិយាយលើខ្លឹមសារនៃឯកសារនោះទេ។ នៅក្នុងចំណោមឯកសារ

រូបថតទាំង២៩ ដែលមាននៅក្នុងរបាយការណ៍នេះ ថាយើងមាននៅក្នុងឧបសម្ព័ន្ធទី១៥ នេះដោយសុទ្ធជាផែនទីរូបថត ដែលមានរូបថត D232/108 ដែលមានលេខជាបន្តបន្ទាប់ដូចលេខមួយ លេខពីរជាដើម។

ទាក់ទងទៅនឹងរបាយការណ៍កំណត់ទីតាំងភូមិសាស្ត្រនេះ ដែលមាន យើងមានឯកសារលេខ D369/38 ហើយឯកសារដើមជាភាសាអង់គ្លេស។ យើងមានរូបថតចំនួន៣៨ ដែលធ្វើនៅនឹងកន្លែង អូ! ៣១ ធ្វើនៅនឹងកន្លែង ហើយដែលនឹងភ្ជាប់ទៅនឹងរបាយការណ៍នេះ។ របាយការណ៍នេះទាក់ទងទៅនឹងច្រាំងចម្រេះ ដែលថាមន្ទីរម-១ ឬក៏ ប-៦០ ហើយវាពាក់ព័ន្ធទៅនឹងវគ្គទីមួយនៃការជម្រះសេចក្តីនេះ ដោយហេតុថាវាមាន វាទាក់ទងទៅនឹងអង្គការ មន្ទីរមួយ និងជំរំការងារដែលចំពោះយើង ថាស្ថិតនៅវាមន្ទីរនេះនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងការបរទេស ហើយនិងរបស់លោក អៀង សារី នៅយ៉ាងហោចណាស់នៅក្នុងរយៈកាលរបបកម្ពុជាប្រជាធិបតេយ្យ។

ដោយដឹងថា សាក្សីនៃក្រសួងនេះនឹងត្រូវស្តាប់យកយកចម្លើយនៅពេលក្រោយ នៅក្នុងវគ្គទីមួយនេះ ដែលទាក់ទងទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល។ ដូច្នេះវាហាក់ដូចជាចង្អុលបង្ហាញឲ្យឃើញថា របាយ-ការណ៍នេះត្រូវបានទទួលស្គាល់ថាមានភាពពាក់ព័ន្ធ ទាំងផ្នែករចនាសម្ព័ន្ធរដ្ឋបាលនៃក្រសួងការបរទេស ទាំងតួនាទីរបស់ជនជាប់ចោទលោក អៀង សារី ដែលជាអ្នកដឹកនាំក្រសួងនេះ។

[១៥:០៤:១៥]

ទាក់ទងទៅនឹងការដែលរបាយការណ៍នេះ មានមូលដ្ឋានលើសាក្សី TCW-729 ដែលគាត់ត្រូវបានស្តាប់យកចម្លើយពីរដង ដោយសហចៅក្រមស៊ើបអង្កេត គឺ D369/18 និង D233/14។ សាក្សីនេះស្ថិតនៅក្នុងបញ្ជីសាក្សីដែលក្រុម ខៀវ សំផន បានស្នើ។ ខ្ញុំគិតថា វាមិនទាន់ដល់ពេលទេ នៅពេលនេះក្នុងការពិភាក្សាទៅលើភាពទុកចិត្តបាននៃសក្ខីកម្មរបស់គាត់។

[១៥:០៥:០០]

អ៊ីចឹងយើងត្រូវចាំថា ដំបូងត្រូវចាំដឹងថា តើសាក្សីនេះអង្គជំនុំជម្រះទទួលយកគាត់ដើម្បីមកធ្វើសក្ខីកម្ម ឬក៏អត់? ហើយទីពីរ បើសិនជាពុំដូច្នេះទេត្រូវតែដឹងថា តើជោគវាសនាដែលអង្គជំនុំជម្រះផ្តល់ទៅដល់កំណត់ហេតុស្តាប់ចម្លើយសាក្សីដែលមាននៅក្នុងឧបសម្ព័ន្ធ១២ នោះយ៉ាងណា? បើសិនជាកំណត់ហេតុទាំងអស់នេះត្រូវអាចប្រើបានជាភស្តុតាងដោយទាំងស្រុង ឬក៏ដោយផ្នែក ដោយហេតុថាវាមិនពាក់ព័ន្ធទៅនឹងទង្វើរបស់ជនជាប់ចោទ ដូច្នេះជោគវាសនាដែលយើងផ្តល់ទៅឯកសារទាំងស្រុង ឬ

ក៏ដោយផ្នែក ដែលប្រភេទឯកសារដូចគ្នានេះក៏ត្រូវតែធ្វើដូចគ្នាដែរ។ ទាក់ទងទៅនឹងសាក្សី TCW-729 ដែលថាគាត់នោះប្រហែលជាមានភាពលម្អៀងនៅក្នុងការស្រាវជ្រាវរកឯកសារដែលដាក់តែបន្ទុក។

[១៥:០៦:១៣]

គឺថាដោយសារគាត់លើកឡើង-- មានការលើកឡើងថាគាត់ធ្វើការអះអាងដោយគ្មានសំអាងហេតុ សាក្សីនេះគឺត្រូវបានគេស្តាប់ពីរដងរួចមកហើយ ដែលគាត់បានស្បថ គាត់បានគូសបង្ហាញថា គឺអ្នកស៊ើបអង្កេតរបស់ចៅក្រមស៊ើបអង្កេតដែលបានបញ្ជាក់ថា គាត់បានបង្ហាញនូវទីកន្លែងច្រាំងចំរេះនេះ។

នៅក្រោមរបបខ្មែរក្រហម នៅកន្លែងដូចគ្នា នៅកន្លែងធ្វើការជាមួយគ្នា ហើយទោះបីជាៗក្មេងជំទង់ក៏ដោយ ហើយពុំមានអ្វីដែលអាចបញ្ជាក់ថា ការចងចាំនៅកន្លែងនេះមិនអាចថាគាត់មិនចាំបាននោះទេ។ ក៏ប៉ុន្តែផ្ទុយទៅវិញ ទោះបីជាក្មេងក៏ដោយគឺថា គាត់មានការចងចាំដែលមិនអាចបំភ្លេចបាន។ ហើយយើងគួរតែយល់ត្រង់ចំណុចនេះផងដែរ។

[១៥:០៧:២៧]

ឥឡូវនេះខ្ញុំចូលទៅដល់ឧបសម្ព័ន្ធទី២០ ដែលជារបាយការណ៍ចាត់ឲ្យស៊ើបជំនួស។ ភាគីការពារក្តីរបស់ នួន ជា បានលើកឡើង ធ្វើការកត់សម្គាល់តែមួយទេលើរបាយការណ៍នេះ។ គាត់បានលើកឡើងថា យើងត្រូវតែពិចារណាដោយប្រុងប្រយ័ត្ន ដោយសារសហចៅក្រមស៊ើបអង្កេតមានភាពលម្អៀង។ ភាពលម្អៀងរបស់សហចៅក្រមស៊ើបអង្កេតនេះមិនត្រូវបានផ្តល់បង្ហាញថាមាននោះទេ។ តាមពិតទៅគឺថាគ្រាន់តែជាការ-- មិនមែនជាការជំទាស់បដិសេធជាក់លាក់ ដែលពាក់ព័ន្ធ ឬក៏មានលក្ខណៈដែលថាអាចលើកយកមកជាបញ្ហានៃភាពពាក់ព័ន្ធ និងយកថាភាពនៃឯកសារនោះទេ។

[១៥:០៨:២៧]

ភាគីខាង អៀង សារី ក៏បានលើកឡើងថា របាយការណ៍នេះមិនអាច-- មិនត្រូវអាចទទួលយកបាននោះទេ ហើយខាងមេធាវី ខៀវ សំផន ក៏បានគាំទ្រផងដែរ។ លោក អាង ឧត្តម នៅថ្ងៃទី10 មករា ឆ្នាំ២០១២ នៅពេលដែលគាត់បានសួរសំណួរទៅ រម៉ាម យុន គាត់មិនបានហាមខ្លួនឯងក្នុងការប្រើរបាយការណ៍នេះ របាយការណ៍ដែលមានលេខ D208/2 នេះទេ ហើយជាពិសេសគឺការកត់សម្គាល់រិះគន់នៃ ទៅលើអ្នកស៊ើបអង្កេតទាក់ទងទៅនឹងសេចក្តីប្រកាសមួយចំនួនដែលគាត់បានប្រមូលនោះ។

ប្រភេទឯកសារទាំងអស់នេះ គឺតម្រូវឲ្យមានការកត់សម្គាល់មួយចំនួន។ ទីមួយ គឺទាក់ទងទៅនឹងរបាយការណ៍ ទាក់ទងទៅនឹងកកំណត់ទីតាំង យថាភាពរបស់ឯកសារទាំងនេះ យើងមិនអាចលើក

យកមកជាបញ្ហាណាស់ ដោយសារថា ធ្វើឯកសារទាំងអស់នេះ សុទ្ធតែមាននិទ្ទេស ដែលខ្ញុំបានបង្ហាញពីលើហើយ មានការបរិច្ឆេទ មានទ្រង់ទ្រាយនៅលើទំព័រជាដើម។

[១៥:០៩:៥៦]

យើងត្រូវតែបែងចែកឯកសារនេះជាច្រើនប្រភេទតូចៗ មានប្រភេទមួយតូចមួយដែលមាន៣១ឯកសារ របាយការណ៍ទាំង៣១ ឬក៏កំណត់ហេតុដែលទាក់ទងទៅនឹងបញ្ជី ឬក៏ការពិពណ៌នានៃឯកសារលាយលក្ខណ៍ជាអក្សរ ឬក៏ឯកសារសោតទស្សន៍ដែលសហចៅក្រមស៊ើបអង្កេតទទួលបានពីអង្គការផ្សេងៗ។ ឧទាហរណ៍ដូចជា មជ្ឈមណ្ឌលបុប្ផាណា ឯកសារមានប្រាំបីស្ថិតនៅក្នុង-- ឯកសារចំនួនទាំង១០២ គឺថាចេញពីមកមជ្ឈមណ្ឌលនុំង មានមន្ទីរទួលស្លែង គឺថាមានពីរឯកសារ ហើយនិងមជ្ឈមណ្ឌលឯកសារកម្ពុជាមាន២០ឯកសារ ដែលបង្ហាញពីលក្ខខណ្ឌ ដែលថាតើឯកសារនេះទទួល បានក្នុងលក្ខខណ្ឌណា ហើយមួយឯកសារមួយទៀត ដែលទាក់ទងទៅនឹងបណ្ណសារជាតិនៅប្រទេសកម្ពុជា។ បន្តិចទៀតនេះ សហភាតារបស់ខ្ញុំនឹងនិយាយពីឯកសារដែលទាក់ទងទៅនឹងពាណិជ្ជកម្ម។ របាយការណ៍ទាំងអស់នេះ អាចឲ្យយើងបង្ហាញថា តើឯកសារភស្តុតាងទាំងអស់នេះ ដែលថាសហចៅក្រមស៊ើបអង្កេតបានបញ្ចូលនៅក្នុងឯកសារនេះ ត្រូវបានទទួលបានតាមវិធីណា ហើយនិងបង្ហាញផងដែរនូវខ្សែសង្វាក់នៃការថែរក្សា ការកាន់កាប់ឯកសារ។ ដូច្នេះ ឯកសារនេះត្រូវតែអាចទទួលយកបានអំពីសំណាក់អង្គជំនុំជម្រះ។

[១៥:១១:៥៤]

ឯកសារប្រភេទមួយទៀតនោះមានលក្ខណៈស្មុគស្មាញ គឺរបាយការណ៍ស្តីពីចាត់ឲ្យស៊ើបសួរជំនួស៦៦ ដែលពាក់ព័ន្ធទៅនឹងការស្តាប់សក្ខីកម្មសាក្សី ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីដោយសហចៅក្រមស៊ើបអង្កេត។ ជាញឹកញាប់ យើងដឹងថា អ្នកស៊ើបអង្កេតគឺបានធ្វើការសង្ខេបនូវការស្តាប់ចម្លើយនេះសម្រាប់សហចៅក្រមស៊ើបអង្កេត គឺថាវាមានតម្លៃគ្រាន់តែជាព័ត៌មានធម្មតាប៉ុណ្ណោះ។ ក៏ប៉ុន្តែជួនកាលអ្នកស៊ើបអង្កេតបានរៀបរាប់អំពីកាលៈទេសៈដែលនៅជុំវិញ ការស្តាប់ចម្លើយ ហើយក៏បានបញ្ជាក់អំពីចំនួនមនុស្សមួយចំនួនដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងពេលធ្វើបេសកកម្មនោះ ហើយនិងបុគ្គលដែលត្រូវបាន បុគ្គលដែលនឹងសម្ភាស ឬក៏នឹងត្រូវកំណត់អត្តសញ្ញាណ។ ហើយរបាយការណ៍ចំនួនទៀតគឺត្រូវបានដំណើរការដើម្បីកំណត់អត្តសញ្ញាណ ឬសួរសាក្សី ប៉ុន្តែដំណើរការទាំងអស់នេះ គឺថាមិនអាចបានបញ្ចប់នោះទេ។ យើងឯកភាពថា ពាក់ព័ន្ធទៅនឹងរបាយការណ៍ទាំង៦៦នេះ គឺជាគោលការណ៍

គឺយើងត្រូវយោងទៅច្បាប់ដើមនៃការផ្តល់សក្ខីកម្មជាជាងទៅលើការផ្តោតទៅលើការសង្ខេបដោយអ្នកស៊ើបអង្កេត។ ទោះជាយ៉ាងក៏ដោយ យើងចង់ឲ្យឯកសាររបាយការណ៍ទាំងអស់នេះ ត្រូវទទួលយកដោយអង្គជំនុំជម្រះសាលាដំបូង។ ហើយខ្ញុំសូមឲ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេចនៅពេលក្រោយ គឺពាក់ព័ន្ធទៅនឹងការសម្រេចទៅលើការស៊ើប-- ទៅលើកំណត់ហេតុដែលមាននៅក្នុងឧបសម្ព័ន្ធ១២ ដែលមិនមែនជាការពិភាក្សានៅថ្ងៃនេះទេ។

[១៥:១៣:៤៤]

គឺវាមាន គឺជាការត្រូវធ្វើជាសារណាជាលាយលក្ខណ៍អក្សរ។ ក្នុងចំណោមរបាយការណ៍ទាំង ៦៦ នេះ គឺ៥៤ ពាក់ព័ន្ធទៅនឹងការស្តាប់ចម្លើយសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី ដែលមានឈ្មោះនៅក្នុងបញ្ជី E9/35 ហើយយើងដឹងហើយថា នៅក្នុងបញ្ជីនេះ គឺមានការចុះនូវរហស្សនាមរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលស្នើឡើងដោយភាគីទាំងអស់។

អង្គជំនុំជម្រះបានបញ្ជាក់ជូនភាគីហើយថា សាក្សី ហើយនិងដើមបណ្តឹងទាំងអស់នេះ គឺថានឹងត្រូវស្តាប់ចម្លើយនៅក្នុងឆ្នាំនេះ នៅក្នុងក្របខ័ណ្ឌនៃសវនាការនេះ។ នេះមិនមែនមានន័យថា សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត ដែលមាននៅក្នុងបញ្ជី E9/35 នេះ មិនត្រូវបានស្តាប់ចម្លើយនៅក្នុងវគ្គដំបូងនៃសវនាការនេះទេ។

ដូច្នេះ យើងត្រូវតែមានការប្រុងប្រយ័ត្ន ពីព្រោះថានៅពេលដែលសាក្សី ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់ដែលនឹងត្រូវធ្វើសក្ខីកម្មនៅសវនាការនោះ ខ្ញុំគិតថាភាគីទាំងអស់ ហើយនិងចៅក្រមទាំងអស់ គឺថាគាត់ពេញចិត្តក្នុងការធ្វើយ៉ាងណាឲ្យទទួលបាននូវរាល់ព័ត៌មានចាំបាច់ទាំងអស់ ធាតុពាក់ព័ន្ធទៅនឹងសក្ខីកម្មទាំងអស់នេះ។ ហើយជាពិសេស គឺថាយើងចង់បានព័ត៌មានដែលមានដូចនៅក្នុងរបាយការណ៍ស្តីពីការចាត់ឲ្យស៊ើបសួរជំនួសពាក់ព័ន្ធទៅនឹងបុគ្គលទាំងអស់នេះ។

[១៥:១៥:៣០]

លើសពីនេះទៅទៀត បន្ថែមទៅលើកំណត់ហេតុស្តាប់ចម្លើយសាក្សី ហើយនិងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នេះ។ សហព្រះរាជអាជ្ញាសូមឲ្យរបាយការណ៍ទាំង៥៤នេះ ត្រូវបានទទួលយកដោយសារតែឯកសារទាំងអស់នោះ គឺពាក់ព័ន្ធទៅនឹងសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងត្រូវស្តាប់ចម្លើយនាពេលខាងមុខនេះ។ ដូច្នេះអង្គជំនុំជម្រះមានអំណាចឆន្ទានុសិទ្ធិក្នុងការវិនិច្ឆ័យថា របាយការណ៍ទាំងអស់នោះមានសារៈសំខាន់ក្នុងការសំដែងឲ្យឃើញនូវការពិត។

លោកប្រធាន លោក លោកស្រីចៅក្រម វាមិនដូចអ្វីដែលលោក កាណាវាស គឺជាមេធាវីការពារក្តីរបស់ អៀង សារី បានលើកឡើងថា គឺជាផែនការរបស់សហព្រះរាជអាជ្ញាក្នុងការប្រើប្រាស់សេចក្តីសង្ខេបនៃសេចក្តីថ្លែងការណ៍របស់សាក្សីនៅក្នុងរបាយការណ៍ទាំងអស់នោះទេ នៅពេលដែលសាក្សីទាំងអស់នេះមិនត្រូវបានកោះហៅឲ្យបង្ហាញមុខនោះ។

[១៥:១៦:៣៧]

ក្រៅពីរបាយការណ៍ពាក់ព័ន្ធទៅនឹងការស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលមាននៅក្នុងបញ្ជីយើងមានរបាយការណ៍ផ្សេងទៀតដែលមិនមានពាក់ព័ន្ធទៅនឹងសាក្សី ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមាននៅក្នុងបញ្ជី E9/35 នេះទេ គឺមានយ៉ាងហោចណាស់១២។ ឧទាហរណ៍ឯកសារលេខ D125/189, ឯកសារ D125/193, ឯកសារ D125/208, ឯកសារ D166/134, ឯកសារ D125/212 ចំពោះរបាយការណ៍ជាក់លាក់ទាំងអស់នេះ យើងខ្ញុំស្នើសុំឲ្យមានការទទួលយកនូវកំណត់ហេតុស្តាប់ចម្លើយសាក្សីដែលនៅឧបសម្ព័ន្ធ១២ ហើយនិងមានការសម្រេចពាក់ព័ន្ធទៅនឹងលទ្ធភាពក្នុងការយោងទៅលើឯកសារទាំងអស់នេះនៅពេលដែលសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីមិនបានមកបង្ហាញមិនត្រូវបានកោះបង្ហាញ មកបង្ហាញខ្លួនដោយសារតែមូលហេតុផ្សេងៗនោះ។

[១៥:១៨:០៦]

ប្រសិនបើអង្គជំនុំជម្រះសម្រេចទទួលយកកំណត់ហេតុស្តាប់ចម្លើយដោយផ្នែក ឬក៏ទាំងស្រុងដោយមិនឲ្យសាក្សីឬក៏ដើមបណ្តឹងរដ្ឋប្បវេណីមកឲ្យភាគីផ្សេងៗសួរនិងដេញដោលនោះ។ ដូច្នេះរបាយ-ការណ៍ទាំងអស់នេះក៏ត្រូវទទួលយកបានដែរ ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថាមានភាពពាក់ព័ន្ធហើយនិងមានសារៈសំខាន់ក្នុងការសម្តែងនិងលាតត្រដាងឲ្យឃើញនូវការពិត ឬក៏ឯកសារទាំងអស់នេះអាចប្រើជាឧបករណ៍សម្រាប់ជាប្រយោជន៍ទៅដល់ភាគីផ្សេងៗ។

តម្លៃជាភស្តុតាងដែលផ្តល់ទៅឲ្យឯកសារនេះ អាចតិចជាងតម្លៃភស្តុតាងដែលផ្តល់ទៅឲ្យច្បាប់ដើមនៃកំណត់ហេតុស្តាប់ចម្លើយ។ ប៉ុន្តែជាថ្មីម្តងទៀត គឺអង្គជំនុំជម្រះជាអ្នកវិនិច្ឆ័យទៅលើបញ្ហានេះ គឺថាយើងអាចធ្វើការបែងចែករវាងសក្ខីកម្មជាលាយលក្ខណ៍អក្សរដែលពាក់ព័ន្ធផ្ទាល់ទៅនឹងអំពើ និងអាប្បកិរិយារបស់ជនជាប់ចោទ ហើយនិងសក្ខីកម្មផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មផ្ទាល់ដោយមិនបានបញ្ចេញឈ្មោះ ឬក៏មានបង្ហាញពីភាពពាក់ព័ន្ធរបស់សាក្សី។

[១៥:១៩:១២]

នៅក្នុងសម្មតិកម្មនេះ ការបែងចែងនេះក៏អនុវត្តផងដែលចំពោះរបាយការណ៍ស្តីពីការចាត់ឲ្យស៊ើបសួរជំនួសពាក់ព័ន្ធទៅនឹងសាក្សីទាំងអស់នេះ។ ទោះយ៉ាងណាក៏ដោយ ការសម្រេចទៅលើឯកសារទាំង១២នេះ គឺពាក់ព័ន្ធទៅនឹងឧបសម្ព័ន្ធ១២ ហើយការសម្រេចនៅពេលនេះ គឺថាវាមានលក្ខណៈឆាប់រហ័សពេក។

ជាចុងក្រោយ ខ្ញុំសូមបញ្ជាក់ថាក្នុងចំណោមឯកសារទាំង១១២ ដែលមាននៅក្នុងឧបសម្ព័ន្ធ២០នេះ គឺពាក់ព័ន្ធទៅនឹងកាលៈទេសៈនៃការចាប់ខ្លួនជនជាប់ចោទ ហើយនិងវត្ថុតាងដែលបានរឹបអូសនៅផ្ទះរបស់ជនជាប់ចោទនៅក្នុងឱកាសនោះ។ ដោយសារតែវត្ថុតាងទាំងអស់នោះ គឺមិនមាននៅក្នុងបញ្ជីឯកសាររបស់ភាគីនៅក្នុងក្របខ័ណ្ឌនៃវគ្គដំបូងនៃសវនាការនេះ យើងជឿទុកចិត្តទៅលើតុលាការក្នុងការសម្រេចអំពីភាពពាក់ព័ន្ធរបស់វា។

ខ្ញុំសូមបញ្ចប់ការអង្កេតការកត់សម្គាល់ទៅលើឧបសម្ព័ន្ធ២០ ហើយខ្ញុំសូមចូលទៅលើឧបសម្ព័ន្ធ១៧ ដែលពាក់ព័ន្ធទៅនឹងទំនាក់ទំនងអន្តរជាតិ។

ឯកសារ១៥៨ ដែលបានដាក់ចូលទៅក្នុងផ្នែកនេះ ដោយសហព្រះរាជអាជ្ញា គឺមាននៅលើបញ្ជីដែលបានធ្វើកាលពីខែកក្កដា ឆ្នាំ២០១១ គឺឯកសារលេខ E109/4.17។ ឯកសារទាំងអស់នេះ គឺពាក់ព័ន្ធនឹងវគ្គទីមួយនៃសំណុំរឿង០០២ ហើយមានតែឯកសារ១៥១ ប៉ុណ្ណោះ ដែលត្រូវបានជជែកដេញដោលនៅថ្ងៃនេះ។ ជាក់ស្តែងឯកសារពីរត្រូវបានជជែកដេញដោលរួចមកហើយកាលពីថ្ងៃទី១៦ មករា ឆ្នាំ២០១២ ហើយឯកសារប្រាំពីរផ្សេងទៀត គឺត្រូវបានពិភាក្សានៅក្នុងសវនាការ ១៦ ខែកុម្ភៈ ២០១២។ ដូច្នេះ ឯកសារនេះ គឺវាមិនមែនជាឯកសារដែលជជែកដេញដោលនៅថ្ងៃនេះទេ។

[១៥:២១:៣៣]

លោក កាណាវាស គាត់បានច្រឡំហើយ ដោយគាត់លើកឡើងនៅក្នុងសវនាការ ដែលគាត់លើកអំពីឯកសារលេខ D2-15.1 គឺយើងត្រូវ-- ឯកសារនេះត្រូវតែអានរួមគ្នាជាមួយនឹងឯកសារលេខ D83-Annex-00011។ នេះគឺជាឯកសារដែលយើងហៅថា “ស្វ័យជីវប្រវត្តិរបស់ កែ ពក”។ ឯកសារនេះគឺត្រូវបានជជែកដេញដោលរួចមកហើយ ពីព្រោះឯកសារនេះមាននៅក្នុងជើងទំព័រនៃផ្នែកពាក់ព័ន្ធនៃដីកាដំណោះស្រាយ។ អ៊ីចឹងឯកសារនេះគឺត្រូវបានជជែកដេញដោលរួចមកហើយ។ ទោះជាយ៉ាងណាក៏ដោយ យើងមិនបានឮការជំទាស់ពាក់ព័ន្ធទៅនឹងឯកសារនេះនោះទេ។ ប៉ុន្តែគ្រាន់តែជាការរអ៊ូរទាំ ដែលបញ្ជាក់ថា ឯកសារនេះត្រូវបានចាត់ថ្នាក់មិនត្រឹមត្រូវ ហើយយើងទទួលយកការរិះគន់នេះ ពីព្រោះថា

ឯកសារនេះមិនគួរស្ថិតនៅក្នុងចំណាត់ថ្នាក់នៃឯកសារទំនាក់ទំនងអន្តរជាតិនោះទេ។ ហើយខាងមេធាវីការពារក្តី នួន ជា លោក អ៊ីនូហ្ស៊ី មិនបានបដិសេធដាច់អហង្ការនូវប្រភេទនៃឯកសារនេះទេ ដោយសារតែវាមានលើកឡើងនូវការទំនាក់ទំនងមួយចំនួនជាភស្តុតាង។

ដូច្នេះ យើងអាចប្រមូលឯកសារទាំង១៥៨នេះ ហើយមកដាក់ជាគឺ-- (សុំទោស) គឺ១៤៩ ទេ គឺយើងអាចដាក់ជាប្រភេទមួយៗ គឺមាន១១០ ឯកសារ ដែលចេញមកពីក្រសួងការបរទេសបារាំង ហើយមាន៧៨ ដែលមានមកពីសហរដ្ឋអាមេរិក ហើយមានបួនមកពីអង្គការលើកលែងទោសអន្តរជាតិ បីមកពីវៀតណាម។

[១៥:២៣:៤៣]

ខ្ញុំនឹងនិយាយអំពីប្រភេទទីមួយ គឺឯកសារដែលចេញមកពីក្រសួងការបរទេសបារាំង គឺឯកសារ៧០។ ឯកសារ៧០នេះ គឺថាមានចេញមកពីបណ្ណសារដ្ឋានបារាំង ដែលត្រូវបានពិគ្រោះដោយអ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេតដោយមានការអនុញ្ញាតពីក្រសួងការបរទេសបារាំង ឆ្លើយតបទៅនឹងដីកាចាត់ឲ្យស៊ើបសួរជំនួសអន្តរជាតិរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៩ ដែលមានលេខយោង D199។ តើនេះជាឯកសារអ្វីដែរ? វាជាឯកសារនៅសម័យនោះ ដែលមានកើតឡើងនៅចន្លោះខែធ្នូ ៧៣ ទៅដល់ខែធ្នូ ៧៨។

ជាសំខាន់ឯកសារទាំងអស់នេះ សុទ្ធសឹងតែជាទូរលេខ ឬរបាយការណ៍ ដែលបានផ្លាស់ប្តូរគ្នារវាងស្ថានទូតបារាំងប្រចាំនៅអាស៊ី ហើយនិងក្រសួងការបរទេសបារាំងនៅទីក្រុងប៉ារីស។ ជាពិសេសគឺនាយកដ្ឋានអាស៊ីអូសេអានី។ ដូច្នេះទូរលេខ២១ ចេញមកពីស្ថានទូតបារាំង ប្រចាំនៅទីក្រុងប៉េកាំង ១៨ពីស្ថានទូតទីក្រុងភ្នំពេញមុនពេលបិទទ្វារ ៩ចេញពីស្ថានទូតនៅបាងកក ២ចេញពីស្ថានទូតហាណូយ ហើយមួយទៀតចេញមកពីស្ថានទូតគូឡាឡាំពួ វៀងចន្ទន៍ ញូវយ៉ក និងអតីយូហ្កោស្លាវី។

ការប្រាស្រ័យ-- ឯកសារ១១ គេចេញមកពីក្រសួងការបរទេសបារាំង ហើយ៥ត្រូវបានផ្ញើដោយក្រសួងការពារជាតិបារាំងជូនក្រសួងការបរទេសមុនពេលការដកស្ថានទូតបារាំងប្រចាំនៅទីក្រុងភ្នំពេញចេញ គឺក្រោយការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។

[១៥:២៥:៤៤]

ពាក់ព័ន្ធទៅនឹងយថាភាព។ ដីកាចាត់ឲ្យស៊ើបសួរអន្តរជាតិ លេខ D199 គ្របដណ្តប់ទៅលើទិដ្ឋភាពផ្សេងៗ ដូចជាការស្តាប់ចម្លើយសាក្សីមួយចំនួន និងដើមបណ្តឹងរដ្ឋប្បវេណីមួយដែលមានទី

លំនៅនៅប្រទេសបារាំង ក៏ដូចជាការស្រាវជ្រាវនៅចំពោះបណ្ណសារដ្ឋាននៃក្រសួងការបរទេសបារាំង មាននៅក្នុងឧបសម្ព័ន្ធ៤ នៃឯកសារ D199។

ជាថ្មីម្តងទៀត នេះគឺជាប្រភេទនៃឯកសារដែលថា វាមិនមានភាពសមហេតុផលនោះទេនៅក្នុងជំទាស់អំពីយថភាពនោះ។ នេះគឺជាឯកសារដែលបានថតចម្លងជាផ្លូវការដោយអាជ្ញាធរតុលាការបារាំង ដោយមានការគាំពារអំពីអ្នកស៊ើបអង្កេតនៃការិយាល័យសហព្រះរាជអាជ្ញានៅបណ្ណសារដ្ឋាននៃរដ្ឋាភិបាលបារាំង ដែលធានាជាផ្លូវការនូវប្រភពនៃឯកសារទាំងអស់នេះ។ ដូច្នេះ មិនមានបញ្ហាយថាភាព ឬក៏ខ្សែសង្វាក់នៃការថែរក្សាឯកសារទាំងអស់នោះទេ។

[១៥:២៦:៥4]

នៅក្នុងឯកសារ D199/2 ស្ថានទូតបារាំងប្រចាំនៅប្រទេសកម្ពុជាបានអនុញ្ញាតឲ្យមានការធ្វើដំណើរនូវអ្នកស៊ើបអង្កេតទៅប្រទេសបារាំង ហើយធានានូវការចូលទៅមើលបណ្ណសារការទូតរបស់ក្រសួងការបរទេស។ នៅទំព័រដំបូងនៃឯកសារ D199/3 ដែលត្រូវបានធ្វើឡើងដោយអ្នកស៊ើបអង្កេតពីរដែលបានធ្វើដំណើរទៅប្រទេសបារាំង ហើយក្នុងឯកសារនោះបញ្ជាក់ថា ឯកសារ៦០៥ ត្រូវបានទទួលពីបណ្ណសារដ្ឋាននៃក្រសួងការបរទេសបារាំង។

នៅក្នុងឯកសារតុលាការផ្សេងៗ អាជ្ញាធរតុលាការបារាំងបានបញ្ជាក់ថា ឯកសារទាំងអស់នោះត្រូវបានទទួលពីបណ្ណសារដ្ឋាននៃក្រសួងការបរទេស ហើយលោក លោកស្រីអាចមើលនៅក្នុងឯកសារ D195/5 គឺជាកំណត់ហេតុសំយោគ ស្តីអំពីដីកាចាត់ឲ្យស៊ើបសួរជំនួស។ សហចៅក្រមស៊ើបអង្កេតបន្ទាប់ពីបានវិភាគទៅលើបណ្ណសារទាំងអស់នេះហើយ បានសម្រេចដាក់បញ្ចូលឯកសារមួយចំនួនទៅក្នុងសំណុំរឿង តាមរយៈសេចក្តីសម្រេចពាក់ព័ន្ធទៅនឹងការដាក់ឯកសារចូលទៅក្នុងសំណុំរឿង ដែលមានលេខយោង D199/26.2។ ហើយក៏មានសម្រេចថា ឯកសារដែលមានមកពីប្រភពដូចគ្នានេះ គឺនឹងដាក់ទៅក្នុង*ហ្វូលឌ័រ* នៃឯកសាររួម តាមរយៈសេចក្តីសម្រេចលេខ D199/26.3។

[១៥:២៨:៥៨]

ពាក់ព័ន្ធទៅនឹងភាពពាក់ព័ន្ធនៃឯកសារទាំងអស់នេះ គឺឯកសារនេះ ពិតជាមានពាក់ព័ន្ធបំផុតពីព្រោះថាវាពាក់ព័ន្ធទៅនឹងបរិបទប្រវត្តិសាស្ត្រ។ ឯកសារប្រាំបួនដែលកើតឡើងនៅមុនថ្ងៃ១៧ មេសា ឆ្នាំ៧៥។ ឯកសារនេះក៏ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរដ្ឋបាលនៃរបបខ្មែរក្រហម តួនាទីរបស់ជនជាប់ចោទនីមួយៗនៅមុន ក្នុងអំឡុងពេល និងអំឡុងពេលរបបខ្មែរក្រហម ហើយនិងពេលជម្លៀសប្រជាជនចេញ

ពីទីក្រុងភ្នំពេញ ហើយនិងជោគវាសនារបស់ខ្មាំងនៅក្នុងអំឡុងពេលជម្លៀសប្រជាជននោះ។ ហើយយើងមានឯកសារយ៉ាងច្រើន ដែលចេញមកពីស្ថានទូតបារាំងប្រចាំនៅទីក្រុងភ្នំពេញ ដែលបានរៀបរាប់ពីមួយថ្ងៃទៅមួយថ្ងៃ អំពីកាលៈទេសៈដែលខ្មាំងមាន-- ដែលខ្មាំងស្ថិតនៅជាមួយនឹងជនបរទេស ដែលមាននៅក្នុងស្ថានទូត ហើយរហូតដល់ពេលដែលពួកគេត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ។

[១៥:៣០:១២]

ចំពោះយថាភាព ភាពអាចជឿជាក់បាននូវឯកសារទាំងអស់នោះ ខ្ញុំសូមគូសបញ្ជាក់ថា មេធាវីការពារក្តី ខៀវ សំផន បានជ្រើសរើសក្នុងការជឿជាក់ទៅលើឯកសារប្រភេទនេះ ពីព្រោះថាខ្លួនបានជ្រើសរើសដោយខ្លួនឯងនូវឯកសារចំនួនប្រាំបី ដែលប្រភេទដូចគ្នានេះ ខ្ញុំចំណោមបញ្ជីឯកសារដែលបានដាក់ជូននៅចំពោះមុខអង្គជំនុំជម្រះកាលពីខែមេសា និងខែកក្កដា ឆ្នាំ២០១១ គឺឯកសារលេខ E9/29.2 និងឯកសារ E109/1.1។

នៅក្នុងសវនាការ ខ្ញុំបានឮមេធាវី ហ្គីសសេ បាននិយាយថា ឯកសារទាំងអស់នេះមិនគួរទទួលយកទេ។ ដូច្នេះនេះមានភាពចម្រូងចម្រាសគ្នាហើយ ហើយខ្ញុំនឹងបង្ហាញឲ្យឃើញថា តើឯកសារណានៅក្នុងចំណោមឯកសារដែលស្ថិតនៅក្នុងឧបសម្ព័ន្ធ១៧ នោះ ត្រូវបានជ្រើសរើសដោយមេធាវីការពារ ខៀវ សំផន ដាក់ចូលនៅក្នុងបញ្ជីរបស់ខ្លួនឯងផ្ទាល់នោះ។

[១៥:៣១:២៣]

ឯកសារបី ដូចតទៅនេះ គឺឯកសារ D199/26.2.172 ដែលជារបាយការណ៍របស់ឯកអគ្គរដ្ឋទូតបារាំងប្រចាំនៅប្រទេសបារាំងផ្ញើជូនក្រសួងការបរទេសបារាំង ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៧៧។ បន្ទាប់មកទៀត ឯកសារមួយទៀត គឺឯកសារ D199/26.2.64 ដែលជាទូរលេខរបស់លោក អារណូ (Arnaud) ដែលធ្វើការនៅស្ថានទូតបារាំងប្រចាំនៅទីក្រុងប៉េកាំង ផ្ញើជូនក្រសួងការបរទេសនៅទីក្រុងប៉ារីស ពាក់ព័ន្ធទៅនឹងព័ត៌មានស្តីអំពីប្រទេសកម្ពុជា។ និងឯកសារចុងក្រោយ គឺឯកសារលេខ D199/26.2.136 ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៧៥ គឺជាទូរលេខមួយទៀតរបស់លោក អារណូ ដដែល ដែលធ្វើការនៅស្ថានបារាំងប្រចាំនៅទីក្រុងភ្នំពេញ ផ្ញើជូនក្រសួងការបរទេសបារាំង ដែលមានចំណងជើងថា “ប្រទេសកម្ពុជា”។

[១៥:៣២:៤៧]

ឯកសារទីបួន ដែលមានលេខ D199/26.2.38 ក៏មាននៅលើបញ្ជីរបស់លោក ខៀវ សំផន

ផងដែរ ហើយត្រូវបានជជែកដេញដោលរួចមកហើយកាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២។ ដូច្នេះ ខ្ញុំមិននិយាយទៀតទេ។ ហើយជាចុងក្រោយមានឯកសារបួនផ្សេងទៀតដែលចេញមកពីប្រភេទនៃឯកសារបារាំងដដែល ដែលទទួលបាននៅក្នុងកាលៈទេសៈដូចគ្នានៅប្រទេសបារាំង ដោយអ្នកស៊ើបអង្កេតនៃ អ.វ.ត.ក ដោយអនុវត្តទៅតាមដីកាចាត់ឲ្យស៊ើបសួរជំនួសរបស់សហចៅក្រមស៊ើបអង្កេត ប៉ុន្តែឯកសារទាំងបួននោះ មិនត្រូវបានទទួលយកដោយសហចៅក្រមស៊ើបអង្កេត ដើម្បីដាក់បញ្ចូលទៅក្នុងបញ្ជីរបស់ខ្លួននោះទេ ប៉ុន្តែនេះគ្រាន់តែជាការចង្អុលបង្ហាញប៉ុណ្ណោះ។ ហើយដើម្បីព្យាយាមបង្ហាញឲ្យឃើញថាមេធាវី ខៀវ សំផន គិតថាជាឯកសារអាចទុកចិត្តបាន គឺឯកសារលេខ D199/26.2.67 ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ៧៧។ ឯកសារ D199/26.2.173 ចុះថ្ងៃទី៧ តុលា ឆ្នាំ៧៧ និងឯកសារលេខ D199/26.2.36 ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ៧៧។ ឯកសារទាំងបីនេះ គឺជាលិខិតឆ្លើយឆ្លងដែលផ្ញើដោយស្ថានទូតបារាំងប្រឆាំងនៅប្រទេសចិន ផ្ញើជូនក្រសួងការបរទេសនៅទីក្រុងប៉ារីស ហើយជាចុងក្រោយមួយទៀត គឺឯកសារលេខ D199/26.2.142 ដែលជាកំណត់បង្ហាញរបស់ក្រសួងការបរទេសបារាំង ខែវិច្ឆិកា ធ្នូ ឆ្នាំ៧៦ ដែលមានចំណងជើងថា “កាលប្បវត្តិកម្ពុជា”។

[១៥:៣៤:៥០]

លោក លោកស្រីបានឃើញហើយ ប្រភេទឯកសារនេះ ត្រូវបានទទួលស្គាល់ថាអាចទទួលយកបានដោយក្រុមមេធាវីការពារក្តីខ្លួន ខៀវ សំផន ខ្លួនឯងផ្ទាល់។ ហើយក៏គាត់ជាអ្នកស្នើឯកសារនេះដែរ។ ចំពោះមេធាវីការពារក្តី អៀង សារី វិញ លោក កាណាវាស បានបញ្ជាក់នៅក្នុងសវនាការថ្ងៃទី ១៦ កុម្ភៈ ២០១២ ថាឯកសារដែលទទួលបានពីក្រសួងការបរទេសបារាំង គឺសម្រាប់តែជាគោលដៅផ្ទៃក្នុងប៉ុណ្ណោះ។ ខ្ញុំសូមដកស្រង់នូវសម្តីរបស់លោកមេធាវី កាណាវាស ដែលបាននិយាយនៅប្រហែលជាម៉ោងដប់មួយកន្លះ នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២។ បើតាមប្រតិចារឹកជាភាសាបារាំងនោះ ខ្ញុំសូមដកស្រង់ “យើងទទួលយកថា ដែលរដ្ឋាភិបាលនៅក្នុងកាលៈទេសៈធម្មតា គឺគាត់មិនព្យាយាមយល់ច្រឡំនោះទេ”។ ហើយបន្ទាប់មកទៀត គាត់ក៏បាននិយាយថា “ឯកសារទាំងនេះចេញពីក្រសួងការបរទេសបារាំងដែលហាក់ដូចជាឯកសារដែលត្រូវបានធ្វើឡើងដោយសុទ្ធចិត្ត ហើយដែលមានគោលដៅក្នុងការព្យាយាមយល់អំពីអ្វីដែលបានកើតឡើង។

អាស្រ័យហេតុនេះហើយ យើងខ្ញុំគិតថា ទោះបីជាឯកសារនេះត្រូវបានបង្កើតឡើងដោយសុទ្ធចិត្តក៏ដោយក៏វាមិនអាចជឿជាក់បានដែរ ប្រសិនបើយើងមិនអាចរកបាននៅតម្រុយឯករាជ្យដែលគាំទ្រ

ទៅលើអ្វីដែលបានកើតឡើងនោះ។ ដូច្នេះតម្លៃដែលត្រូវបានផ្តោតទៅលើឯកសារនោះ គឺមិនត្រូវមានធំពេកទេ ទោះបីជាយើងដឹងហើយថា ប្រភពដែលចេញឯកសារនោះអាចជឿជាក់បានក៏ដោយ”។

សូមបញ្ចប់ការដកស្រង់។

[១៥:៣៦:៣០]

ជាថ្មីម្តងទៀត នៅទីនេះគឺមិនមានការជជែកតវ៉ាទៅលើយថាភាពនៃឯកសារទេ គឺយើងនិយាយអំពីតម្លៃផ្តល់ទៅឲ្យខ្លឹមសារនៃឯកសារនេះ។ គឺមិនមានការជជែលកតវ៉ាអំពីយថាភាព និងភាពអាចជឿជាក់បានទេ។ ហើយកាលពីថ្ងៃច័ន្ទ កន្លងទៅនេះលោក កាណាវ៉ាស បាននិយាយថា ឯកសារទំនាក់ទំនងអន្តរជាតិទាំងអស់នេះ ហើយនិងឯកសារដែលចេញមកពីបណ្ណសារដ្ឋានបារាំងនោះ មិនអាចទទួលយកបានទេ។ ហើយប្រសិនបើឯកសារទាំងអស់នោះអាចទទួលយកបាននោះ ឯកសារទាំងអស់នោះត្រូវតែមានការគាំទ្រនិងស៊ីសង្វាក់គ្នាដោយឯកសារផ្សេងទៀត។

[១៥:៣៧:១២]

ហើយក្រោយមកទៀត ពាក់ព័ន្ធទៅនឹងឧបសម្ព័ន្ធ១៨ ដដែល គឺគាត់បាននិយាយថា “ប្រសិនបើជនជាតិបារាំងស្តាប់នូវការផ្សាយរបាយការណ៍របស់ សេ.អ៊ី.អា នោះគឺថា វាមានផ្តល់ទម្ងន់ទៅដល់ឯកសារទាំងអស់នេះ”។

ដូច្នេះ នេះគឺជាឯកសារដែលយើងមិនអាចជជែកតវ៉ាដេញដោលពាក់ព័ន្ធទៅនឹងភាព យថាភាព ភាពពាក់ព័ន្ធនៅក្នុងដំណាក់កាលនៃសវនាការនេះ ឬក៏ជជែកតវ៉ាទៅលើភាពអាចជឿជាក់នៃប្រភពឯកសារបានដែរ។ ដូច្នេះ យើងត្រូវតែអាចទទួលយកបានឯកសារនេះនៅតែមួយក្រឡេកភ្នែក។ ច្បាស់ណាស់លោក លោកស្រីនឹងកត់សម្គាល់ឃើញថា ឯកសារទាំងអស់នេះ គឺមានលក្ខណៈសម្គាល់ផ្ទៃក្នុងដូចគ្នា គឺមានន័យថា មានក្បាលទំព័ររបស់ក្រសួងការបរទេស មាននិទ្ទេសទូរលេខចូល គឺជាឯកសារទូរលេខទៅទទួលពីស្ថានទូតដោយក្រសួងការបរទេស។ ហើយមានបញ្ជីនៃអ្នកដែលត្រូវទទួលឯកសារ និងមានលក្ខណៈសម្គាល់ប្រើប្រាស់គឺដូចៗគ្នា ហើយខ្ញុំមិននិយាយច្រើនអំពីឯកសារទាំងអស់នេះទេ គឺជាឯកសារផ្លូវការដែលបានផ្ញើដោយអាជ្ញាធរបារាំងខ្លួនឯងផ្ទាល់។ ហើយចំពោះតម្លៃជាភស្តុតាងដែលត្រូវផ្តល់ទៅឲ្យខ្លឹមសារនៃឯកសារទាំងអស់នេះ ដែលត្រូវ-- ដែលសុទ្ធសឹងជាការវិភាគអំពីស្ថានភាព ឬក៏សភាពការណ៍ដែលកើតមាននៅកម្ពុជាប្រជាធិបតេយ្យ ឬទំនាក់ទំនងរបស់ប្រទេសផ្សេងទៀតនៅតំបន់ជាមួយនឹងកម្ពុជាប្រជាធិបតេយ្យ។

[១៥:៣៨:៥៣]

យើងគិតថា ការជជែកដេញដោលបែបនេះ គឺមានភាពលឿនរហ័សពេកនៅក្នុងក្របខ័ណ្ឌនៃសវនាការពាក់ព័ន្ធទៅលើភាពទទួលយកឯកសារ ហើយគួរតែមានការជជែកដេញដោលនៅពេលដែលធ្វើការ-- សេចក្ដីសន្និដ្ឋានបញ្ចប់ការដេញដោលនៃសវនាការនេះ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ខ្ញុំសូមផ្ដល់នូវឧទាហរណ៍មួយចំនួនអំពីថា ប្រព្រឹត្តការណ៍ដែលបានរៀបរាប់នៅក្នុងឯកសារទាំងអស់នេះ គឺវាស៊ីសង្វាក់គ្នាទៅនឹងប្រភពនៃឯកសារផ្សេងៗទៀត។ ខ្ញុំនឹងផ្ដល់ឧទាហរណ៍បី។ ឧទាហរណ៍ទីមួយ ឯកសារទូរលេខដែលមានលេខD199/26.2.7ដែលជាទូរលេខចុះហត្ថលេខាដោយ ម៉ាណាក (MANAC'H) ស្ថានទូតបារាំងប្រចាំនៅទីក្រុងប៉េកាំងផ្ញើជូនទៅក្រសួងការបរទេសបារាំងនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ ១៩៧៥។

[១៥:៤០:០០]

នៅក្នុងទូរលេខនេះ លោក ម៉ាណាក បានប្រកាសថាខៀវ សំផន និង អៀង សារី នឹងធ្វើដំណើរទៅកាន់ប្រទេសរ៉ូម៉ានី នាពេលឆាប់ៗខាងមុននេះ។ ព្រឹត្តិការណនេះស៊ីសង្វាក់គ្នាទៅនឹងប្រភពផ្សេងៗទៀតជាច្រើន ដោយបញ្ជាក់ថា ខៀវ សំផន ឋានៈជាឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាអគ្គមេបញ្ជាការកងទ័ពប្រជាជនរំដោះជាតិកម្ពុជា។ អៀង សារី ជាបេសកជនពិសេស ឬក៏ជាទីប្រឹក្សាពិសេសរបស់អនុប្រធានក្រុមប្រឹក្សានៃរដ្ឋាភិបាលរួបរួមជាតិ។ អៀង ធីរិទ្ធ ដែលសម័យនោះ ជារដ្ឋមន្ត្រីក្រសួងអប់រំប្រជាជន និងយុវជន និង សារិន ឆាក បានចាកចេញពីក្រុងភ្នំពេញតាមរយៈយន្តហោះមួយ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ៧៤ ដើម្បីទៅបំពេញទស្សនកិច្ចនៅប្រទេសអឺរ៉ុបជាច្រើន ដូចជា ប្រទេសអាល់បានី យូហ្គោស្លាវី និងប្រទេសរ៉ូម៉ានី ហើយនិងប្រទេស១១ទៀត នៅទ្វីបអាហ្វ្រិក។ ហើយពួកគាត់ត្រឡប់មកទីក្រុងប៉េកាំងវិញ នៅដើមខែឧសភា ឆ្នាំ៧៤។ ប្រភពទាំងអស់នេះ ដែលមានភាពស៊ីសង្វាក់នោះ គឺមានដូចជា អត្ថបទចុះផ្សាយរបស់រណសិរ្សរួបរួមជាតិកម្ពុជាដែលមានចំណងជើងថា “ដំណឹងពីប្រទេសកម្ពុជា” លេខ៧០៨ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៤ ដែលមានលេខយោង IS12.8 ហើយនៅមានទំព័រដំបូងៗនៃឯកសារ E3/40 ឬក៏ឯកសារលេខ IS3.9។

[១៥:៤១:៥១]

ឯកសារនេះ គឺឯកសារស្វ័យជីវប្រវត្តិរបស់សាក្សី TCW-694 ហើយយើងនឹងស្ដាប់សក្ខីកម្មរបស់គាត់នាពេលខាងមុខនេះ ហើយក៏បានលើកឡើងអំពីដំណើរទស្សនកិច្ចក្នុងរយៈមួយខែ នៅក្នុង

ប្រទេសអាហ្វ្រិកចំនួន១១។ ហើយមានរបាយការណ៍របស់រដ្ឋមន្ត្រីក្រសួងការបរទេសផ្ញើនៅថ្ងៃ៣០ មេសា ៧៤ នៅស្ថានទូតអាមេរិកាំងប្រចាំទីក្រុងសៃហ្គុន ដែលបានលើកឡើងអំពីអត្ថបទរបស់កាសែតញូវយ៉កថាមស៍ ដែលបញ្ជាក់អំពីទស្សនកិច្ចរបស់លោក ខៀវ សំផន នៅប្រទេសអាល់បានី យូហ្គោស្លាវីរ៉ូម៉ានី ហើយនិងបន្ទាប់មកទៀតនៅក្នុងប្រទេសអាហ្វ្រិក។ ឯកសារនេះមានលេខយោង D313/1.2.34។ មានឯកសារពីរផ្សេងទៀត ដែលមានភាពស៊ីសង្វាក់គ្នា ដែលបញ្ជាក់អំពីដំណើរទស្សនកិច្ចផ្លូវទូតនេះ គឺឯកសារលេខ D313/1.2.35 ដែលជាឯកសារដែលផ្ញើដោយក្រសួង-- ដោយស្ថានទូតអាមេរិកប្រចាំនៅទីក្រុង ប៊ុយការ៉េស ប្រទេសរ៉ូម៉ានី នៅថ្ងៃទី២ ឧសភា ឆ្នាំ៧៤ ដែលបញ្ជាក់អំពីទស្សនកិច្ចរបស់លោក ខៀវ សំផន នៅប្រទេសរ៉ូម៉ានី។ ហើយជាចុងក្រោយ គឺសាក្សី TCW-475 ដែលបានបញ្ជាក់នៅចំពោះសហចៅក្រមស៊ើបអង្កេតថាបានអមដំណើរលោក ខៀវ សំផន នៅឆ្នាំ១៩៧៤ នៅក្នុងដំណើរទស្សនកិច្ចនេះ នៅប្រទេសយូហ្គោស្លាវី និងនៅប្រទេសរ៉ូម៉ានី គឺឯកសារលេខ D201/8 ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៩។

[១៥:៤៣:៤០]

ឧទាហរណ៍ទីពីរ ដែលកើតឡើងនៅសម័យកម្ពុជាប្រជាធិបតេយ្យ គឺការចាប់ព្រះអង្គម្ចាស់ សិរិមតៈ នៅស្ថានទូតបារាំង ហើយដែលត្រូវបានរៀបរាប់ដោយឯកសារជាច្រើន ហើយជាដំបូងគឺដោយទូរលេខមួយដែលចេញមកពីបណ្ណសារដ្ឋានបារាំង ដែលត្រូវបានសរសេរដោយលោក ហ្សង់ឌីរ៉ាក (Jean Dyrac) ដែលជាកុងស៊ុលនៃស្ថានទូតប្រចាំនៅទីក្រុងភ្នំពេញនៅពេលជម្លៀស។ ទូរលេខនេះ ចុះថ្ងៃទី២០ មេសា ឆ្នាំ៧៥។ ឯកសារនេះមានលេខយោង D199/26.2.212។ ជាបន្ថែមទៀតគឺវាមានភាពស៊ីសង្វាក់ទៅនឹងឯកសារបីផ្សេងទៀត គឺទូរលេខចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ៧៥ របស់ស្ថានទូតអាមេរិក ផ្ញើជូនរដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិក ដែលមានចំណងជើង *“អាមេរិកខិន ថក អូហ្វ ភ្នំពេញ អាហ្វទ័រ ឌឺ ហ្វល”* ដែលបានរៀបរាប់អំពីការជម្លៀសប្រជាជនចេញពីទីក្រុង ភ្នំពេញដែលបានមើល ឃើញដោយពលរដ្ឋអាមេរិកមួយរូប។ ហើយដែលបញ្ជាក់អំពីការចុះចូលសិរិមតៈ ជាមួយនឹងខ្មែរក្រហម គឺឯកសារ លេខ D313/1/2.65 មានអត្ថបទដ៏ល្បីល្បាញមួយទៀត គឺអត្ថបទកាសែត ដែលសរសេរដោយ ចន ស្វេន (John Swayne) នៅក្នុងសារព័ត៌មាន ឡុងដុនថាមស៍ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ៧៥ ដែលបានរៀបរាប់អំពីស្ថានភាពប្រចាំថ្ងៃនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ហើយនិងស្ថានភាពនៅក្នុងស្ថានទូត ហើយនិងនិយាយផងដែរអំពីការចាប់ខ្លួនព្រះអង្គម្ចាស់ សិរិមតៈ នៅថ្ងៃទី២០

ខែមេសា ឆ្នាំ៧៥ នៅក្នុងស្ថានទូត។ ហើយគាត់ក៏បាននិយាយផងដែរថា ប្រជាជនកម្ពុជាទាំងអស់ត្រូវចាកចេញពីស្ថានទូត ហើយចេញក្រៅទៅជាមួយអ្នកផ្សេងទៀត គឺឯកសារលេខ E3/51 ហើយឯកសារដដែលនេះក៏មានលេខយោង D366/7.1.278។

ជាចុងក្រោយ ខ្ញុំសូមលើកឡើងនូវឯកសារមួយទៀត គឺឯកសារ D365/1.1.39 ឯកសារនេះគឺជាអត្ថបទរបស់សារព័ត៌មាន វ៉ាស៊ីនតោនប៉ុស្ដិ៍ ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ហើយក្នុងឯកសារនេះមានរាយកាណ៍ថា លោក អៀង សារី បានប្រកាសថា សិរិមតៈ ត្រូវបានសម្លាប់ចោលភ្លាមៗបន្ទាប់ពីការវាយយកទីក្រុងភ្នំពេញ។

[១៥:៤៧:០៥]

ឧទាហរណ៍ទី៣ ពាក់ព័ន្ធទៅនឹងបណ្ណសារដ្ឋានបារាំងនេះដដែល គឺជាទស្សនកិច្ចរបស់លោក អៀង សារី នៅចន្លោះថ្ងៃទី៧ មីនា និងថ្ងៃទី៣០ មីនា ឆ្នាំ៧៧ នៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ដូចជានៅភូមា ស្រីលង្កា សិង្ហបុរី ម៉ាឡេស៊ី ហើយនិង ប៉ាគីស្ថាន ហើយបានរៀបរាប់លម្អិតនៅក្នុងឯកសាររបស់ក្រសួងការបរទេសបារាំង ដែលមានលេខ D199/26.2.168។ (សុំម្ដងទៀត) D199/26.2.168 នេះគឺជាដំណើរទស្សនកិច្ចការទូតដែលមានភាពស៊ីសង្វាក់គ្នាជាមួយនឹងឯកសារផ្សេងទៀត។ ហើយពាក់ព័ន្ធទៅនឹងទស្សនកិច្ចនៅប្រទេសភូមា មានឯកសារមកពី ហ្វីប៊ីស ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ៧៧ ដែលមានលេខយោង D262.33។ នេះគឺជាប្រតិចារឹកនៃកម្មវិធីផ្សាយ ដែលចុះផ្សាយដោយវិទ្យុទីក្រុងភ្នំពេញនៅថ្ងៃទី២៩ ខែសីហា ឆ្នាំ៧៧។ ឯកសារមួយទៀតមកពី ហ្វីប៊ីស ដដែល គឺលេខ D262.28 ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ៧៧ ដែលមានចំណងជើងថា *"សាំងហ្គាពួរ កម្ពុជា អ៊ីសស្យូ ស្តេតមិន អន អៀង សារី វីស៊ីត"* ហើយមានការចុះផ្សាយចេញពីកម្មវិធីរបស់វិទ្យុភ្នំពេញជាភាសាខ្មែរនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ៧៧។

[១៥:៤៨:៥៨]

មានប្រភពបីផ្សេងទៀត ដែលមានភាពស៊ីសង្វាក់ទៅនឹងអង្គហេតុដែលមានសរសេរនៅក្នុងរបាយការណ៍របស់ក្រសួងការបរទេសបារាំង គឺឯកសារលេខ D262.29 ចុះថ្ងៃទី២ មេសា ៧៧ របស់ ហ្វីប៊ីស ដែលនិយាយអំពីដំណើរមកដល់របស់លោក អៀង សារី នៅប្រទេសស្រីលង្កា នៅអត្ថបទសារព័ត៌មានដែលមាននៅក្នុង ស្ត្រេតស៍ ថាមស៍ ចុះថ្ងៃទី២២ មីនា ឆ្នាំ៧៧ ដែលមានចំណងជើងថា "អៀង សារី ដឹកនាំគណៈប្រតិភូខ្មែរទៅកាន់ប្រទេសសិង្ហបុរី" ដែលមានលេខយោង D313/1.2.323។ ហើយ

ជាចុងក្រោយ គឺឯកសាររបស់ ប៊ី.ប៊ី.ស៊ី ដែលចេញមកពី អេស.ដាប់ប៊ិលយូ.ប៊ី ដែលមានឯកសារលេខ D56-10.069 ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ៧៧ ដែលមានចំណងជើងថា "អៀង សារី នៅប្រទេសប៉ាគីស្ថាន"។

ខ្ញុំសូមបញ្ចប់ចំពោះបណ្ណសារបារាំង ហើយខ្ញុំសូមចូលទៅឯកសារអាមេរិក គឺឯកសារអាមេរិកដែលមាននៅចន្លោះថ្ងៃទី១ តុលា ឆ្នាំ៧០ និងខែមិថុនា ឆ្នាំ៧៨ ដែលរៀបរាប់អំពីស្ថានភាពនយោបាយនៅប្រទេសកម្ពុជាក្នុងអំឡុងពេល នៅពេលផ្ញើឯកសារនេះ។ ក្នុងចំណោមឯកសារទាំងអស់នេះ គឺមានឯកសារ១៥ ដែលផ្ញើតាមទូរលេខរបស់ស្ថានទូតអាមេរិកនៅទីក្រុងភ្នំពេញ ផ្ញើជូនក្រសួងការបរទេសអាមេរិកនៅចន្លោះថ្ងៃទី១ តុលា ឆ្នាំ១៩៧០ និងថ្ងៃទី១២ ខែមេសា ឆ្នាំ៧៥។

[១៥:៥០:៤៩]

មានឯកសារទាក់ទង២១ ដែលចេញមកពីស្ថានទូត ស្ថានកុងស៊ុល ឬក៏ស្ថានបេសកកម្មប្រចាំនៅទីក្រុងសៃហ្គន ហាណូយ ប៉ុយការ៉េស ប៉ារីស តូក្យូ វៀងច័ន្ទន៍ ហុងកុង បាងកក ប៉េកាំង ហ្សាកាតា ឬក៏ស្ថានបេសកកម្មប្រចាំនៅអង្គការសហប្រជាជាតិ។ ហើយមានឯកសារទាក់ទងចំនួន១៤ ដែលមានជាទូរលេខ ឬក៏ឯកសារផ្សេងៗទៀត ដែលចេញមកពីក្រសួងការបរទេសអាមេរិក ផ្ញើជូនស្ថានទូតនានា។ ឯកសារទាក់ទងប្រាំមួយ របស់រដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិក ហើយមានកំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សាសុវត្ថិភាពអាមេរិកជាតិ ដែលប្រាំមួយ ហើយនិងមានឯកសារប្រាំមួយផ្សេងទៀតរបស់សេតវិមាន។

ពាក់ព័ន្ធទៅនឹងយថាភាពនៃឯកសារទាំងអស់នេះ ជាដំបូងខ្ញុំចង់បញ្ជាក់ជូនថា ក្នុងចំណោមឯកសារទាំង៦៨ នេះគឺសុទ្ធសឹងតែជាឯកសារផ្លូវការទាំងអស់ ហើយមួយផ្នែកធំនៃឯកសារទាំងអស់នេះគឺចុះសម័យថ្ងៃទី១៥ មីនា ឆ្នាំ៧៣ ដល់ថ្ងៃទី២២ ខែធ្នូ ឆ្នាំ៧៥ ហើយត្រូវបានផ្សព្វផ្សាយជាសាធារណៈបន្ទាប់ពីមានការទទួលយកដោយបណ្ណសារដ្ឋានជាតិសហរដ្ឋអាមេរិក ហើយនិងរដ្ឋបាលអាមេរិក។

[១៥:៥២:២៧]

ឯកសារ១៥០ នៃសម័យនោះត្រូវបានដាក់ទៅក្នុងឧបសម្ព័ន្ធ នៃសំណើលេខ D313 របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ គឺឧបសម្ព័ន្ធ៣។ ហើយឯកសារ៣៥ គឺស្ថិតនៅក្នុងចំណោមឯកសារទាំង៦៨ ដែលយើងកំពុងតែពិភាក្សានេះហើយ។ ឯកសារមួយចំនួនទៀត ក៏ត្រូវបានប្រមូលដែរ គឺចុះមុនថ្ងៃទី១៥ ខែមីនា ឆ្នាំ៧៣ ដែលត្រូវបានទទួលដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។

ហើយឯកសារជាងមួយរយត្រូវបានផ្ញើជូនសហចៅក្រមស៊ើបអង្កេត តាមរយៈសំណើរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១២ ខែកុម្ភៈ ២០១០ លេខ D366/-- (សូមទោស) លេខ D366/1 ហើយនិងចុះថ្ងៃទី ១៣ ខែមេសា ឆ្នាំ២០១០ លេខ D366/5 ដូចដែលបានឯកភាពដោយសហចៅក្រមស៊ើបអង្កេត។ ឯកសារជាង២០ ក្នុងចំណោមឯកសារទាំង៦៨ ដែលយើងជជែកពិភាក្សាគ្នានេះ គឺជាឯកសារដែលដកស្រង់ចេញពីឯកសារដែលបានទទួលយកដោយអាមេរិក មុនថ្ងៃទី១៥ មីនា ៧៣។

[១៥:៥៣:៤៤]

ហើយជាចុងក្រោយគឺ ឯកសារ-- ដីកាចាត់ឲ្យស៊ើបសួរជំនួសចំពោះអាជ្ញាធរអាមេរិក ដែលមានឯកសារ D291 ដើម្បីទទួលបាននូវឯកសារមួយចំនួន ហើយនិងឯកសារលេខ D296/1។ យើងអាចឃើញថាឯកសារមួយចំនួនត្រូវបានទទួល ជាពិសេសទូរលេខដែលចេញមកពីស្ថានទូតអាមេរិកប្រចាំនៅទីក្រុងបាងកក ហើយក្នុងនោះ ប្រាំ គឺស្ថិតនៅក្នុងចំណោមឯកសារទាំង៦៨នោះហើយ។ ហើយឯកសារចុងក្រោយនេះ គឺឯកសារដែលទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយសហចៅក្រមស៊ើបអង្កេត គឺដីកាចាត់ឲ្យស៊ើបសួរជំនួស ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩។ ចាប់ពីពេលដែលសាធារណជនអាចផ្ទៀងផ្ទាត់នូវប្រភពនៃឯកសារទាំងអស់នេះបាន ឬក៏ចាប់ពីពេលដែលអាជ្ញាធរអាមេរិកខ្លួនឯងផ្ទាល់នេះ បានផ្ញើឯកសារទៅឲ្យសហចៅក្រមស៊ើបអង្កេតនេះ គឺមានសច្ចធារណ៍យថាភាពរួចទៅហើយ ចំពោះឯកសារទាំងអស់នេះ។ ហើយសច្ចធារណ៍នេះ គឺខាងមេធាវីការពារក្ដីមិនអាចច្រានចោលបាននោះឡើយ ហើយមិនអាចនិយាយថា វាជាឯកសារក្លែងក្លាយនោះទេ។

[១៥:៥៤:៥៧]

ខ្ញុំចូលទៅដល់ភាពពាក់ព័ន្ធ។ ឯកសារ៣៧ ដែលកើតឡើងនៅមុនថ្ងៃទី១៧ មេសា ៧៥ គឺពាក់ព័ន្ធទៅនឹងបរិបទប្រវត្តិសាស្ត្រដែលកើតឡើងនៅក្នុងអំឡុងសង្គ្រាមរយៈពេលប្រាំឆ្នាំ។ ៣១ឯកសារគឺកើតឡើងនៅក្នុងសម័យនោះនោះតែម្ដង។ ក្នុងចំណោមឯកសារ៦៨, ២៦ឯកសារ ពាក់ព័ន្ធទៅនឹងតួនាទីរបស់លោក ខៀវ សំផន នៅមុន និងក្រោយខែមេសា ឆ្នាំ៧៥។ ឯកសារ១៩ ពាក់ព័ន្ធនឹងតួនាទីរបស់ អៀង សារី ហើយនិងឯកសារមួយពាក់ព័ន្ធទៅនឹងតួនាទីរបស់ នួន ជា។ ឯកសារទាំងអស់នេះមានភាពពាក់ព័ន្ធ ពីព្រោះថាភាគីច្រើន គឺពាក់ព័ន្ធដោយផ្ទាល់ទៅនឹងចលនាជម្លៀសប្រជាជនដោយបង្ខំ គឺជាពិសេសពាក់ព័ន្ធទៅនឹងការជម្លៀសចេញពីទីក្រុងភ្នំពេញ។

[១៥:៥៥:៥៤]

ឯកសារបួនពាក់ព័ន្ធដោយផ្ទាល់ទៅនឹងរចនាសម្ព័ន្ធរដ្ឋបាលមជ្ឈិមបក្ស ពីរពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធយោធារបស់កងទ័ពបដិវត្តន៍កម្ពុជា និងជាចុងក្រោយឯកសារផ្សេងទៀតនៃឯកសារអាមេរិកនេះពាក់ព័ន្ធទៅនឹងការអភិវឌ្ឍ ឬក៏ការបង្កើតនូវការអនុវត្តគោលនយោបាយទាំងប្រាំរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានពិនិត្យ ចាត់ទុកដោយសហចៅក្រមស៊ើបអង្កេត ដែលជាផែនការឧក្រិដ្ឋកម្មរួម។ ហើយក្នុងចំណោមនោះ មាន១៦ឯកសារ ដែលពាក់ព័ន្ធទៅនឹងក្រុមជាក់លាក់ ដែលតម្រង់ទិសដោយរបបខ្មែរក្រហម នៅមុន និងក្រោយថ្ងៃទី១៧ មេសា ឆ្នាំ៧៥ ហើយឯកសារផ្សេងទៀតពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខ ជំរំការងារ និងសហករណ៍។

[១៥:៥៦:៤៤]

ខ្ញុំគិតថា ខ្ញុំមានប្រាំនាទីទៀត ដើម្បីនិយាយអំពីឯកសារអាមេរិកនេះ។ តើខ្ញុំអាចបន្តទៅទៀតបានទេលោកប្រធាន?

ពាក់ព័ន្ធទៅនឹងភាពអាចជឿជាក់បាន ពាក់ព័ន្ធទៅនឹងធាតុខាងក្នុង នៅពេលដែលយើងប្រៀបធៀបឯកសារអាមេរិកដែលមានប្រភេទដូចគ្នា ដែលមាននៅក្នុងសំណុំរឿងតាមរយៈវិធីផ្សេងៗ យើងឃើញថា វាមានលក្ខណៈដូចៗគ្នា គឺមានសារទូរលេខ ឬមានលិខិតទាក់ទងផ្សេងទៀតដែលចេញមកពីស្ថានទូត ឬក៏ចេញមកពីក្រសួងការបរទេសអាមេរិក។ គឺវាមានលក្ខណៈ ចរិតលក្ខណៈសម្គាល់ដូចគ្នាដែលពាក់ព័ន្ធទៅនឹងការសម្ងាត់នៃឯកសារ ហើយនិងមានបញ្ជីយោងដែលមានជាលេខកូដសម្ងាត់ ដែលមានយោង EO ហើយនិងមានបញ្ជីអ្នកទទួលជាច្រើន។ ឧទាហរណ៍ដូចជា ស្ថានទូតពាក់ព័ន្ធ ក្រសួងផ្សេងៗ ឬក៏មន្ទីរស្ថាប័នរបស់អាមេរិក ហើយមានការសរសេរអក្សរលក្ខណៈដូចគ្នា ហើយនិងមាននិទ្ទេស *អាន់ក្លាស៊ីហ្វាយ* ឬក៏ *ឌីក្លាស៊ីហ្វាយ* ដែលបង្ហាញអំពីលក្ខណៈជាសាធារណៈ របស់ឯកសារទាំងអស់នេះ។

[១៥:៥៨:០៦]

ឯកសារទាំងអស់នេះមានរចនាសម្ព័ន្ធដូចគ្នា នៅពេលដែលសារនេះមានលក្ខណៈវែង គឺមានត្រូវបានបែងចែកជាផ្នែកជាច្រើន ហើយនៅពេលដែលមានការចម្លងឡើងវិញនូវអត្ថបទនៃទូរលេខនោះ គឺទំព័រចុងក្រោយនោះ គឺមានដាក់អក្សរថា "*មីសសេក អាត់ទ្រីប៊ីយូត*" ដែលបញ្ជាក់អំពីព័ត៌មានលម្អិតនៃទូរលេខនីមួយៗ គឺមានអ្នកផ្ញើ អ្នកទទួល ហើយនិងអ្នកចំណាត់ថ្នាក់ការសម្ងាត់ជាដើម។

ខ្ញុំសូមបង្ហាញនូវឧទាហរណ៍មួយចំនួនដែលមានលក្ខណៈស៊ីសង្វាក់គ្នាទៅនឹងឯកសារអាមេរិក

នោះ គឺឯកសារលេខ D313/1.2.79 ចុះថ្ងៃទី១៩ សីហា ឆ្នាំ៧៥ គឺជាឯកសារមួយដែលផ្ញើដោយមន្ត្រីទំនាក់ទំនងអាមេរិកប្រចាំនៅទីក្រុងប៉េកាំង ដែលបញ្ជាក់អំពីការចាកចេញរបស់លោក ខៀវ សំផន ពីប្រទេសចិននៅថ្ងៃទី១៩ សីហា ៧៥ ដែលនៅទីនោះគាត់បានបំពេញបេសកកម្មជាមួយលោក អៀង សារី ទៅកាន់ប្រទេសកូរ៉េខាងជើង ដើម្បីទៅសួរសុខទុក្ខសម្តេច នរោត្តម សីហនុ ហើយនិងបញ្ចុះបញ្ចូលព្រះឲ្យយាងត្រឡប់មកពីក្រុងភ្នំពេញវិញ។

[១៥:៥៩:៣០]

ឯកសារនេះក៏និយាយអំពីផងដែរ អំពីការចាក់ចេញពីទីក្រុងប៉េកាំងរបស់លោក អៀង សារី, សារិន ឆាក និង ជួន ប្រសិទ្ធិ ទៅកាន់លីម៉ា ដើម្បីចូលរួមប្រទេសមិនចូលបក្សសម្ព័ន្ធ និងបន្ទាប់មកទៀតទៅកាន់ទីក្រុងញូវយ៉ក ដើម្បីចូលរួមក្នុងមហាសន្និបាតរបស់អង្គការសហប្រជាជាតិ នៅខែកញ្ញា ឆ្នាំ៧៥។ ពាក់ព័ន្ធទៅនឹងវត្តមានរបស់ ខៀវ សំផន និង អៀង សារី នៅប្រទេសចិននៅចន្លោះថ្ងៃទី១៦ ដល់ថ្ងៃទី១៩ សីហា ឆ្នាំ៧៥ គឺមានប្រតិចារឹករបស់ស្ថាប័ន ហ្វីប៊ីស ដែលគាំទ្រទៅដល់ហេតុការណ៍នេះ ហើយនិងមានអត្ថបទកាសែតរបស់ញូវយ៉កថែមស៍ ដែលបានលើកឡើងអំពីព័ត៌មានដែលសរសេរដោយទីភ្នាក់ងារព័ត៌មានចិនស៊ីនហួរ ថ្ងៃទី១៦ សីហា ៧៥ ដោយមានលេខយោង D56-10.032 ពាក់ព័ន្ធទៅនឹងទស្សនកិច្ចរបស់លោក ខៀវ សំផន នៅកូរ៉េខាងជើង ហើយនិងលទ្ធផលដែលទទួលបាន ដែលជាការយាងត្រឡប់របស់សម្តេច នរោត្តម សីហនុ នៅប្រទេសកម្ពុជា នៅប៉ុន្មានសប្តាហ៍ក្រោយមកនេះ ហើយហេតុការណ៍នេះត្រូវបានបញ្ជាក់ ដោយរណសិរ្សរួបរួមជាតិកម្ពុជានៅក្នុងការបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្តីព័ត៌ពីកម្ពុជា លេខ០៣៨ ដែលមានលេខ IS12.13។

[១៦:០១:១៣]

នៅក្នុងអត្ថបទចុងក្រោយនៃទស្សនាវដ្តីនេះ ក៏បាននិយាយផងដែរ អំពីទស្សនកិច្ចរបស់លោក អៀង សារី នៅទីក្រុងលីម៉ា។ នេះគ្រាន់តែជាឧទាហរណ៍មួយចំនួន ក្នុងចំណោមឧទាហរណ៍ជាច្រើនផ្សេងទៀត ដែលបង្ហាញឲ្យឃើញថា ឯកសារឧបសម្ព័ន្ធ A17 នេះមិនអាចត្រូវបានច្រានចោលបានឡើយ ហើយយើងត្រូវពិនិត្យមើលទៅលើឯកសារផ្សេងទៀត ដែលមានភាពស៊ីសង្វាក់គ្នា ហើយក៏យើងនឹងត្រូវពិភាក្សាគ្នានៅពេលដែលមានសាក្សីមកធ្វើសក្ខីកម្មនៅពេលខាងមុខនោះ។ ដោយសារតែម៉ោងជាងបួនទៅហើយ ខ្ញុំសូមបញ្ចប់ទៅលើឯកសារ ដែលមានរបាយការណ៍១៤នេះ ខ្ញុំសូមបន្តប្រហែលជា ១៥នាទីទៀត លោកប្រធាននៅថ្ងៃ ព្រឹកស្អែកនេះ ចំពោះឧបសម្ព័ន្ធ១៧ នេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។

សូមអញ្ជើញលោកមេធាវី!

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន ខ្ញុំធ្វើសំណើដោយខ្លីនោះទេ។ ដូច្នេះហើយ ខ្ញុំមិនចំណាយពេលច្រើនទេ ហើយអត់មានពាក់ព័ន្ធទៅនឹងនាយករដ្ឋមន្ត្រីនោះឡើយ។ នៅពេលដែលខ្ញុំមើលកាលវិភាគ មិនមានរៀបចំពេលវេលាសម្រាប់ការឆ្លើយតបនោះទេ។ ដូច្នេះហើយ មេធាវីការពារក្តីស្នើសុំពេលវេលាធ្វើការឆ្លើយទៅនឹងចម្លើយតបរបស់សហព្រះរាជអជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះហើយដើម្បីជាមូលដ្ឋានសម្រាប់សវនាការ យើងខ្ញុំសូមស្នើដូច្នេះ។

[១៦:០២:៥៩]

មានចំណុចមួយចំនួនដែលទាមទារឲ្យមានការបញ្ជាក់បំភ្លឺ ហើយប្រសិនបើខ្ញុំទទួលបានពេលវេលាក្នុងការដាក់ការឆ្លើយតបនោះ ខ្ញុំគិតថាជាការល្អ ហើយវាមិនមានការប៉ះពាល់ទៅដល់ភាគីណាមួយនោះទេចំពោះការឆ្លើយតបរបស់ខ្ញុំនេះ។ ដូច្នេះហើយ គឺខ្ញុំសូមទទួលការបញ្ជាក់បំភ្លឺពីអង្គជំនុំជម្រះ ហើយបើសិនច្រើនបំផុតនោះ អាចឲ្យខ្ញុំមួយម៉ោងបាន ចំពោះក្រុមខ្ញុំ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកមេធាវី កាណាវាស សិន សឹមអង្គជំនុំជម្រះពិចារណា។

សូមអញ្ជើញលោក កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ សូមអរគុណ លោក លោកស្រីចៅក្រម។

ខ្ញុំមានសំណើដូចគ្នា ប្រហែលជាក្រុមខ្ញុំសុំតែ១៥នាទី តែប៉ុណ្ណោះ ប្រសិនបើយើងខ្ញុំទទួលឱកាសក្នុងការដាក់ការឆ្លើយតបនោះ គឺជាការល្អ។ ខ្ញុំយល់អំពីកាលវិភាគដែលបានកំណត់នៅក្នុងដីកាបង្គាប់កាលបរិច្ឆេទសវនាការ ក៏ប៉ុន្តែយើងខ្ញុំស្នើសុំដូចទៅនឹងមេធាវីមុន។ សូមអរគុណ។

[១៦:០៤:១០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខាងក្រុមមេធាវីការពារលោក ខៀវ សំផន ក៏សុំពេលដើម្បីឆ្លើយតបនេះដែរ ពីព្រោះថាការធ្វើបទជំទាស់រួចហើយ ព្រះរាជអាជ្ញាបានបង្ហាញពីការឆ្លើយតប ប៉ុន្តែយើងមិនបានធ្វើសេចក្តីឆ្លើយតបទៅវិញ ហាក់ដូចជាបាត់បង់នូវសិទ្ធិនិយាយចុងក្រោយរបស់ខាងមេធាវីការពារ។ បាទ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០៤:៤៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទសូមអរគុណ។ ទាក់ទងនឹងបញ្ហានេះ គឺថាយើងយល់ស្របនឹងសិទ្ធិដែលថាឆ្លើយតបនោះដែលថាពីមុនមកយើងធ្លាប់ធ្វើអ៊ីចឹងដែរទាក់ទងនឹងការពិភាក្សាលើឯកសារ។ បើសិនជាខ្ញុំមិនច្រឡំទេកាលថា សម្រាប់ថ្ងៃច័ន្ទ នោះគឺថាភាគីការពារក្តីអាចឆ្លើយតបទៅនឹងឯកសារ ប៉ុន្តែយើងពុំមាន ប៉ុន្តែយើងមិនមានការឆ្លើយតបទេ ខ្ញុំយល់ឃើញថា ការផ្តល់សិទ្ធិឆ្លើយតបទៅគាត់នេះជាការសមស្រប ហើយយើងក៏សូមឲ្យផ្តល់ជាកាលវិភាគឲ្យបានច្បាស់លាស់ថា តើកាលសវនាការនិយាយអំពីការពិនិត្យសំអាងហេតុទាក់ទងទៅនឹងការស្តាប់សាក្សី TCE-38 ទៅតាមរយៈវីដេអូខនហ្វេរ៉ង់នោះ តើធ្វើនៅពេលណា? ហើយឯកសារទាក់ទងទៅនឹងការពិភាក្សាទៅលើឯកសារនេះគឺថា វាអាចប៉ះពាល់ទៅដល់ការស្តាប់សាក្សី TCE-38 នេះ។

[១៦:០៦:០៦]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០៧:២០]

**ប្រធានអង្គជំនុំ៖**

បន្ទាប់ពីបានស្តាប់សំណើរបស់សុំរបស់មេធាវីការពារក្តីទាំងបីក្រុម អំពីសំណើសុំឲ្យមានឱកាសនៅក្នុងការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ហើយនិងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើឯកសារទាំងឡាយដែលភាគីបានស្នើសុំដាក់ចំពោះមុខអង្គជំនុំជម្រះ ដែលបាន

ធ្វើការពិភាក្សា និងថ្លែងរៀងៗខ្លួននៅក្នុងអំឡុងពេលពីដើមសប្ដាហ៍រហូតដល់ថ្ងៃនេះ។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ក្រុមមេធាវីការពារក្ដីទាំងបីក្រុម ដោយកំណត់ថាមេធាវីទាំងបីក្រុមមានពេលវេលាមួយម៉ោងក្នុងការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា និងក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដោយចម្លើយតបនេះគឺធ្វើបន្ទាប់ពីចម្លើយតបរបស់ក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលនឹងធ្វើបន្ទាប់ពីក្រុមសហព្រះរាជអាជ្ញា។

[១៦:០៨:៣៤]

ដំណើរការ--

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០៨:៥៨]

**ប្រធានអង្គជំនុំ៖**

បាទសូមជម្រាបផងដែរថា ដំណើរការសវនាការបន្តបន្ទាប់ គឺយើងធ្វើតាមកាលវិភាគដែលយើងបានគ្រោងទុកដែលនៅសេសសល់។ ដូចជាការដេញដោលពាក់ព័ន្ធជាមួយនឹងការធ្វើសក្ខីកម្មចំពោះអ្នកជំនាញ TCE-38 នោះគឺយើងនឹងធ្វើតាមកាលវិភាគដែលបានកំណត់ទុកបន្ទាប់ពីធ្វើការស្ដាប់ការឆ្លើយតបទៅនឹងចម្លើយតបរបស់ក្រុមមេធាវីការពារក្ដីទាំងបីក្រុម។

[១៦:០៩:៣៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០៩:៥២]

**ប្រធានអង្គជំនុំ៖**

បាទទំនងជាច្បាស់ហើយ ប៉ុន្តែឥឡូវខាងចៅក្រមគាត់បារម្ភខ្លាចជាមិនច្បាស់ គឺសូមជម្រាបថាលំដាប់លំដោយនៃការពិភាក្សាតាមកាលបរិច្ឆេទដែលបានកំណត់នេះ គឺយើងធ្វើបន្តបន្ទាប់រហូតដល់ចប់ហើយតាមទំនង គឺមិនអាច យើងធ្វើដំណើរការនៃសវនាការនេះ បន្តរហូតដល់ថ្ងៃច័ន្ទនោះទេ ពីព្រោះពេលវេលា យើងនៅពីរថ្ងៃ គឺថ្ងៃស្អែក ហើយនិងថ្ងៃខានស្អែក។ អ៊ីចឹង បញ្ហាដែលមានទាំងប៉ុន្មាននេះគឺយើងនឹងប្រឹងប្រែងធ្វើឲ្យបានចប់នូវយ៉ាងយូរគឺត្រឹមថ្ងៃព្រហស្បតិ៍។ អ៊ីចឹង របៀបវារៈដែលបានកំណត់កាលវិភាគសម្រាប់ធ្វើសវនាការរហូតដល់ព្រឹកថ្ងៃច័ន្ទនោះ យើងកិលមកដល់ត្រឹមនៅក្នុងថ្ងៃព្រហស្បតិ៍វិញ ដើម្បីធ្វើយ៉ាងណាជាបន្តបន្ទាប់រហូតដល់ចប់តែម្ដង ហើយទំនងពេលវេលាដែលយើងបានប្រើប្រាស់

នេះ ទំនងជាមិនអានឈានដល់រហូតដល់ទៅបន្តនៅថ្ងៃច័ន្ទទេ។ ហើយជម្រាបផងដែរ គឺថានៅថ្ងៃច័ន្ទ គឺយើងនឹងចាប់ផ្ដើមនៃការដេញដោលលើអង្គហេតុនៅពេលព្រឹកចំពោះជនជាប់ចោទ ហើយពេលរសៀល ចំពោះសាក្សី ដែលយើងបានកំណត់ថា គ្រោធ្វើនៅថ្ងៃអង្គារ។

ឥឡូវនេះ យើងចាប់ផ្ដើមប្ដូរនូវកាលវិភាគហ្នឹង មកចាប់ផ្ដើមធ្វើចាប់ពីថ្ងៃច័ន្ទនេះតទៅ។

**លោក អេនឌ្រូ អ៊ីនួហ្ស៊ី៖**

សូមអភ័យទោសលោកប្រធាន ខ្ញុំដូចជាយល់ច្រឡំ។ នៅថ្ងៃស្អែក សហព្រះរាជអាជ្ញានឹងបញ្ចប់ បន្ទាប់មក ថាតើយើងនឹងមានរយៈពេលកន្លះថ្ងៃ។ បន្ទាប់មក មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដូច្នេះហើយក្រោយពីខាងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមក គឺយើងឆ្លើយតប។ ហើយបន្ទាប់មក ទើបយើងស្ដាប់នូវចម្លើយសក្ខីកម្មតាមសោតទស្សន៍ ប្រហែលជានៅថ្ងៃព្រហស្បតិ៍នោះ តើត្រឹមត្រូវដែរឬទេ?

**ប្រធានអង្គជំនុំ៖**

បាទគឺត្រឹមត្រូវហើយ។ គឺយើងនឹងបន្តកិច្ចដំណើរការនីតិវិធីតាមអ្វីដែលយើងបានកំណត់នេះ គ្រាន់តែបញ្ចូលនូវរបៀបវារៈបន្ថែមទៀត គឺឲ្យមានឱកាសនៅក្នុងការជំទាស់ទៅនឹងសេចក្ដីជំទាស់របស់ -- ឆ្លើយតបរបស់ក្រុមសហព្រះរាជអាជ្ញា ហើយនិងមេធាវីការពារក្ដីប៉ុណ្ណោះ។ ចំណែកឯពេលវេលា បន្ទាប់ទៅទៀត គឺយើងអនុវត្តទៅតាមរបៀបវារៈនៃបញ្ហាដែលយើងបានកំណត់រួចហើយ។ ហើយតាម កាលវិភាគដែលយើងបានកំណត់នេះ គឺយើងនៅពីរថ្ងៃទៀត។ ដូច្នេះគឺទំនងជាមិនអាចឈានដល់ទៅ ថ្ងៃច័ន្ទទេ។ ដោយឡែកថ្ងៃច័ន្ទ ដែលយើងគ្រោងធ្វើការសវនាការចំពោះជនជាប់ចោទ នួន ជា នៅថ្ងៃ អង្គារនោះ យើងនឹងរំកិលៗនៃការសវនាការដេញដោលចំពោះជនជាប់ចោទមកថ្ងៃច័ន្ទ យើងនឹងជូន ដំណឹងនៅក្នុងស្អែកជូនដល់ភាគី។ ហើយដោយឡែកសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ក៏ដូចគ្នា ដែល យើងគ្រោងសួរដេញដោលនៅចាប់ពីរសៀលថ្ងៃអង្គារ ក៏យើងរំកិលមកចាប់ផ្ដើមពីថ្ងៃច័ន្ទដែរ ដើម្បីឲ្យ កាលវិភាគនៃកិច្ចដំណើរការសវនាការរបស់យើងហ្នឹង គឺប្រព្រឹត្តទៅបានឆាប់រហ័សនិងមានប្រសិទ្ធភាព។

[១៦:១៣:៤០]

ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការ សវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅព្រឹកថ្ងៃស្អែកចាប់ផ្ដើមពីម៉ោងប្រាំ បួន។ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ

ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងបីរូបមកកាន់បន្ទប់សវនាការនេះ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:១៤ នាទី)*